ចាន.សយ

# អធិប្បាយ

# ច្បាប់ផ្សេងៗ







សម្រាប់ថ្នាក់ទី ៦ ទំនើបជាតិ

. ច្បាប់ក្រម

. វាក្យសព្ទ . ច្បាប់កេរ្តិ៍កាល

. សទិសសូរស័ព្ទ . ច្បាប់អរិយសត្ថា

. សទិសន័យស័ព្ទ . ច្បាប់ពាក្យបណ្ដៅ

. បដិពាក្យ . ច្បាប់ភាសិត

www.budinst.go... www.el...mbodia...

៣១៤.១៣៤

អធិប្បាយ

# ច្បាប់ផ្សេង ៗ

## សម្រាប់ថ្នាក់ទី ៦ ទំនើបជាតិ

ការផ្សាយរបស់

បណ្ណាគារ **សម័យអង្គរវត្ត**

៣៤ វិថីកោះព្រាប (ក្រុងព្រះសីហនុ)

មានលក់ដុំនៅរោងពុម្ពពន្លឺពេជ្រ

លេខ ៣៣៩ វិថី កម្ពុជាក្រោម ភ្នំពេញ

បោះពុម្ពលើកទី ១

អ្នកនិពន្ធ

**ចាន់-សុយ**

២៥១១ គ.ស. ១៩៦៧

រក្សាសិទ្ធិគ្រប់យ៉ាង

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
៧០៣៤/០៣

www.budinst.gov.kh www.elibraryofcambodia.org

## ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
**អង្គការរីស្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**
**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

**www.budinst.gov.kh        www.elibraryofcambodia.org**

www.budinst.gov.kh        www.elibraryofcambodia.org

# អារម្ភកថា

ព្រឹទ្ធប្រាជ្ញស្នេហការអក្សរសាស្ត្រ   ប្រាជ្ញាយល់ច្បាស់យ៉ាងថ្លែងថ្លាន
បង្កើតក្បួនច្បាប់ដ៏ចំណាន   ដឹកនាំសន្តានកូនចៅខ្មែរ ។
ទោះបីកើតពួករាពណាមិត្ត   ត្រូវរនោតបរយោះបពិសខ្មែរ
ឡោមភាំងនាំយើងឲ្យភាពបែរ   ប្រើគេកទីបើភាសាជាតិ ។
កវីតស្ទីយក៏ងសភាបភវ   ដែរការនាញការរាំងមិនឲ្យឃ្លាត
បារបងក្បួនច្បាប់សព្រប់ជាតិ   ខ្មែរនេះទាញកកតាំងព្រាយយក្ស ។
ជាតិខ្មែរបានត្តល់ឯករាជ្យ   ហេតោះ មហោភជីតាមប្រុតព្យក្ស
សម្តេចបិតាជាឯកអគ្គ   អគ្គខ្ទេតរក៏ដាក់របស់ខ្លួន ។
សមាជលើកទីម្ភៃបីគត់   បរិញ្ញូលមត់យ៉ាងខ្ជាប់ខ្ជួន
ឲ្យប្រើភាសាហើយនឹងក្បួន   វិជ្ជាផងខ្លួនសុទ្ធតែខ្មែរ ។
កម្មវិធីសិក្សាថ្មី   សិក្សាប្រុសសិស្សស្រីជាកូនខ្មែរ
រដ្ឋាភិបាលលោកបានកែ   តាមបែបបទខ្មែរយាងកម្ម ។
គម្ពីរក្បួនច្បាប់បែបផ្សេង ៗ   យើងខំរមែងតែងតែចាំ
ត្រូវបុរាណលោកបានផ្តាំ   បង្ហាត់ឲ្យចាំតាំងពីក្មេង ។
ហេតុខ្ញុំតាំងនាមដោយប្រាជ្ញប្រាយ   ក្បួនអធិប្បាយច្បាប់ផ្សេង ៗ
ច្បាប់ក្រមកេរ្តិ៍កាលច្បាប់ព្រឹទ្ធព្រេង   បណ្ដាំក្មេង ៗ ច្បាប់ភាសិត ។

និងច្បាប់អរិយសច្ចា　　　　សំនាំសាស្ត្រាច្បាប់ដើមពិត
របខ្ញុំយកមកលៃពិនិត្យ　　　　រិះរេគ្រោះគិត　បរិយាយ ។

*ចាន់សយ* ខ្ញុំសូមអភ័យទោស　　ពាក្យពេចន៍សើសលោះនឹងប្រាជ្ញប្រាយ
សូមមិត្រពិនិត្យកែកំចាយ　　　　ផ្សិតអន្តរាយដោយអចិត្ត ។
និត្ថាសរសើរជាធម្មតា　　　　ចំពោះកិច្ចការអ្នកទំរិត
កំហុសតែងមានស្ថិតនៅនិត្យ　　　　នេះជាធម៌ពិតនៃអ្នកធ្វើ ។
ជាអវសាននៃកិច្ចការ　　　　សូមផ្ទួនកុសលបព្វអធ្វើ
ដោតភសីសព្វសារពើ　　　　សូមបានជាឈ្នើរនៃពលរដ្ឋ ។
ឯទេមរយានកម្ម　　　　ត្រូវតែចងចាំឲ្យបានស្ទាត់
សូមមានជោគជ័យកុំបីភ្ជាត់　　　　វិបត្តិហាមឃាត់សូមឃ្លាតឆ្ងាយ ។
ភាសាមានវឌ្ឍនភាព　　　　នៅលើផ្ទៃភពដែនដីអាយ
ជាតិខ្មែរមាននាមល្បីខ្ចរខ្ចាយ　　　　សូមមិត្តទាំងឡាយរៀនច្បាប់ខ្មែរ ។

ចាន់ – សយ

www.budinst.gov.kh　　www.elibraryofcambodia.org

# មុនអានសូមមេត្តាកែសិន

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| គូ | គូរ | ៥ | ៨ |
| ពាពោ | ពាពោះ | ១៤ | ១៤ |
| ក្រិឲ្យ | ក្រិត្យ | ១៦ | ៨ |
| អាគិស្សង | អាគិសង្ស | ១៧ | ៤ |
| ក្បូន | ក្បួន | ១៩ | ១៥ |
| គ្រ | គ្រូ | ២៧ | ៧ |
| មាយ | ម្ដាយ | ២៧ | ៧ |
| នាថ | នាបី | ២៩ | ១០ |
| សធិសស្សូរ | សធិសច័យ | ៣១ | ៧ |
| មានមាន | មានមានៈ | ៣២ | ១០ |
| គណា | គុណា | ៤៤ | ៣ |
| ដំណោង | ដំណោក | ៥៤ | ១៤ |
| អចៃទ្រ្ទយ៍ | អចិន្ត្រ្ទយ៍ | ៦១ | ៤ |

www.budinst.gov.kh www.elibraryofcambodia.org

| | | | |
|---|---|---|---|
| សពាន | ស្រពាន | ៧៩ | ៧ |
| ទីគ្រង់ | រីគ្រង់ | ៨៥ | ១៤ |
| ប្រហែល | ប្រហែស | ៨៨ | ១១ |
| ភ្លើតភ្លើជ | ភ្លើតភ្លើន | ៩០ | ១៣ |
| ឧហាទ | ឧហាត | ៩៦ | ៨ |
| Touche | Toucher | ១០៥ | ១៤ |
| ៗ | ៗ- | ១១១ | ១១ |
| ជ្រាង | ជ្រោង | ១១៨ | ៩ |
| ដេម | ដើម | ១១៨ | ៩ |
| លិទ្ធិ | លិទ្ធ | ១២៨ | ១០ |
| ខ្វះយាម | ខ្វះព្យាយាម | ១២៨ | ៤ |
| កំពង់ពុំដែលភ្លាប់ | កំពង់ភ្លាប់ | ១៣៤ | ៥ |
| ទុកយាន | ទុកជាយាន | ១៣៧ | ១១ |
| គ្រាះថ្នាក់ | គ្រោះថ្នាក់ | ១៤៣ | ១២ |

សូមអរគុណ

www.budinst.gov.kh www.elibraryofcambodia.org

# ច្បាប់ក្រម

| |
|---|
| នេះគឺច្បាប់ក្រម ប្រសើរឧត្តម ទូន្មានអ្នកផង |
| ប្រើទូន្មានលំនាំ កុំបីមានឆ្គង ប្រាជ្ញាបុណ្យផង |
| កើតដោយប្រណិប័តន៍ ។ |

## ការពន្យល់ពាក្យ

ច្បាប់ក្រម ន. ច្បាប់ + ក្រម = លំដាប់ច្បាប់, លំអានវិន័យ

ឧត្តម គុ. ប្រសើរ , ខ្ពង់ខ្ពស់

ទូន្មាន កិ. ដឹកនាំ , ប្រៀនប្រដៅ

ប្រាជ្ញា ន. បញ្ញា , ការចេះដឹង , ការយល់ច្បាស់

www.budinst.gov.kh www.elibraryofcambodia.org

បុណ្យ ន. កុសល. សេចក្ដីសុខចំរើន, អំពើល្អ

ប្រណិប័តន៍ ន. ការគោរព, ការយកចិត្តទុកដាក់

## ឧត្តមគតិ

បញ្ញប់ខ្មាន ឲ្យមនុស្សបេះគួរសម កុំឲ្យធ្វើបុកពា ឈ្លើយឆ្គងក្នុងទីដទៃ ៗ ឯប្រាជ្ញានិងបុណ្យ តែងកើតមាន ឡើងដោយការគោរពតាមផ្លូវកាយ គឺមានការទុនលំទោន តាមការគួរ និងការគោរពតាមផ្លូវចិត្ត គឺរៀនដោយយក ចិត្តទុកដាក់ ៗ ការគោរពចំពោះការសិក្សា រមែងនាំឲ្យកើត ប្រាជ្ញា បើប្រាជ្ញាកើតមានហើយ បុណ្យសក្តិក៏កើតឡើង ជាប្រច័ក្ខ ៗ

> នរអ្នកណា ទោះយកអាត្មា ចូលសាសន៍ពុទ្ធក្តី
> ចូរធ្វើឲ្យត្រង់ ដោយនូវបន្ទាត់ ហៅស្មូនសម្បត្តិ
> យកផ្លូវនិព្វាន ៗ

# ការពន្យល់ពាក្យ

នរៈ ន. ជនទាំងឡាយ

អាត្មា ន. អត្តៈ, ខ្លួន

សាសន៍ ន. ពាក្យប្រៀនប្រដៅ

ពុទ្ធវេត ន. ពុទ្ធៈ + វេតនៈ = កែវគឺព្រះពុទ្ធ

សម្បត្តិ ន. ទ្រព្យ, ធនធាន, ភោគទ្រព្យ

និព្វាន ន. ការរលត់ទុក្ខ, ទីគ្មានសេចក្ដីទុក្ខ

ឧត្តមគតិ

ជនទាំងឡាយ កាលតាំងខ្លួនចូលក្នុងពុទ្ធសាសនា ហើយធ្វើឲ្យត្រង់តាមគន្លងច្បាប់ នរជននោះ ឈ្មោះថា ជាអ្នកបាននូវសម្បត្តិគ្រប់យ៉ាងក្នុងបច្ចុប្បន្ន ហើយរមែងជាជនស្ថិតនៅលើមាគ៌ាដើរទៅរកព្រះនិព្វាន ពោលគឺសេចក្ដីសុខ ឥតប្រែក្លាយដោយទុក្ខភាពជាប្រក្រតី ។

www.budinst.gov.kh www.elibraryofcambodia.org

ឱអ្នកផង ទោះដឹងយល់ហោង ចិត្តនោះឲ្យហ៊ាន
ចូលបំពេញព្រះផ្នួស ដោយព្រះទូន្មាន កុំធ្វើលីកលាន
ដោយចិត្តអន្ធពាល ។

## ការពន្យល់ពាក្យ

អ្នកផង ន. អ្នកទាំងពួង, គេពល់គ្នា, មហាជន

ទោះ និ. បើសិនជា, ទុកជា

យល់ហោង កិ. យល់សូរប, យល់ច្បាស់

ព្រះផ្នួស ន. ការបួស, បព្វជ្ជា

លីកលាន គុ. បែបសោះអង្គើយ, បែបស្លូកស្មើរ

ចិត្តអន្ធពាល ន. ចិត្ត + អន្ធ + ពាល = ចិត្តល្ងីតល្ងង់

## ឧត្តមគតិ

បើយើងយល់ច្បាស់ថា ច្បាប់សម្រាប់ទូន្មានខ្លួនឲ្យល្អ
តោងយើងហ៊ានពុះពារឧបសគ្គ ចូលមកបំពេញព្រះផ្នួស

www.budinst.gov.kh www.elibraryofcambodia.org

គឺត្រូវចូលមកតាំងខ្លួនឲ្យមាំក្នុងការសិក្សា  កុំបីធ្វើចិត្តរវើរវាយ  ដោយគំនិតទុច្ចរិត ។

| |
|---|
| ម្តាយឪពុកសោតណា ស្រឡាញ់ស្ងួនភ្ងា ហៅកូនសង្សារ<br>អាចមកបំបួស ហេតុចង់សម្ភារ ប្រើចង់អន្ទពាល<br>រៀនដោយប្រក្រមច្បាប់ ។ |

## ការពន្យល់ពាក្យ

| | | |
|---|---|---|
| សោតណា | និ. | យ៉ាងណាក៏ដោយ , បែបណាក៏ដោយ |
| ស្ងួនភ្ងា | ន. | អ្នកជាទីថ្នាក់ថ្នម , បុត្រគួរថ្នាក់ថ្នម |
| សង្សារ | គុ. | ជាទីស្រឡាញ់ , ជាទីគាប់ចិត្ត |
| សម្ភារ | ន. | តេជបារមី , អំណាច , |
| ហេតុចង់ | | ព្រោះចង់ , ព្រោះតែចង់បាន |

## ឧត្តមគតិ

នៅក្នុងអត្ថបទនេះ  សញ្ញាតច្បាប់បានបញ្ជាក់ថា :

មាតាបិតា ទោះបីមានឋានៈបែបណាក៏ដោយ  តែង

www.budinst.gov.kh www.elibraryofcambodia.org

មានចិត្តចង់ឲ្យកូនចូលមកសិក្សាគ្រប់វិជ្ជា ដើម្បីឲ្យកូនបាន ទទួលយកទូវប្រទីបគឺចំណេះវិជ្ជា ក្នុងមាត្រាច្បាប់របស់ មនុស្សជាតិ ដើម្បីឲ្យកូនលះបង់នូវអវិជ្ជា គឺសេចក្តីល្ងង់ ទៅ ។

| |
|---|
| សង្វាតសរសេរ អស់អញកុំខ្ជិល ទើបបានជាគាប់ សង្វាតសូត្ររៀន ដោយគ្រូប្រញាប្តិ កុំធ្វើលេលាប់ ដោយចិត្តមាកឆ្ងាយ ។ |

## ការពន្យល់ពាក្យ

សង្វាត កិ. ប្រឹងប្រែង , ព្យាយាម , ស្រវាស្រទេញ

អស់អញ ន. យើងទាំងអស់គ្នា , អាត្មាអញ

បានជាគាប់ កិ. បានជាទីពេញចិត្ត , បានត្រឹមត្រូវ

សូត្ររៀន កិ. ទន្ទេញទង់ពិនិត្យពិច័យ

ប្រញាប្តិ ន. បញ្ញត្តិ , ការហាមប្រាម

www.budinst.gov.kh www.elibraryofcambodia.org

លេលាប់ កិរិ. ពត្ទីពត្ទើ , ស្ទាក់ស្ទើរ

មាក់ងាយ កិ. ប្រមាថ , មើលងាយ , ខុសគ្គង

## ឧត្តមគតិ

យើងជាសិស្សត្រូវតែហាត់សរសេរ និងពិនិត្យក្បួនច្បាប់ដែលគ្រូដាក់ឲ្យធ្វើ ។ កុំមើលងាយបណ្តែតបណ្តោយ ដោយគិតថា ចាំស្អែកអញធ្វើ ដោយសំអាងលើការខ្ជិលច្រអូស ។

កាលយើងលះបង់កោសដ្ឋភាព យើងនឹងបានទៅជាជនគួរគាប់ដល់គ្រូឧបជ្ឈាយនិងមាតាបិតាគ្រប់ពេលវេលា ។

ហៃអស់សាមណេរ ម្តាយមកបង្ហើរ អ្នកជាបាធ្យាយ
សង្កាត់សូត្ររៀន ដូចលោកទាំងឡាយ កុំធ្វើពាយងាយ
ដូចនៅគ្រហស្ថ ។

## ការពន្យល់ពាក្យ

សាមណេរ ន. កូនចៅរបស់សាមណៈ; លោកនេន

បង្វែរ ក. ធ្វើឲ្យបែរ

ឧបជ្ឈាយ ន. អ្នករៀនសូត្រ , សិក្ខាកាម

ពាយឆាយ ក. ប្រហែសធ្វេស , សោះអង្គើយ

គ្រហស្ថ ន. អ្នកគ្រប់គ្រងផ្ទះ , ឧបាសក

គ្រហស្ថ ≠ បព្វជិត, ពិនិត្យផង គ្រហស្ថ ≠ ព្រះហស្ត

## ឧត្តមគតិ

គេចង់ប្រដៅសិស្សានុសិស្សដែលចូលមកសិក្សា ជាចាំបាច់ណាស់ ហើយត្រូវឧស្សាហ៍សម្ភ័ររៀនសូត្រកុំបីធ្វេសប្រហែសតាមពាក្យទូន្មានគ្រូ ។ ក្រមប្រាប់ហាមមិនឲ្យសិស្សក្មេងខ្លួន គិតដូចជាជនដែលឥតរៀន គឺត្រូវយើងតាំងចិត្តឲ្យមាំថា អញជាសិស្ស ដូចនេះអ្វីជាករណីយកិច្ចរបស់អញ ? អញត្រូវធ្វើយ៉ាងណាខ្លះ ? តើអញបានបំពេញធុរៈនោះគ្រប់គ្រាន់ហើយឬនៅ ? ។

www.budinst.gov.kh www.elibraryofcambodia.org

កុំធ្វើកយមាយ នឹងគ្រូបាធ្យាយ ទុកស្មើអម្ចាស់
សង្វាតសរសេរ សូត្ររៀនឲ្យណាស់ ប្រាជ្ញាយល់ច្បាស់
នាំញាតិតាំងឡាយ ។

## ការពន្យល់ពាក្យ

កយមាយ គុ. ដែលរវើរវាយ, ពុំប្រាកដប្រជា

គ្រូបាធ្យាយ ន. អ្នកប្រៀនប្រដៅ, អ្នកបង្រៀន

អម្ចាស់ ន. ព្រះរាជា, ម្ចាស់ជីវិត

ញាតិ ន. អ្នកដែលរួមខ្សែលោហិតតាំងសន្តាន ។

**អ្នកញាតិ ៧ សន្តាន?** គេចាត់ជាពីរប៉ែកគឺ ខាងលើ ៣ ថ្នាក់ បានដល់ថ្នាក់មាតាបិតា១, ថ្នាក់ជីដូនជីតា ១ និងថ្នាក់យាយទួតតាទួត១ ។ ខាងក្រោមគឺថ្នាក់កូន១, ថ្នាក់ចៅ ១, និងថ្នាក់ចៅទួត១ បូកនឹងផងជំនាន់ខ្លួន១ទៀត គម្រប់៧ ។

### ឧត្តមគតិ

ជនដែលបង្ហាញផ្លូវដល់យើង គេសន្មតហៅថាគ្រូ ។

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងឋានៈជាសក្ខីភាព ត្រូវចាត់អ្នកទាំងនោះ ទុកដូចជាព្រះរតនៈដែរ ព្រោះគ្រូបាធ្យាយ អាចនាំឲ្យយើងមានប្រាជ្ញាយល់ច្បាស់ នូវហេតុការណ៍ពត់ជ្រៅ ៗ កាលបើយើងបានចេះដឹងច្បាស់លាស់ហើយ យើងត្រូវទៅដឹកនាំញាតិរបស់យើង ឲ្យឡើងទៅកាន់វឌ្ឍនភាព ជាទីរន្ទំផង ៗ

| |
|---|
| អាសូរមេបា ចិញ្ចឹមរក្សា កុំឲ្យអន្តរាយ<br>អាចយកមកធ្វើ ទីនគ្រូបាធ្យាយ ហេតុបង្រៀនណ្ណកាយ<br>ប្រយោជន៍ទាំងបី ៗ |

## ការពន្យល់ពាក្យ

អាសូរ ក. អាណិត, គាំទ្រតាមផ្លូវចិត្ត, អាណិតទន់ចិត្ត

រក្សា ក. បីបាច់, ឃុំគ្រង, បីបម, ថែទាំ

អន្តរាយ ន. សេចក្តីទើសទាក់, វិនាស, ការបាត់បង់

www.budinst.gov.kh www.elibraryofcambodia.org

ពណ្ណកយ    គុ. ភ្លឺត្រចះត្រចង់ , ដែលភ្លឺព្រោងព្រាត

ប្រយោជន៍  ន. អ្វីៗ ដែលគេត្រូវការ , គ្រឿងប្រកប,

លទ្ធផល

## ឧត្តមគតិ

យើងត្រូវនឹកដល់គុណបំណាច់មាតាបិតា ដែលគាត់បានបង្កើតយើង ហើយចិញ្ចឹមយើង ដោយលំបាកជាអតិបរមា លុះធំកាលណា គាត់បានយកយើងឲ្យចូលទៅសាលាដើម្បីសិក្សា ព្រោះតែចង់ឲ្យកូនចេះដឹង មានពន្លឺប្រាជ្ញាត្រចះត្រចង់ ដោយគាត់បានយល់ច្បាស់នូវប្រយោជន៍បីគឺ: ប្រយោជន៍សម្រាប់ខ្លួនយើង១, ប្រយោជន៍ដើម្បីគ្រួសារយើង១ និងប្រយោជន៍ដើម្បីជាតិយើង ១ ។

មួយចង់ក្តីច្បាប់ ឲ្យបានខ្លួនគាប់ នៅនាលោកិយ
មួយចង់ប្រាជ្ញា មិនឲ្យអប្រិយ មួយចង់បារមី
នាំញាតិទាំងឡាយ ។

www.budinst.gov.kh www.elibraryofcambodia.org

## ការពន្យល់ពាក្យ

ក្ដីច្បាប់ ន. ដំណើរច្បាប់

លោកិយ ន. លោកនេះ ទីកើតនៃសត្វសាមញ្ញ

អប្រិយ គុ. មិនជាទីស្រឡាញ់, ដែលគួរឲ្យស្អប់

បារមី ន. គុណសម្បត្តិដែលគួរបំពេញ

## បារមី ១០ យ៉ាងគឺ:

| | |
|---|---|
| ១ – ទាន ការឲ្យទាន | ៧ – សច្ចៈ រក្សាការពិត |
| ២ – សីល ការរក្សាបរិសុទ្ធ | ៨ អធិដ្ឋាន ការតាំងចិត្តយុត្តិធម៌ |
| ៣ នេក្ខម្មៈ ការកំចាត់កាម | ៩ – មេត្តា ការរាប់អានមនុស្សមិនរើសមុខ |
| ៤ – បញ្ញា ការស្គាល់សេចក្ដីពិត | ១០ – ឧបេក្ខា ការតាំងចិត្តស្មោះស្មើ |
| ៥ – វិរិយៈ សេចក្ដីព្យាយាម | |
| ៦ – ខន្តី ការអត់ធន់ | |

www.budinst.gov.kh www.elibraryofcambodia.org

## ឧត្តមគតិ

– ខ្ញុំចង់រស់នៅតាមច្បាប់ មិនចង់ឲ្យគេជិះជាន់ គឺចង់ស្ថិតនៅលើវិថីយុត្តិធម៌ , សមភាពទៅវិញទៅមក ។

– ខ្ញុំមានប្រាជ្ញាចេះដឹងហើយ តែងចង់បង្ហាញថ្វីដៃខ្លួនបំរើជាតិគឺមិនព្រមស្ថិតនៅ ដូចជាមនុស្សល្ងង់ ។

– ខ្ញុំចង់បំពេញបារមី ដើម្បីនាំញាតិរួមលោហិតទៅរកសេចក្តីសុខសន្តិភាពក្នុងអនាគតកាល ។

> ហៃអស់សាមណេរ កុំធ្វើដែលដែរ ត្រង់ក្តីពាយឆាយ<br>
> លំអុតបំរើ អ្នកជាបាធ្យាយ ជូនបុណ្យទៅម្តាយ<br>
> អាតុកទទៃ ។

## ការពន្យល់ពាក្យ

ធ្វើដែលដែរ ក. ធ្វើធ្វើសធ្វៃ

ក្តីពាយឆាយ ខ. ការប្រមាថ , ការមើលងាយ

www.budinst.gov.kh www.elibraryofcambodia.org

លំអុត  ក. ខុនលំទោន , យកចិត្តទុកដាក់

ទីទៃ  និ. ផ្សេង , ផ្សេងទៀត , ដោយខ្លួន

អាពុក  ន. បិតា , ប៉ា , ពុក , ឪពុក

## ព្រហ្មវិហារធម៌ ៤ យ៉ាង

១) មេត្តា ចិត្តអាណិត ២) ករុណា ចិត្តអាណិត ហើយជួយ ៣) មុទិតា ចិត្តទន់ភ្លន់ ៤) ឧបេក្ខា ចិត្តព្រងើយបន្តិច ៗ

## ឧត្តមពាក្យ

មាតាបិតាមានគុណូបការៈ ដល់បុត្រធីតាជាច្រើន សូម្បីតែអ្នកបួសក៏ត្រូវបំរើគាត់ដែរ កុំថាតែយើងជាមនុស្សសាមញ្ញ ៗ គុណអ្នកទាំងពីរនេះ យើងត្រូវគោរពជូនបុណ្យទៅម្ដាយមួយចំណែក និងឪពុកមួយចំណែក ស្មើភាគគ្នា តែទោះបីយ៉ាងណា ក៏ម្ដាយមានគុណធំជាងឪពុកបន្តិច ព្រោះគាត់ពពោះយើងតាំងពីនៅក្នុងផ្ទៃ ៗ

www.budinst.gov.kh www.elibraryofcambodia.org

| |
|---|
| សង្វាតសូត្ររៀន កុំធ្វើអៀនប្រៀន ក្នុងចិត្តសព្វថ្ងៃ<br>លំអុតបំរើ ផ្គាប់ដោយហឫទ័យ ធារម្ភរៃម ។<br>ក្តីច្បាប់កុំចំបង់ ៗ |

## ការពន្យល់ពាក្យ

អៀនប្រៀន គុ. ដែលមុខដូរអៀរមៀរ, ក្រអឺមក្រអៀម

ចិត្ត ន. អារម្មណ៍ត្រិះរិះ , ធម្មជាតដែលរិះគិត

ធារម្ភ កិ. ព្រួយ , សញ្ជឹងគិត

រៃម ៗ កិវិ. រឿយ ៗ , ញឹកញយ , ញឹក ៗ

## វេវចនសព្ទឬសទិសន័យសព្ទ

ចិត្ត = ចិត្តា = ហឫទ័យ = ព្រះទ័យ =
ចេតនា = ដួងចៃ = សន្តាន

## ឧត្តមគតិ

ដើម្បីឲ្យបានឆាប់ចេះ គេមិនត្រូវខ្មាសអៀននឹងគ្រូ

www.budinst.gov.kh www.elibraryofcambodia.org

បាធ្យាយហើយ សមដូចពាក្យថា «ខ្មាស់គ្រូខ្សត់វិជ្ជា ខ្មាសភរិយាខ្សត់កូន» លើន័យនេះ បញ្ជាក់ថា បើយើងនៅបំរើឬសិក្សានឹងគ្រូណា យើងត្រូវគោរពគាត់ តែគប្បីយើងកុំខ្លាចសាកសួរ ចំពោះវិជ្ជាដែលយើងឆ្ងល់ឲ្យសោះៗ

បើយើងនៅជាមួយអ្នកចេះ តែយើងមិនយកចិត្តទុកដាក់សាកសួរទេ ប្រៀបដូចជាវែកនៅក្នុងឆ្នាំងសម្ល ហើយមិនស្គាល់រសជាតិសម្លអំបិលដែរ ។

| |
|---|
| ច្បាប់នេះសោតណា ទូន្មានអាត្មា ដោយនូវក្រិត្យសង្ឃ<br>គ្រង់ណាហៅច្បាប់ កាន់ខ្ជាប់កុំបីបង់ ចំណាស់ទៅលង់<br>ខ្លួនបានជាធំ ។ |

## ការពន្យល់ពាក្យ

សោតណា និ. យ៉ាងណាក៏ដោយ, ទោះបីយ៉ាងណាក៏ដោយ

អាត្មា ន. អត្តៈ, ខ្លួន, រូបកាយ

ក្រិត្យសង្ឃ ន. ច្បាប់សង្ឃ, វិន័យសង្ឃ

www.budinst.gov.kh www.elibraryofcambodia.org

ចំណេរ ឧ. កាលដ៏យូរ , ពេលដ៏វែង

កុំបីបង់ ឧ. កុំបីចោល , កុំបោះបង់ចោល

## សទិសសូរស័ព្ទ

## សង់ផ្ទះ , សង្ស័យ–សង្កា , អាធិស្បង់៖ ព្រះសង្ឃ

### ឧត្តមគតិ

ច្បាប់ណាក៏ដូចច្បាប់ណាដែរ តែងតែបង្អុលបង្ហាញនូវចំណុចក្រិត្យនៃពួកក្រុម ទោះបីក្នុងមុខដំណែងណាក៏ដូចគ្នាដែរ ។ លក្ខណៈដែលស្ដីពីបរិយាសណ្ដាប់ធ្នាប់ នៃការរស់នៅដ៏ល្អក្នុងសង្គមគ្រួសារ ហៅថាច្បាប់ ។ កាលណាបើយើងបានសិក្សា ហើយមានការប្រព្រឹត្តិផ្សំជាមួយផងនោះ យូរទៅគង់បានជាធំមិនខាន ។

សព្វថ្ងៃសោតណា ខ្ទាងអាត្មា ដោយនូវក្រិត្យក្រម
បំពេញព្យាយាម ឲ្យមានបារម្ភ ទើបខ្លួនជាធំ
ទៅដល់មហាក្សត្រ ។

## ការពន្យល់ពាក្យ

ដោយឡែក អា. និ. ទី ៣ (សម្រាប់ប្រើនៅខាងមុខនាម)

ដោយឡែកអំពីពាណា, ដោយឡែក...

ទៅ កិ. ស្ដិត. មាន ។ កិ. វិ. (ដែលមិនទាន់

អស់) ហើយឬនៅ ?

ក្រិត កិ. លាក់ចំណាំ. គូសសំគាល់. ក្រិតឈើ

ក្រិត្យ ន. កិច្ច. វិន័យ, ច្បាប់

ក្រឹត គុ. អព្យាក្រឹតភាព នយោបាយអព្យាក្រឹត

មហាក្សត្រ ន. ក្សត្រជាធំ, ក្សត្រដ៏ប្រសើរ

### ឧត្ដមគតិ

លក្ខណៈនៃប្រគេទក្រមខាងលើ បានបញ្ជាក់ថា បើ

យើងរបេះដូង យើងត្រូវប្រព្រឹត្តតាមក្រិត្យច្បាប់ ហើយកុំ

ភ្លេចគុណបំណាច់ អ្នកដែលមានគុណដល់ខ្លួនពីពេលមុនៗ

កាលបើ យើងយកចិត្តទុកដាក់នឹងក្សន្ដច្បាប់ អនាគត

www.budinst.gov.kh www.elibraryofcambodia.org

យើងរមែងតែងតែបានផងធំ ស្ថិតនៅជិតព្រះមហាក្សត្រ ដោយពិត ។

| |
|---|
| ច្បាប់នេះសោតណា ខ្ញុំបានអាត្មា ថេរនៅពុំបាត់ ទោះខ្លួនឥតបុណ្យ បំរើមហាក្សត្រ គោរពប្រណិប័តន៍ យសនោះពុំលែង ។ |

## ការពន្យល់ពាក្យ

ថេរនៅ គំ. តាំងនៅ, ស្ថិតនៅ

យស ន. បរិវារ, អានុភាព, សេចក្ដីរុងរឿង

ពុំលែង និ. ឥតខាន, មិនដែលឥត

## ឧត្តមគតិ

ច្បាប់ជាទ្រឹស្ដីស្ថិតនៅជានិច្ច ទោះបីក្នុងកាលៈទេសៈណាក៏ដោយ ច្បាប់តែងតែសំនៅជានិច្ចនិរន្តរ ។ រូបមនុស្សបាត់ទៅ ក្បួនច្បាប់ស្ថិតនៅជានិច្ច ហើយ

www.budinst.gov.kh www.elibraryofcambodia.org

មានរូបកាន់សំនួនអំហាររស់នៅរើកគ្រប់ពេលវេលា ។
ពោះបើពេលនេះ យើងជាអ្នកឥតបុណ្យក៏ដោយ បើយើង
គោរពប្រណិប័តន៍ គឺយកចិត្តទុកដាក់នឹងការងារទៅ
យសសក្តិមុខតែកើតឡើងជាមិនខាន ។

| |
|---|
| ហេតុបានទឹងច្បាប់ កាន់ជួបបង្គាប់ ចិត្តគ្រូយល់ស្តែង<br>ពោះទៅចំរើ ស្តេចជាតម្លែង យសនោះពុំលែង<br>ប្រាកដពណ្ណកាយ ។ |

## ការពន្យល់ពាក្យ

យល់ស្តែង ក. យល់ច្បាស់ , ស្គាល់ជាក់ស្បាន់

ស្តេច ន. ក្សត្រិយ៍ , អ្នកដែលកើតក្នុងវង្សក្សត្រ

តម្លែង គុ. ដែលជាធំ , ជាម្ចាស់

ប្រាកដ ន. ពិត , ប្រត្យក្ស ,

| |
|---|
| គិង + គឹង + ហ្គឹង . ពិនិត្យទំព័រ ២៣ |

## ឧត្តមគតិ

សិស្សដែលយកចិត្តទុកដាក់ នឹងការសិក្សាដោយមិនម៉ាត់ ត្រូវតែងពេញចិត្តកោតសរសើរជានិច្ច ។ បើទៅបំរើស្តេច ហើយគោរពចំពោះការងារបែបនេះ នោះយសសក្តិតែងបានចាប់ឡើងយ៉ាងរហ័ស ។

ក្តីនេះជាច្បាប់ ឲ្យសាមណេរគ្រប់ សព្វសរិលទាំងឡាយ
កុំសើចតិះដៀល អ្នកជាបាច្យាយ អ្នកហានស្នើម្តាយ
បង្កើតក្តីច្បាប់ ។

## ការពន្យល់ពាក្យ

គ្រប់ — កិ. យកតម្រាប់ , ធ្វើតាមគេ

សព្វ — គុ ទាំងអស់ . ទាំងតួង , ទាំងស្រុង

សរិល — ន. សរីរៈ , អត្តភាព , រាងកាយ

តិះដៀល — កិ និន្ទាកន្ទើកំប៉ាំងមុខ

អ្នកហាន — ន. អ្នកទាំងនោះ , អ្នកផង

www.budinst.gov.kh www.elibraryofcambodia.org

# សទិសសព្ទ ឬ សទិសស្វរសព្ទ

## គ្រប់សព្វ + យល់សប្តិ + ព្រះសព + សប់ កង់ + សប្តាហ៍ = ៧ ថ្ងៃ

### ឧត្តមគតិ ១

ដោយយល់ឃើញថា៖ ច្បាប់សព្វយ៉ាងកាលមើកបង្កើតឡើងហើយ តែងមានការមិនសមរម្យខ្លះមិនខាន ហេតុនេះ បើក្តីច្បាប់ត្រង់ណាខុសបន្តិចបន្តួច ឬអ្នកបង្កើតច្បាប់ត្រឹមត្រូវ បានលទ្ធផលល្អដែរ តែការប្រព្រឹត្តនៃម្ចាស់ច្បាប់ មិនសូវត្រឹមត្រូវតាមច្បាប់នោះ ៗ យើងជាសិស្សមិនត្រូវសើចតិះដៀលទេ „ពុតគ្រូកុំគ្រាប់ ច្បាប់គ្រូឲ្យយក„ ៗ

សាមណេរណា ៗ ពោះមានប្រាជ្ញា ទឹងចង់រៀនគ្រាប់
ឲ្យយកគ្រូបៀក នោះខុនខូលស្លាប់ ធ្វើដោយក្រមច្បាប់
នៃគ្រូបាធ្យាយ ៗ

www.budinst.gov.kh www.elibraryofcambodia.org

## ការពន្យល់ពាក្យ

ពោះពាន   និ. ទុកជាមាន , បើទុកជាមាន

និង   និ. សម្រាប់តពាក្យ អ្នកនិងខ្ញុំ , គេនិងគាត់

នឹង គ. បុក. ស្ងៀម , ទឹកនឹងថ្កល់, ។ កិនុ. ខ្ញុំនឹងទៅ

ហ្នឹង កិ.សេ. នុះ , ហ្នឹងហើយ , ហ្នឹងឯងកើតក្អើន

## ប្រាជ្ញាកើតដោយហេតុ៣យ៉ាង

– ប្រាជ្ញា កើតឡើង ដោយការរៀន

– ប្រាជ្ញា – ដោយការស្ដាប់

– ប្រាជ្ញា – ដោយការគិត

## ឧត្តមគតិ

ធម្មជាតិបង្កើតមនុស្សឡើង តែងមានប្រាជ្ញាប្រចាំក្នុងខួរសេរីពិត ប៉ុន្តែបើយើងមិនបង្កើនកម្លាំង ក្នុងការចូលទៅជិត ចំពោះការស្ដាប់ ដោយយកចិត្តទុកដាក់ និងការ

ពន្យល់របស់គ្រូទេ នោះខ្លួនប្រាជ្ញាក៏មិនអាចកើតមានដែរ។

| |
|---|
| សាមណេរណាសោត ចិត្តនោះក្រេវក្រោធ ឲ្យចៀស |
| ចេញឆ្ងាយ |
| ច្បាប់នេះមិនទំ សាមណេរចាំងឆ្ងាយ តាមចិត្តសប្បាយ |
| អាត្មាទីទៃ ៗ |

## ការពន្យល់ពាក្យ

ក្រេវក្រោធ កិ. ខឹងគួង , ខឹងក្រវីក្រវា

ចៀសចេញ កិ. ថយចេញ , ដកឃ្លាផុត

សប្បាយ កិ. រីករាយ , បីតិប្រាមោទ្យ

អាត្មាទីទៃ ន. ដោយខ្លួន , ផ្សេងពីអាត្មា

## ឧត្តមគតិ

ក្នុងការរួមរស់សិក្សា បើសិស្សណាមួយខឹង មាន ចិត្តពាសៈកើតឡើង យើងត្រូវចៀសចេញឲ្យឆ្ងាយលុះ ដលបាត់ក្រោធសឹមយើងវិលមកពន្យល់ដឹកនាំ ៗ បើចិត្ត

www.budinst.gov.kh www.elibraryofcambodia.org

សាមណេរនៅទីកកាយ គឺសិស្សនៅទៀតសប្បាយហួស ហេតុយើងមិនត្រូវតាំងខ្លួនឲ្យសប្បាយដូចគេឡើយ គឺត្រូវទុកខ្លួនឲ្យទីទៃពីគេវិញ បើករណីយកិច្ចខ្លួនមិនទាន់ស្រេច ។

| |
|---|
| ទរអ្នកណា នឹងស្វែងប្រាជ្ញា ឲ្យបានខ្លួនថ្លៃ<br>ចូរដឹងខុសគាប់ ដោយអធ្យាស្រ័យ ផ្គាប់ដោយហឫទ័យ<br>អ្នកជាបញ្ញាយ ។ |

## ការពន្យល់ពាក្យ

ស្វែង កិ. ស្រាវរក , ស្កាត់រក

ខ្លួនថ្លៃ ន. ខ្លួនថ្កើងថ្កាន

ខុសគាប់ ន. ខុសត្រូវ , គុណវិបត្តិនិងគុណសម្បត្តិ

អធ្យាស្រ័យ ន. ការប៉ងទុក , បំណងចិត្ត

## ឧត្តមគតិ

នរជនទាំងឡាយ អ្នកស្វែងរកប្រាជ្ញា ដើម្បីឲ្យបាន

www.budinst.gov.kh www.elibraryofcambodia.org

ខ្លួនថ្ងៃថ្ងរ គប្បីយើងដឹងខុសត្រូវដោយការកំណត់ចិត្តក្នុងការផ្ចាប់ចិត្ត នៃជនជាគ្រូបង្រៀន ។ ជាពិសេសសាស្ត្រាចារ្យ តែងមានការពេញចិត្តចំពោះសិស្សប្រពៃណា ដែលឧស្សាហ៍រៀនសូត្រ ចេះមេរៀនដែលគាត់ដាក់ឲ្យសិក្សា ។

| |
|---|
| តោះទឹងស្ងួនធម៌ ឲ្យមានសំគាល់ កុំធ្វើកយមាយ<br>ព្រោះទឹងស្ងួនច្បាប់ កាន់ខ្ជាប់កុំបំណាយ កុំឲ្យអន្តរាយ<br>នូវច្បាប់ក្រមផង ។ |

## ការពន្យល់ពាក្យ

ធម៌ ន. ធម្ម , ធម្មជាតិទ្រទ្រង់សត្វ ច្បាប់

សំគាល់ កិ. ពិនិត្យ ; ចំណាំ , កំណត់ទុក

កុំបំណាយ និ. កុំបំគ្រប់គ្រាន់ , កុំគិតថាល្អម

អន្តរាយ ន. ការវិនាស , ភាពហិនហោច

## ឧត្តមគតិ

- បើមិនជាយើងស្មើគេផង ត្រូវតាំងចិត្តកុំឲ្យពាយមាយ ក្នុងដំណើរហេតុផ្សេង ៗ គឺត្រូវធ្វើចិត្តឲ្យស្ងប់ស្ងាត់ កុំឲ្យធ្វើតាមដំនោរតណ្ហាលោភលន់ ។

- បើយើងស្មើគេគ្រប់ លុះត្រាតែយើងកាន់ខ្ជាប់នូវច្បាប់ទាំងនោះ កុំឲ្យវិនាសសាបសូន្យ ដោយហេតុគ្រាន់តែដឹង តែមិនគោរពតាមច្បាប់ ។

> គ្រូឧបាធ្យាយ ប្រដូចនូវម្ដាយ ឪពុកយើងផង
> ហ្វឹកហ្វឺនប្រដៅ មិនឲ្យមានឆ្គង តាមដោយគន្លង
> ព្រេងព្រឹទ្ធបុរាណ ។

## ការពន្យល់ពាក្យ

ហ្វឹកហ្វឺន កិ. បង្ហាត់ , ហាត់ពត់

ឆ្គង គុ. ដែលខុសទំនង , ដែលខុសបែប

ព្រេងព្រឹទ្ធ ន. ចាស់ពីព្រេងនាយ

www.budinst.gov.kh www.elibraryofcambodia.org

បុរាណ    ន. ជំនាន់មុន , បុព្វសម័យ . បុព្វកាល

## សទិសសូរស័ព្ទ

## ព្រេងព្រឹទ្ធ + ព្រឹទ្ធាចារ្យ + ព្រឹត្តិប័ត្រ + ប្រព្រឹត្ត—ត្តិ

## ឧត្តមគតិ

សាស្ត្រាចារ្យជាអ្នកបង្រៀន គេទុកដូចជាម្តាយ និងឪពុកទាំងទ្វេហា ព្រោះអ្នកទាំងពីរនេះ គាត់បានបង្ហាត់ បង្ហាញយើងឲ្យយល់ច្បាប់ និងប្រព្រឹត្តតាមមាគ៌ាមហាគ្រឹះ វប្បធម៌ នៃបាស់ព្រឹទ្ធាចារ្យពីបុរាណ ក្នុងការវិវត្តទៅរក វឌ្ឍនភាពគ្រប់វិស័យ ។

| | | |
|---|---|---|
| នរអ្នកណា | នឹងស្វែងប្រាថ្នា | ជាស្មើប្រាណ |
| ឲ្យគិតជញ្ជឹង | រំពឹងលែងបាន | កុំធ្វើបំពាន |
| | ប្រចុស្តរឹងស្នួង ។ | |

## ការពន្យល់ពាក្យ

រស្មី    ន ពន្លឺភ្លឺចេញ , រង្សី

ប្រាណ ន. អត្តនូ, ខ្លួន, គ្រោងខ្លួន

ធ្វើបំពាន កិ. ធ្វើទាំងរំលោភ

ប្រទូស្ត គុ. ធ្វើទុកបុកម្នេញ, ប្រទូសរ៉ាយ

វិងស្វាង គុវិ. ដែលលឿនអស់ល្បឿន

## ឧត្តមគតិ

ប្រាជ្ញាចាត់ទុកជាពន្លឺស្មើមួយ ដ៏ក្លៀតប៉ះគ្រប់ សម្រាប់បំភ្លឺខ្លួនប្រាណនៃមនុស្សម្នាក់ ៗ ហេតុនេះហើយជាអ្នករៀនសូត្រមិនត្រូវធ្វើបំពានប្រទូស្តនឹងក្បួនច្បាប់ គឺប្រលែងខ្លួនឲ្យធ្លាក់ចុះ ក្នុងអំពើអមនុស្សធម៌ឡើយ ។

| |
|---|
| នាយហៅគ្រូ ដូចអ្នកនាំផ្លូវ ដើរដោយគន្លង<br>ពោះទីងគោះទៅ ស្រុកតូចធំផង សឹងដូចបំណង<br>នៃចិត្តចិន្តា ។ |

## ការពន្យល់ពាក្យ

នាយ ន. វីង, ចម្ងាង, ដែលហៅថា

www.budinst.gov.kh www.elibraryofcambodia.org

ព្រោះទៅ កិ. សំដៅទៅ , លីលាទៅ

បំណង ន. ការប៉ុនប៉ង , សេចក្ដីប្រាថ្នា

## ឧត្តមគតិ

សិក្ខាកាមជាសិស្សានុសិស្ស ដែលចូលមកសិក្សា ប្រៀបដូចជាអ្នកមានបំណង ដើរទៅកាន់ចំណុចដៅ គឺ វិជ្ជាជាន់ទាបខិតជាន់ខ្ពស់ ៗ ឯគ្រូ ឧបមាដូចជាអ្នក សម្រាប់នាំផ្លូវព្រោះទៅកាន់ស្រុកភូមិ ដែលសិស្សមាន បំណងនឹងព្រោះទៅ ៗ ដោយន័យនេះ បើអ្នកនាំផ្លូវ មិនសូវស្គាល់ផ្លូវទេ មុខជានាំឲ្យទៅប៉ះពារលើគ្រោះថ្នាក់ ជាមិនខាន ៗ ដូច្នេះ បើគ្រូប៉ុនពន្យល់ សិស្សក៏ងាយ យល់ហើយបានឆាប់ទៅជាសិស្សពូកែទៀតផង ៗ

រីឯចេះងង ដូចអ្នកវង្វេង កណ្ដាលអន្ធ
ពុំនោះដូចខ្វាក់ តែម្នាក់អាត្មា បរចេញយាត្រា
ឥតអ្នកដឹកដៃ ៗ

ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

## ការពន្យល់ពាក្យ

ទីទៃ ន. ចំណែកទីទៃ, ដែលទីទៃ

រង្វើរ កិ. ប្រឡំ, ភាន់ភាំង, ភ្លេច

អធ្វា ផ្លូវ, ជនវិថី, ជនផ្លូវ

ពុំទោះ ន. មួយទៀត, មួយវិញទៀត

យាត្រា កិ. ចរចេញ, លីលា, ចេញចាក

## វេវចនសព្ទ ឬ សទិសសទ្ទសព្ទ

## អធ្វា = ផ្លូវ = វិថី = មាគ៌ា = មគ្គៈ = បថ = កន្តារៈ

ធម្មតាសិស្សដែលរៀនដឹងបាន ដោយអាស្រ័យគ្រូជាអ្នកដឹកដៃ ៗ សូម្បីព្រះពុទ្ធ ក៏ព្រះអង្គបានទៅរៀនសារមួយអាឡារតាបស និងឧទ្ទកតាបសទាំងពីរដែរ មុននឹងចេញទៅស្វែងធម៌ ៗ ដូច្នេះ នរណាម្នាក់ ដែលរៀនហើយគ្មានគ្រូនោះ គេអាចបាត់ជាមនុស្សម្នាក់ ដើរវង្វើងផ្លូវតែម្នាក់ឯង ដោយឥតអ្នកកូដឹកដៃ ៗ

www.budinst.gov.kh www.elibraryofcambodia.org

សូម្បីរកផ្លូវ    ពុំដែលនឹងត្រូវ    សឹងពានឯព្រៃ
ហេតុផ្សិតចេះឯង    ឥតអ្នកដឹកដៃ    ចិត្តនោះសង្ស័យ
ដូចដល់ពុំដល់ ។

## ការពន្យល់ពាក្យ

ពុំដែល    ទិ    មិនដែល , ឥតដែល

សឹងពាន    កិ.    មុខតែប៉ះ , ត្រូវតែប៉ះពារ

ហេតុផ្សិត    និ.    ព្រោះតែ , ហេតុតែ

សង្ស័យ    ន.    ងឿងឆ្ងល់ , គិតមិនដាច់

### ឧត្តមគតិ

អ្នកដែលមានមាន រឹងត្អឹង រៀនតែខ្លួនឯង មិនយកអ្នកដទៃធ្វើជាគ្រូនាំផ្លូវ តែងប៉ះពារលើឧបសគ្គជានិច្ច ហើយចិត្តដែលគិតនោះ មិនអាចដឹងខុសឬត្រូវចំពោះខ្លួនឯងផង ពោះបើ ការគិតនោះចំលើចំណុចល្អ ក៏ការសង្ស័យ នៅតែមិនទាន់ដាច់ស្រេច ចំពោះធាតុពិត ។

www.budinst.gov.kh    www.elibraryofcambodia.org

ះនេះដូចអ្នកផង ពុំដោយគន្លង នៃលោកណាយល់
សឹងផ្ដើមោហោ ទោសោកំហល ពុំអាចទប់ទល់
នាធ្ងន់ឥតស្រាល ។

## ការពន្យល់ពាក្យ

អ្នកផង — សព្វ អ្នកទាំងឡាយ , អ្នកដទៃ

មោហោ ន. ការវង្វេង , សេចក្ដីល្ងីតល្ងង់ , អវិជ្ជា

ទោសោ ន. កំហឹង , សេចក្ដីក្រេវក្រោធ

ទប់ទល់ កិ. ទប់ទ្រ , តតាំង, ភកាំង

នា អា.ន. ពួក . ត្រង់ , នាធ្ងន់ៈ ត្រង់ធ្ងន់

## ពាក្យផ្ទុយ ឬ បដិពាក្យ

ទោសៈ ≠ អទោសៈ , មោហៈ ≠ អមោហៈ

លោភៈ ≠ អលោភៈ . ធ្ងន់ ≠ ស្រាល

www.budinst.gov.kh www.elibraryofcambodia.org

## ឧត្តមគតិ

អ្នកដែលមិនបានគោរពតាមច្បាប់ របស់មនុស្សធម៌ ព្រោះហេតុលង់ខ្លួនក្រោមចំណោទ មោហៈនិងទោសៈ ។ មេធម៌ទាំងពីរនេះ ជាឫសគល់នៃអកុសល សម្រាប់ទាញជនឲ្យធ្លាក់ចុះក្នុងរណ្ដៅលាមក គឺទុច្ចរិតបីយ៉ាង " កាយទុច្ចរិត , វចីទុច្ចរិត និងមនោទុច្ចរិត " ហើយរមែងទទួលយកនូវភយន្តរាយ ក្នុងឆាកជីវិតមិនគប្បីខាន ។

ប្រសើរក្ដីច្បាប់ សឹងជាពុំគាប់ ហេតុចិត្តអន្ធពាល
ក្ដីច្បាប់ទម្ងន់ សឹងជាជាស្រាល ហេតុចិត្តអន្ធពាល
ចង់តែសប្បាយ ។

## ការពន្យល់ពាក្យ

សឹងជា ន. បេះតែថា , រកកលថា

ពុំគាប ន. ពុំពេញចិត្ត មិនគាប់អធ្យាស្រ័យ

www.budinst.gov.kh www.elibraryofcambodia.org

ហេតុចិត្ត      ន. ព្រោះចិត្ត ,  ព្រោះតែចិត្ត

# សទិសសូរស័ព្ទ

## ចិតខ្មៅដៃ+សន្តានចិត្ត+ល្អវិចិត្រ+វិចិត្រសិល្បៈ

### ឧត្តមគតិ

ដំពូកដងមួយផ្លែក បើគេប្រដៅឲ្យល្អ បែរជាពោល ថាពុំគាប់ទៅវិញ ព្រោះតែចិត្តខ្លួនអន្ធពាល ៗ មួយ ស្រទាប់ផងទៀត មានមនោគមស្និតនៅលើការស្រើប ស្រាល មិនព្រមប្រព្រឹត្តតាមលក្ខណៈច្បាប់ ដែលខ្លួនបាន បេះដឹង ក៏បណ្តោយខ្លួនឲ្យធ្លាក់ក្នុងរណ្តៅខ្មៅងងឹត គឺ មនុស្សពាលអបលក្ខណ៍ ៗ

ពុំដឹងដើមគ្រឹប  បង្កើតអគិរូប៍  ប្រដូចទៅម្តាយ
ក្ដីពីមនុស្សលោក រួចផល់ស្លូតទាយ ចៀសចតុកបាយ
នរកទាំងបួន ៗ

www.budinst.gov.kh www.elibraryofcambodia.org

## ការពន្យល់ពាក្យ

អភិរូប៍ ន. ការផុះផាល ការលូតលាស់

បដូច កិ. ប្រៀបឲ្យដូច , ប្រៀបប្រហែល

មនុស្សលោក ន. សត្តនិករ , ប្រជាជន . ពស្ត្រទូទៅ

សួគ៌ ន. ទេវលោក , លោកទិព្វ , ឋានទេវតា

ចតុរាបាយ ន. ចតុ + អបាយ = អបាយ ៤ យ៉ាង ។

## ឧត្តមគតិ

សាស្ត្រាចារ្យ ជាអ្នកបង្ហាត់បង្ហាញ ប្រៀបប្រដូចទៅនឹងម្ដាយ ដែលលោកដឹកនាំឲ្យយើងបានរួច ក្នុងចំណោមមនុស្សលោកនេះ រហូតដល់ឋានសួគ៌ ជាពិសេស គឺចៀសឲ្យផុតនូវអបាយទាំង ៤ យ៉ាង គឺ នរក ប្រេត , អសុរកាយ និងតិរច្ឆាន ។

www.budinst.gov.kh www.elibraryofcambodia.org

ទាបីហៅគ្រូ  កុំធ្វើមូទូ  ចិត្តនោះឲ្យស្លូន
កុំធ្វើធំកើង  ចង់ធំតែខ្លួន  ក្រែងបាបមកបួន
នៅនាលោកិយ ។

## ការពន្យល់ពាក្យ

មូទូ  កិវិ. ទន់, អន់ខ្សោយ, សោះអង្គើយ ។
គុ. មិនស្រួល

ឲ្យស្លូន  កិ. ឲ្យថ្នម, ឲ្យប្រយ័ត្ន

បាប  ន. អំពើអាក្រក់, អំពើពុំប្រសើរ

លោកិយ  គុ. ដែលមានក្នុងលោក, ដែលទាក់ទងក្នុងបច្ចុប្បន្ន

## ឧត្តមគតិ

ជនប្រភេទខ្លះ ច្រើនតែភ្លេចសភាពដើម ក្នុងពេលដែលខ្លួនសិក្សាឡើងថ្នាក់ ដោយលើកកំពស់ខ្លួនលុបគុណដែលគេធ្វើដល់ខ្លួនពីពេលមុន ៗ សភាពអ្នកអង្គុយរាយ

www.budinst.gov.kh www.elibraryofcambodia.org

បុកពាកាន់ខ្លួនបេះដូងនោះ   សង្គមជនខ្វះគេមិនបាន

គោរពសរសើរជាជាប់ខាត ។   មិនតែប៉ុណ្ណោះជននោះ

តែងទទួលនូវអំពើតិះដៀល   ពីបរជនក្នុងលោកិយ

ជាចាំបាច់ ។

| | | |
|---|---|---|
| វិគ្រុបាធ្យយេ | អាចឲ្យពណ្ណកាយ | មានរូបស្មី |
| ហើយឲ្យរុងរឿង | អស់បញ្ចិន្ទ្រិយ | ស្មើព្រះជននី |
| | ជនកសោភហោង ។ | |

## ការពន្យល់ពាក្យ

រុងរឿង  គុ. ថ្កុំថ្កើង , ឧត្តុង្គឧត្តម

បញ្ចិន្ទ្រិយ ន. បញ្ច = ៥ + ឥន្ទ្រិយ = ឥន្ទ្រិយ ៥ យ៉ាង

ព្រះជននី  ន. ព្រះមាតានៃក្សត្រគ្រងពង្ស

ព្រះជនក  ន. ព្រះបិតានៃក្សត្រគ្រងពង្ស

ឥន្ទ្រិយ ៥ គឺ : ភ្នែក , ត្រចៀក , ច្រមុះ,

អណ្តាត , កាយ

www.budinst.gov.kh www.elibraryofcambodia.org

## ឧត្តមគតិ

ព្រះជននីនិងព្រះជនក ដែលមានព្រះទ័យសន្ដោស ដល់បុត្រាបុត្រី ដោយព្រះកជធម៌មែមណា គ្រូបាធ្យាយ តែងឲ្យប្រទីប គឺចំណេះវិជ្ជាដ៏ពណ្ណកយ ដល់សិស្ស ទុសិស្សមិនរើសមុខ ដើម្បីឲ្យសិស្សបានរុងរឿងក្នុង នាមនៃការលើកដំកើងស្ត្រីយទាំង ៥ ។

| | |
|---|---|
| ព្រះជនកសោតណា បង្កើតកាត្តា | ឲ្យមានសរីរផង |
| គេក្រពីតូច | មិនឲ្យមានហ្មង អស់សុខទុក្ខផង |
| | តាំងដែលនីធំឆ្អែត ៗ |

## ការពន្យល់ពាក្យ

មានហ្មង ក. កខ្វក់ , កមកតតាស់

សុខ ន. សេចក្ដីសប្បាយ , ដំណើរស្រណុក

ទុក្ខ ន. សេចក្ដីព្រួយ , សេចក្ដីលំបាក

www.budinst.gov.kh www.elibraryofcambodia.org

ទីជំនួន គឺ. ទីជំគ្រប់គ្រាន់ , ទីជំជិនណាយ , ទីជំគ្រាន់

## ឧត្តមគតិ

ធម្មតាមាតាបិតា ទោះបីមានសកាពទន់ខ្សោយបែបណាក៏ដោយ តែងមានព្រហ្មវិហារធម៌ចំពោះបុត្រជានិច្ច ។ សូម្បីតែព្រះវរបិតា នៃព្រះមហាក្សត្រ ក៏មានព្រះទ័យរក្សាបុត្រមិនឲ្យមានហ្នឹងសៅ តាំងពីតូចក្រូចឆ្មារដែរ ហើយការរក្សាថែទាំនេះ ពុំមានការទៀយណាយ ជិនឆ្អន់ឝុំដំណើរការនោះឡើយ ករណីយកិច្ចបិញ្ចឹមបុត្រនេះ ជាធម្មតារបស់មនុស្សលោកគ្រប់វណ្ណៈ ។

| |
|---|
| ព្រះជនកព្រះជននី បើទីជំស្រជី ប្របសើរពេកពន់ ជាគុំព្រះសុមេរុ នោះហោជមហាធ្ងន់ ជាបើទីជំគណន៍ ពុំអាចកន្ទង ។ |

## ការពន្យល់ពាក្យ

ពេកពន់ គឺ. ក្រៃលែងហួសប្រមាណ , ក្រៃហួស

www.budinst.gov.kh www.elibraryofcambodia.org

ព្រះមេរុ ន. ឈ្មោះភ្នំមួយដែលខ្ពស់ជាងភ្នំដទៃ

មហា គុ. ធំ, សម្បើម, ប្រសើរ

គណន៍ ន. ការរាប់, ដំណើររាប់ចំនួន

## ឧត្តមគតិ

គឺបញ្ញា ដែលធំធេងជាងគេ គឺភ្នំព្រះសុមេរុ ចំណែកឯព្រះសាវនាការនៃព្រះជននី និងព្រះជនកវិញ តែងមានឧផារស ត្រៃប្រសើរលើសភ្នំទាំងនោះទៅទៀត ។ ព្រះនុភាពនៃព្រះជនកនិងព្រះជននី តែងដឹកនាំកូនចៅដែលនៅក្រោមការឧបត្ថម្ភ ស្វែងរកអត្ថប្រយោជន៍ សព្វកាលៈទេសៈក្នុងការពង្រឹងឯកភាពដ៏ថ្លៃថ្នូរនៃសង្គមជាតិ ។

| | | |
|---|---|---|
| ត្រៃបាបព្យាយ | ប្រផុតឧប្តម្ភាយ | ផ្តុំគងឯងហោង |
| គាបឲ្យក្តីញ៉ាប់ | ប្រដៅដមិនធង់ | ដោយខ្ជាប់ខ្ជួន |
| | ព្រះពុទ្ធទាំងឡាយ ។ | |

www.budinst.gov.kh www.elibraryofcambodia.org

# ការពន្យល់ពាក្យ

ឯងះហោង ន. មែនពិតហោង

គាបឲ្យ កិ. ធ្វើឲ្យ , ទៅជា . បានជា

ព្រះពុទ្ធ ន. លោកអ្នកត្រាស់ដឹងនូវធម៌កំបាំងមុនគេ

## ឧត្តមគតិ

១- កម្ពុជរដ្ឋ ជារដ្ឋមានពុទ្ធសាសនាជាជន្ទល់ ដោយប្រជាជនខ្មែរស្ទើរតាំងអស់បានគោរពសាសនានេះ ។ ព្រះពុទ្ធពុំមែនជាអាទិទេពទេ ពិតជាអ្នកប្រាជ្ញពិភពលោកបុព្វសម័យ ។

រីឯមាតាបិតាគ្រូបាធ្យាយ តែងនាំសិស្សឲ្យស្ថិតនៅក្នុងគន្លងព្រះពុទ្ធសាសនា ដែលជាសាសនាបង្ហាញនូវមាគ៌ាសន្តិភាព , យុត្តិធម៌ , សមភាព និងការតស៊ូគ្រប់ជំហាន ដើម្បីស្វែងរកប្រយោជន៍ក្នុងបច្ចុប្បន្ន និងបរលោក ។

www.budinst.gov.kh www.elibraryofcambodia.org

ទោះអ្នកណា  ពោះមានប្រាជ្ញា  ឲ្យគិតវែងឆ្ងាយ
គុណនោះទាំងបី  ហៅមហាទូលាយ  កុំឲ្យអន្តរាយ
ក្តីព្យាយាម ។

## ការពន្យល់ពាក្យ

វែងឆ្ងាយ  គុ. វែងសែនវែង , វែងអន្លាយ

គុណ  ន. អំពើល្អដែលគេធ្វើដល់យើង

មហាទូលាយ  គុ. ទូលាយណាស់ណា

ព្យាយាម  ន. ដំណើរខ្មីឃ្មាត , ការប្រឹង

## ឧត្តមគតិ

បងប្រុស - បងស្រី មានគុណលើប្អូនស្រី - ប្រុស មាតាបិតាមានគុណលើបុត្រធីតា គ្រូបាសាស្ត្រាចារ្យ មានគុណលើសិស្សានុសិស្ស ព្រះមហាក្សត្រមានគុណដល់ប្រជារាស្ត្រក្នុងរដ្ឋ ព្រោះអ្នកទាំងនេះ បានជួយដឹកនាំបង្ហាញផ្លូវទៅរកសុភមង្គលគ្រប់ប្រការ ។ តែគុណ

ទាំងនេះពុំទាន់ប្រសើរទេ ព្រោះ បងប្រុស - ស្រី មាតា បិតា សាស្ត្រាចារ្យ ព្រះរាជា មានមេត្តាចិត្តករុណាលើតែក្រុមញាតិរបស់ខ្លួន ប៉ះពោះគុណគឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃទាំងបីនេះ ដឹកនាំមនុស្សជាតិឲ្យបានសមក្នុងពិភពលោកទាំងមូល មិនរើសពណ៌សម្បុរ ទោះបីជាតិសាសន៍ណា ក៏ដូចជាជនជាតិសាសន៍ណាដែរ ។

| |
|---|
| វីបុណ្យនិងបាប អំពើសភាព ទោះពាក់តែងតាម<br>ប្រដូចស្រមោល អន្ទោលតាមប្រាណ ពុំដែលបៀសបាន<br>ត្រង់ក្តីសល់វ៉ល់ ។ |

## ការពន្យល់ពាក្យ

សភាព ន. ដំណើរកើតឯង, ធម្មតា ហេតុ

ស្រមោល ន. ម្លប់ដែលបាំងកំដៅ, ឆាយា

អន្ទោល កិ. ស្ទុះទៅ, រុលទៅ

សល់វ៉ល់ គុ. តប្រមល់ទល់ពុំខ្លា

www.budinst.gov.kh www.elibraryofcambodia.org

# ឧត្តមគតិ

បុណ្យនិងបាប ក្នុងខាងនេះ សំដៅយកអំពើល្អនិងអំពើអាក្រក់ ករណីទាំងពីរនេះ ប្រៀបទៅនឹងស្រមោលអន្ទោលតាមប្រាណរបស់មនុស្ស ។

បុណ្យក្តី បាបក្តី, យុត្តិធម៌ក្តី, អយុត្តិធម៌ក្តី, កុសលក្តី, អកុសលក្តី, សុចរិតក្តី ទុច្ចរិតក្តី ទាំងប្រាំបីក្តីនេះ បើនរណាប្រព្រឹត្តហើយ តែងផ្តល់ផលវិបាកដល់ខ្លួនជាចាំបាច់ដោយគេចពុំរួចឡើយ ។ សិស្សឧស្សាហ៍រៀនសូត្រ ទោះបីមិនទាន់បានទទួលលទ្ធផលក្នុងពេលនេះ ពេលក្រោយគង់តែបានសម្រេចមិនខាន ជៀសមិនរួចទេ ។

| | | |
|---|---|---|
| ឲ្យគិតជញ្ជឹង | ហើយឲ្យពឹង | ប្រាជ្ញាឲ្យយល់ |
| ឲ្យមានវីរិយំ | សន្សំកុសល | កុំធ្វើសល់វល់ |
| | នឹងក្តីទុក្ខសោក ។ | |

ការពន្យល់ពាក្យ

វីរិយំ ន. វីរិយៈ, ការព្យាយាម, សេចក្ដីប្រឹងប្រែង

សច្ចំ គុ. ពិត, ប្រាកដ ទៀងទាត់

ទុក្ខសោក ន. ទុក្ខ + សោក = ការស្រណោះដោយការ

ព្រួយ

## ពាក្យផ្ទុយ ឬ បដិពាក្យ

ប្រាជ្ញា ≠ អប្បប្រាជ្ញា , វីរិយៈ ≠ កោសជ្ជៈ

សច្ចៈ ≠ អសច្ចៈ , សុខ ≠ ទុក្ខ

ឧត្តមគតិ

វីរិយៈនិងសច្ចៈ គោលការទាំងពីរប្រការនេះជាប្រ ការចាំបាច់របស់យុវជន ដែលមានខួរសៅស្អាតស្អំ ៗ លើ ទំព័រជីវិតម្នាក់ៗ កាលបើមានលក្ខណៈព្យាយាម និងការទៀង ត្រង់ហើយ កុំថាឡើយដល់ជីវិតធំធាត់ សូម្បីតែជីវិតទ ខ្សោយបែបណាក៏ដោយ ក៏អនាគតនៃជីវិតនោះស្ថិតនៅ

www.budinst.gov.kh www.elibraryofcambodia.org

លើខឿនឧត្តុង្គឧត្តមក្នុងជើងរុងរឿង    ប្រាសចាកឧបទ្រព
ឧបសគ្គជាតិយោភាព ។

| |
|---|
| ឧស្បកណា    នឹងនាំគ្នា    ឧស្សាហ៍អធ្យាគ<br>ស្វែងធម៌ជាផ្លូវ  ទៅកាន់បរលោក   ចូលមហាបថមោក្ខ<br>គឺនិព្វានហោង ។ |

## ការពន្យល់ពាក្យ

បរលោក    ន.    បរៈ + លោក = លោកដទៃ

មហាបថមោក្ខ    ន.    មហា + បថ = ផ្លូវ + មោក្ខ =
ផ្លូវដ៏ធំសម្រាប់ធ្វើដំណើរទៅរួចចាកទុក្ខទាំងពួង

## សទិសសូរសព្ទ

ថលបថ    ន.    ថល + បថ = ផ្លូវគោក

ព្រះបដ    ន.    ផ្ទាំងបដារូបព្រះពុទ្ធ

ឋានបទ្ម    ន.    ទីទ្រព្រះពុទ្ធរូប

បទ    ន.    បែប, បទបែប  អត្ថបទ

www.budinst.gov.kh    www.elibraryofcambodia.org

បត់ កិ. ពត់, ត្រឡប់ជាផ្នត់, បត់សំពត់,

បត់ជើង, ផ្លូវបត់

ឧត្តមគតិ

នរជនប្រុសស្រី ដែលស្វែងរកធម៌ កាលបើចេះក្បួនច្បាប់ហើយ តែងស្គាល់ច្បាស់ នូវផ្លូវដែលដើរទៅកាន់សេចក្ដីសុខគ្រប់ប្រការ ជាពិសេសគឺព្រះនិព្វាន ដែលជាសុខមិនលាយដោយសេចក្ដីទុក្ខ ក្នុងទំព័រជីវិតគ្រប់ភាគ ។

— ចប់ —

អាប៊ីកំញ៉ាំងត្បូងពេជ្រនៅបរប៉ៃលិន
ជាវណ្ណកម្មប្រលោមលោកពិសេស របស់មិត្ត
សាខុន
ចេញហើយ !!! ចេញហើយ !!!
សូមប្រិយមិត្រ កុំភ្លេចរឿងអាប៊ីកំប៉ាំង ត្បូងពេជ្រនៅបរប៉ៃលិន
សូមអំណរគុណ !!!

www.budinst.gov.kh www.elibraryofcambodia.org

# ច្បាប់កេរ្តិ៍កាល

- កេរ្តិ៍កាលពីព្រេងព្រឹទ្ធ សាងសុចរិតទៀងទុកនៅ
សេដ្ឋីផ្តាំប្រដៅ បុត្រសន្តានទុកក្រោយហោង ។
- កូនអើយកេរ្តិ៍មេបា ចូររក្សាគន់គិតគ្រង
ថែទាំចាំសោរង ប្រុងប្រយ័ត្នប្រយោជន៍យូរ ។
- ធម្មតាអ្នកជាជាតិ កាលគេកាច់ឲ្យគិតគូរ
កុំខ្ជិលដេកចចូរ ដល់ថ្ងៃរះពេញពន្លឺ ។
- គាត់តែងខំកំដរ ចេញទៅរកផ្ទៃស្រែក្លឹ
ចិញ្ចឹមគោក្របី រកខ្សែល្វើចោះក្រោលឃ្នង ។

## ពាក្យបច្ចេកទេស

កេរ្តិ៍កាល ន. វត្ថុដំណាង , វត្ថុដំណែលពីបុរាណ.

សេដ្ឋី ន. អ្នកមានទ្រព្យសម្បត្តិច្រើន

www.budinst.gov.kh www.elibraryofcambodia.org

រួសរាន់ កិរិ. យ៉ាងឆាប់ដោយប្រុងប្រៀប

ប្រយោជន៍ ន. គ្រឿងប្រកប , លទ្ធភាព

កាលគេគាទ៍ ន. កាលគេផ្តួចផ្តើម កាលគេរៀបចំ

ដេកចទូរ កិ. ដេកទ្រមក់ , ដេកដំអក់

វល្លិ៍ ន. រុក្ខជាតិម្យ៉ាងខ្សែតោងលើឈើ

ក្រោលឃ្នង ន. បង្គោលសម្រាប់ឃាំងសត្វពាហនៈ

## ពាក្យផ្ទុយ ឬ បដិពាក្យ

សុចរិត ≠ ទុច្ចរិត , សន្តិសុខ ≠ អសន្តិសុខ

សាមគ្គី ≠ សាមគ្គីភេទ , សន្តិភាព ≠ សង្គ្រាម

## លក្ខណពិសេស

បុព្វបុរសពីព្រេងនាយ តែងសាងអំពើសុចរិត ឯសេដ្ឋីតែងប្រដៅកូនសំឡាញ់ទុកជាខាងក្រោយ ៖

កេរ្តិ៍ដំណែលរបស់មេបា ត្រូវយើងថែរក្សាកុំឲ្យបាត់បង់ ។ យើងមិនត្រូវដេកដល់ថ្ងៃរះបាំងគូថ ទាល់តែក្លូច

www.budinst.gov.kh www.elibraryofcambodia.org

ការងារនោះឡើយ ៗ ត្រូវរៀបចំកម្មករទៅរកធ្វើស្រែភ្ជួរឲ្យទាន់ពេល បើចិញ្ចឹមគោក្របីត្រូវរកខ្សែចងនិងធ្វើក្រោល ៗ

## ឧត្តមគតិ

ក្នុងអត្ថបទខាងលើ អាចទាញមកបញ្ជាក់នូវគោលគតិដូចតទៅ :

- ប្រដៅមនុស្សឲ្យសាងសេចក្ដីសុចរិត
- បញ្ជាក់ពីជំបូន្មាន របស់ពួកនាយខុន
- ឲ្យគេរក្សាទ្រព្យកេរ្តិ៍របស់ដូនតា
- បើគេផ្ដួចផ្ដើម យើងត្រូវជួយជ្រោមជ្រែង
- កុំដេកដំអក់ដល់ថ្ងៃរះ ( អ្នករកស៊ីថ្ងៃ )
- ដឹកនាំកម្មករចេញទៅបំពេញការងារ
- ចិញ្ចឹមគោក្របីត្រូវធ្វើក្រោល ដើម្បីជៀសផុតចោរឈ្មួញ និងកុំឲ្យគោចូលលុកដំណាំអ្នកដទៃ ៗ

X

X X

www.budinst.gov.kh www.elibraryofcambodia.org

ធ្វើស្រែទិសព្រាំបី ខំប្រុសស្រីចេញជួញផង
មើលផ្ទះស្រាស់បេង រាំងចំណារគួរកេរ្យ ៗ
– ឲ្យមានក្ដីបារម្ភ ធ្វើស្រែកុំចោលចម្ការ
ដីផងដែកកាំបិតព្រា ទុកឲ្យជាកុំឲ្យបាត់ ៗ
– ដេកយប់ឲ្យរាំងទ្វារ ទ្រព្យសម្រាលរៀបប្រយ័ត្ន
បងទុកកុំឲ្យសាត ផ្ទះធ្លាក់បែកឆាប់ទប់ទ្រ ៗ
– សារពើទ្រព្យអ្វី ៗ ប្រេងស្លារគ័ទុកឲ្យល្អ
ឧសទឹកស្រូវអង្ករ យកចេញតាមមានកំណត់ៗ
– កុំអាងមានទ្រព្យច្រើន ពុំក្រើនរកផ្គងផ្គត់
យកតាម ៗ ដោយបទ ទោះនឹងទុក ៗ ដោយខ្នាត

ច្បាប់កេរ្តិ៍កាល

## ពាក្យបច្ចេកទេស

ចេញជួញ ក. ចេញទៅជួញ, ចេញជួយ

រាំងចំណារ ក. រាំងចំណារដារបង

ជីនដែក . ន. ជីនចឈើ (ធ្វើពីដែក)

កំផ្ទារ ក. ខ្ទបឬបិទទ្វារ

ទ្រព្យសម្រាល ន. ទ្រព្យដែលអាចជួយរំដោះ

ប្រយ័ត្ន ក. ការពារ , ប្រុងប្រៀប

ទប់ទ្រ ក. ទល់ទ្រ , ទប់ឡើង , ទ្រឡើង

ពុំគ្រវើន ក. មិនស្លុះស្លា

## ទិសប្រាំបី

បូព៌ → អាគ្នេយ៍ → ទក្សិណ → និរតី → បស្ចិម → ពាយ័ព្យ → ឧត្តរ → ឦសាន

## លក្ខណពិសេស

យើងជាអ្នកសិក្សា ត្រូវចេះស្រឡាញ់ស្រែចំការ ។ បើធ្វើស្រែ ត្រូវគុំប្រុសស្រីឲ្យជួយផង ឯផ្ទះស្លាក់អាស្រ័យ ត្រូវយកចំណារមកស្រោសជារបង ។ បើធ្វើស្រែកុំហោលចំការ ពេលឈប់ធ្វើត្រូវរក្សា កាំបិត ចប

www.budinst.gov.kh www.elibraryofcambodia.org

ពូថៅទុកដាក់ដោយកន្លែង ។ បើមានទូកក្តារត្រូវបង់ឲ្យមាំ សម្ភារៈដូចជា ឧស ទឹក ស្រូវអង្ករ ត្រូវវែលតាមខ្សែគិត ប្រមាណកុំអាងតែមានទ្រព្យច្រើន ចេះតែចាយឥតគិត ហើយមិនព្រមរកថែម តែកុំកំណាញ់ហួសមាត្រា ។

## ឧត្តមគតិ

អត្ថន័យនៃអត្ថបទនេះ បញ្ជាក់នូវគោលនិយម សម្រាប់ជាចរិយាវិទ្យា នៃយុវជនដែលប្រកបការងារ នៅពេលដែលខ្លួនបានរួមរស់នៅក្នុងសង្គមគ្រួសារ ឬក្នុងពេលដែលខ្លួនចេញទៅបំពេញមុខងារ ក្នុងដំណែងណាមួយ ត្រូវគោរពតាមគឺ :

- បើធ្វើស្រែត្រូវកុំគិតឆ្ងាយឬជិត ត្រូវធ្វើឲ្យទាន់ពេលវេលា
- ពេលរួចពីរដូវស្រែ ត្រូវបែរមកធ្វើចំការ
- មុនពេលចូលដំណេក ត្រូវបិទទ្វារ

www.budinst.gov.kh www.elibraryofcambodia.org

– សម្ភារៈគ្រប់យ៉ាង ត្រូវទុកឲ្យមានរបៀប

– ស្រូវអង្ករដែលរកបាន កុំលក់រហូតដល់ថ្នាក់ខ្វះ

បរិភោគ ហើយបែរទៅរកទិញពីគេវិញ

– មិនត្រូវទុកផលដំណាំច្រើនហួស រហូតដល់សល់

លក់មិនបានឡើយ

X

X X

– រទេះសេះដើរ កប់ចញ្លីកុំឲ្យឃ្លាត

ខ្ញុំណាមានមារយាទ ទុកដាក់ដៃឲ្យរក្សា ។

– សប្បុរសយល់ដោយមុខ ស៊ុកគ្រលុកពេកពុំផា

កំណាញ់ក្រៅតម្រា សោកសឹងអាប់ប្រយោជន៍យស ។

– រក្សាខ្លួនឲ្យរុង– រឿងឧត្តុង្គឧត្តមខ្ពស់

ប្រដាប់ដោយសក្តិយស ខ្លួនជាធំឲ្យថៃថ្នូន ។

– ឲ្យមានគំនិតចិត្តស្មោះ កុំការឡោះអាល័យស្ងួន

ទ្រព្យនេះទីងនាំខ្លួន ទៅបរលោកពុំសោះសូន្យ ។

www.budinst.gov.kh www.elibraryofcambodia.org

– ទ្រព្យធនទោះថោកថ្លៃ  កុំដាក់ដៃឲ្យតែកូន
ទូវអស់ទាំងបងប្អូន  អ្នកដទៃរក្សាគាង ។
– ទុកចិត្តខ្ញុំមើលដាក់  ស្មើតែអ្នកខ្វាក់ទាំងសង្វាង
ឲ្យកូនគន់មើលគាង  ស្មើតែអ្នកម្ខាងពុំពេញពីរ ។

ច្បាប់កេរ្តិ៍កាល

## ពាក្យបច្ចេកទេស

មារយាទ  ន. អាចារៈ, ឫកពា, សណ្ដាប់ធ្នាប់

សប្បុរស  ន. អ្នកចិត្តល្អ, អ្នកប្រសើរ, អ្នកត្រឹមត្រូវ

ស៊ុកគ្រលុក  កិ.វិ.ឬគុ. ដែលប្រហូកប្រហល់, ខ្ជីខ្ជា

ប្រយោជន៍យស  ន. គុណភាពដែលគេប្រកបបានផលល្អ

ពាន  ន. ស្មារឲ្យ, វត្ថុដែលគេត្រូវឲ្យ

ពុំពេញពីរ  ន. មិនបានពីរ, មានតែម្ខាង

## ពាក្យគួរកត់សំគាល់

+ មារយាទ, មារសត្រូវ, មារជ្រែក, យក្សមារ ។

www.budinst.gov.kh  www.elibraryofcambodia.org

– មាយាស្រី , មមាញឹក , មាគា , មាត្រា , មារយើង , ព្យុះព្យាមា ( មេឃខ្យល់ខ្លាំង ) ។

## លក្ខណពិសេស

ចំពោះវិជ្ជា ដែលយើងរៀនបេះដូង ពេលយើងឈប់សិក្សា យើងត្រូវយកទៅប្រើ តាមលក្ខណៈច្បាប់ យើងត្រូវ ធ្វើបញ្ជីពិសេសនៃគ្រួសារ សម្រាប់កត់ត្រាដែលមាន ទិញការបំណុល ឬបំណាយ ហើយឈ្នួលណាមានគំនិតយើងត្រូវប្រគល់ការឲ្យគេមើលជំនួស ។ ខ្ញុំទីងចិត្តល្អ ឲ្យមើលមុខមនុស្សស្រ័ន ។ បើឲ្យពានកុំឲ្យស្តាយក្រោយ ទើបបានផល កុំទុកទ្រព្យធនទាំងអស់លើដៃកូននោះ គឺត្រូវចែកបងប្អូនកូនក្មួយផង ។ បើយើងមានខ្ញុំកំដរ មិនត្រូវទុកចិត្តទាំងអស់ទេ ឯកូនក៏យើងមិនត្រូវទុកចិត្តពេកដែរ គឺយើងត្រូវតាមដានពិនិត្យផងទើបល្អ ។

www.budinst.gov.kh www.elibraryofcambodia.org

# ទុក្ខមកពី

ដោយយល់ឃើញថា : ចលនាជីវិតច្រើនតែស្ថិតនៅលើធនាគារ មិនគ្រប់លក្ខណៈគឺ ម្ចាស់ច្រើនតែមើលងាយខ្ញុំកំដរ ឯខ្ញុំកំដរមិនសូវយកចិត្តទុកដាក់ នឹងទ្រព្យធនរបស់នាយខៅហ្វាយ ។ មនុស្សខ្លះចិត្តល្អជ្រុលគន្លាក់ តែខ្លះកំណាញ់ខុសគន្លឹះ ហើយខ្លះក៏ស្រឡាញ់ខុសសៃវៀន ។ ដូចនេះ ច្បាប់ខាងលើត្រូវបានអត្ថន័យ :

— ខ្ញុំកំដរ យើងត្រូវទុកចិត្តខ្លះដែរ បើគេមានចិត្តស្មោះត្រង់ ។

— មុននឹងធ្វើចិត្តល្អនឹងនរណាត្រូវពិនិត្យជាមុនសិន ។

— កុំធ្វើចិត្តកំណាញ់ ហួសដល់លែងស្គាល់បងប្អូនមិត្តភក្តិខ្សត់ក្រជាមួយគ្នា កន្លងពេលមុន ។

— កុំឲ្យបែកទ្រព្យកេរ្តិ៍ឲ្យទៅកូនអស់លើងពីខ្លួន មុនពេលស្លាប់ ។

www.budinst.gov.kh www.elibraryofcambodia.org

— កុំទុកចិត្តខ្ញុំកំដរ ដោយប្រគល់សោរឲ្យកាន់

— កុំទុកចិត្តកូនឲ្យមើលកេរ្តិ៍មតិក

X

X X

| | | |
|---|---|---|
| — | ធ្វើអ្វីធ្វើឲ្យហើយ | កុំទុកឡើយបង្កើតកេរ្តិ៍ |
| | សំអាតអស់សរិល | កុំឲ្យមានកក្តិន្ទាៗ |
| — | ដំណេកដេកជាខ្នាត | ឲ្យសំអាតសំអាងផា |
| | ទើបទេពតារក្សា | បម្រើនសុខស្រីសួស្តី ៗ |
| — | គ្រឹហាឲ្យផ្ចិតផ្ចង់ | កុំឲ្យផង់ផុយធូលី |
| | ជម្រះបារបោសដី | ឲ្យម៉ត់ហ្មង់កើតសុខា ៗ |
| — | អញ្ចាលទុកឲ្យគង់ | ប្រាក់កង់ថង់ទុកឲ្យផា |
| | ប្រើខ្ញុំមើលមុខក់ | ទោះគាប់ជាមើលឲ្យស្តែង ៗ |
| — | សារពើរួសរៀនរ៉ះ | ឲ្យចាំបេះ ៗ ចារបែង |
| | ចង់គាប់ប្រើសួះស្វែង | រករៀនរ៉ះសារពើក្តី ៗ |

ច្បាប់កេរ្តិ៍កាល

www.budinst.gov.kh www.elibraryofcambodia.org

## ពាក្យបច្ចេកទេស

បង្កើតកេរ្តិ៍ : បង្កើតដំណែលចាស់

អស់សរិល ន. សព្វសពាង្គកាយ

ក្តីនិន្ទា ន. ការរិះគន់, កិច្ចឈ្នានីស

ស្រីសួស្តី ន. សិរីសួស្តី, មង្គល

គ្រឹហា ន. ញកភ្នំ, ប្រាសាទថ្ម

ស្វែរៀនរិះ កិ. ប្រញាប់រៀនគិតគន់,

ចារចែង កិ. សរសេរចងក្រងឡើង

សារពើក្តី ន. ប្រាប់សព្វយ៉ាង

## ពាក្យគួរគិត

គ្រឹហា + គ្រឹះស្ថាន + វឌ្ឍស្ថាន + ប្រតិស្ថាន +

គុហា + ព្រះវិហារ + ព្រហ្មវិហារធម៌

## លក្ខណពិសេស

លក្ខណៈនៃច្បាប់កេរ្តិ៍កាល បានបញ្ជាក់នូវភស្តុតាង

www.budinst.gov.kh www.elibraryofcambodia.org

នៃរបបរស់នៅគឺៈ បើធ្វើការអ្វី ៗ ត្រូវធ្វើឲ្យហើយ កុំទុកឲ្យសល់ នាំឲ្យធ្លាប់ខ្លួន ឯសរីរៈយើងត្រូវសំអាតជានិច្ច កុំឲ្យក្លិនម្ហឹះៗ ដល់អ្នកនៅជិតខាង ។

ទីដេកពួន យើងត្រូវបោសសំអាត ជាអចិន្ត្រៃយ៍ ទើបមានសេរីសួស្ដី ។

បើយើងរស់នៅ ហើយចេះបោសសំអាតគេហដ្ឋាន ប្រកបដោយអនាម័យនោះ សុខភាព តែងកើតមាន ដល់យើងជាពុំខាន ។ ប្រាក់កាសត្រូវទុកឲ្យគង់ បើសិនជាប្រើអ្នកនៅក្រោមបង្គាប់ ឲ្យមើលមុខគេសិន ។

យើងជាអ្នកសិក្សា ត្រូវចេះសរសេរកត់ត្រាទុក នូវវិជ្ជាដែលខ្លួនបានសិក្សា ហើយយើងត្រូវស្វះស្វែងរៀនក្បួនច្បាប់ដទៃទៀត ទើបគាប់ប្រសើរជាមនុស្សពេញលក្ខណៈ ។

www.budinst.gov.kh www.elibraryofcambodia.org

## ឧត្តមគតិ

ដោយយល់ច្បាស់ថា: ការរស់នៅនៃជនភាគខ្លះ មិនសូវគិតដល់បញ្ហាអនាម័យលើទំព័រជីវិត, ចាយវាយប្រាក់កាស តាមចិត្តចង់, រំលោភដល់ខ្ញុំកំដរ, ខ្ជិលប្រអូសមិនព្រមរៀនក្បួនច្បាប់ ដោយន័យនេះ ទើបបុត្របុរសយើង ឆ្លៀតឱកាសទូន្មានដូចតទៅ :

— ត្រូវតស៊ូ ឲ្យសម្រេចកិច្ចការដែលកំពុងប្រព្រឹត្ត

— ត្រូវរក្សាច្បាប់អនាម័យជានិច្ច

— ត្រូវទុកប្រាក់សំចៃ ការពារពេលគ្រោះថ្នាក់

— ត្រូវទុកសិទ្ធិសេរីភាពដល់ខ្ញុំបំរើ

— ត្រូវសិក្សាវិជ្ជាក្បួនច្បាប់គ្រប់វ័យ លុះត្រាតែស្លាប់

— សប្បុរសពេកចាញ់ធម ឆាតុជំនួចាញ់ឥន្ទ្រីយ
ប្រពន្ធល្អច្រើនចាញ់ប្ដី ពាក្យច្រើនក្ដួតចាញ់គាថា ។
— ឈើផ្លែច្រើនចាញ់ស្លឹក ត្រីច្រើនទឹកល្អក់ពុំថា

www.budinst.gov.kh www.elibraryofcambodia.org

ទ្រព្យច្រើនព្រួយរក្សា  ទ្រព្យតិចណាព្រួយរិះគិត ។
ដេកយប់កុំតំអក  ឲ្យលង់លក់ក្រៅសុបិត
ខ្ញុំណាមានគំនិត  គួរឲ្យគិតប្រណីត ។
– ចង់ទូកបោះបង្គោល  រិះរកថ្នោលគួរឃ្មេថា
ការខ្យល់កាចពុំជា  ក្រែងពានពារបោកបែកបាក់ ។
រៀនរិះសារពើក្ដី  ពោ[illegible]សដីកាន់ពាក្យសត្យ
ចាំក្បួនចាំឲ្យស្ទាត់  កុំអៀនប្រៀនសមពាក្យពោល ។

ច្បាប់កេរ្ដិ៍កាល

## ពាក្យបច្ចេកទេស

ចាញ់ធន  អស់ធន , ហិនសម្បត្តិ

ចុះដីន  ន. ផងអាក្រក់ . ផងទុច្ចរិត

អាត្មា  ន. អត្ត: , ខ្លួនប្រាណ

ល្អក់ពុំជា  គុ. ល្អក់ខ្វល់ , ល្អក់មើលមិនយល់

ដំអក់  កិ. ទំនេរ , រៃរ៉ៃ អអង់ , ដំកៀក


www.budinst.gov.kh www.elibraryofcambodia.org

គិតប្រណី    កិ. គិតប្រោសប្រាណ , គិតសន្តោស

ថ្កោល    ន. ឈើម្យ៉ាងសម្រាប់ដោលទូក

ពាក្យស័ត្យ    ន. ពាក្យពិត , វាចាទៀងត្រង់

## ពាក្យផ្ទុយ

ជន ≠ ទុជ្ជន , យស ≠ ទុយ្យស

សុភាសិត ≠ ទុព្ភាសិត, ពលភាព ≠ ទុព្វលភាព

បញ្ញា ≠ ទុប្បញ្ញា , សុទិដ្ឋិ ≠ ទុទិដ្ឋិ

ភិក្ស ≠ ទុព្ភិក្ស , សុជីព ≠ ទុជ្ជីព

## លក្ខណពិសេស

អ្នកចិត្តល្អច្រើនអស់ទ្រព្យ    ជនអាក្រក់តែងអាប់អន់ រូបលក្ខណៈទង់លក្ខណចរិយា    ប្រពន្ធគ្រប់លក្ខណ៍តែង ឈ្នះស្វាមី    ឯពាក្យមិនពិតតែងចាញ់ខ្លួន ៗ ឈើដែល ផ្លែច្រើន    មិនសូវមានស្លឹកទេ    ត្រពាំងដែលមានត្រី

ទឹកក៏មិនឆ្ងាយបានថា ទ្រព្យច្រើនពេកក៏ពិបាកថែទាំ ឯអ្នកខ្សត់ទ្រព្យតែងមានការព្រួយបារម្ភជានិច្ច ។ ដេកយប់ឲ្យប្រយ័ត្ន ឈ្មលណាលួចត្រូវបេះសន្ធោសក់ ។ ចង់ទូកឲ្យបោះបង្គោលឬបោះយុថ្កា កុំចងនឹងស្មៅក្រែងដាច់សាត់បាត់ ។

បើជាអ្នកសិក្សា ត្រូវស្ដីនិយាយតែពាក្យសច្ចៈ ហើយរៀនឲ្យចាំក្បួនច្បាប់ពិតប្រាកដ កុំឲ្យធ្លាក់ខ្លួនទៅក្នុងករណីថា រៀនបំបង់បាយ ។

ឥន្ទ្រី ៦ យ៉ាង : ភ្នែក, ត្រចៀក, ច្រមុះ, អណ្ដាត, កាយ និងចិត្ត ។

ឧត្ដមគតិ

ដោយឆ្លុះឃើញថា ពេលសុជីវធម៌និងខ្លួនមនុស្សគង់ឃ្លាតពីគ្នាខ្លាំងពេក ទើបវីរបុរសខ្មែរ បានឲ្យដំបូន្មានទុកជាទ្រឹស្ដីសង្ខេបដូចតទៅ ៖

www.budinst.gov.kh www.elibraryofcambodia.org

– បើចិត្តល្អ គោរពិនិត្យសិន

– ជនទុច្ចរិត សមនឹងទទួលគ្រោះថ្នាក់ជីវិត

– ប្តីអាក់អន់ មកពីស្រីមិនប៉ុនប្រសប់

– ល្បែងកុហក់មិនត្រូវសោក ប្រយ័ត្នអន់ខ្លួន

– ឈើផ្លែមិនសូវមានស្លឹក ( អ្នកចេះមិនសូវអួត )

– រណ្តៅមានត្រីច្រើន ទឹកតែងល្អក់ខ្វល់ (គ្រួសារមាន

គ្នាច្រើនតែងមានជម្លោះច្រើនជាធម្មតា)

– អ្នកមានទឹកដូចអ្នកក្រដែរ គឺសុទ្ធតែពិបាកទាំងអស់

( ច្បាប់មនុស្សលោក )

– គោលគេងប្រយ័ត្នក្រែងឥតក្រោក

– ពួកនាយទុនត្រូវចេះអនុគ្រោះ ដល់កម្មករផង

– បង្ខំកូនត្រូវបោះបង្គោល (សិស្សរៀនត្រូវមានសម្ភារៈ

សម្រាប់សិក្សា )

– អ្នករៀនសូត្រ មិនត្រូវមើលងាយអ្នកល្ងង់ទេ

www.budinst.gov.kh www.elibraryofcambodia.org

– មុននឹងធ្វើអ្វី អ្នកបេះត្រូវតែគាន់គ្បួន ។

X

X X

| | |
|---|---|
| ការក្រកុំគិតឆ្ងាយ | ការសម្លាយដាកក្រោល |
| សទ្រឹមកុំបំពោល | ក្រែងពុំដល់ដូចប្រាថ្នា ។ |
| – រៀនរិះរួសរាន់ | ធ្វើស្រែប្រាំងស្រែវស្សា |
| ធ្វើស្រែមានបំណារ | ធ្វើការចាររបង ។ |
| – ផ្លូវវៀចកុំបោះបង់ | ផ្លូវណាត្រង់កុំដើរហោង |
| ដើរដោយផ្លូវគន្លង | គម្រាយអ្នកចាស់បុរាណ ។ |
| – ផ្លែផ្កាឲ្យប្រុយឆី | ដេកនៅដីចាំឆមឆាន |
| គ្រឿងសឹកទុកទាហាន | កើតគម្ពីរទុកប្រាជ្ញប្រាយ ។ |
| – យល់តូចកុំកាលខ្ញុំ | ពោះយល់ធំកុំអាលស្រាយ |
| គិតក្តីកុំគិតឆ្ងាយ | មើលពិនិត្យពិនិស្ស័យ ។ |
| | ច្បាប់កេរ្តិ៍កាល |

www.budinst.gov.kh www.elibraryofcambodia.org

## ពាក្យបច្ចេកទេស

ការសម្ងាយ ន. ការគំរាមបន្ទាប់បន្សំ , ការកេងយករង

ចំណារ ន. វត្ថុដែលគេហារ , របឹប

ហាររបឹប ក. ចាប់របឹប , ស្រាស់របឹប

កុំប៉ាបង់ ក. កុំបង្អាក់លះបង់

ផ្លូវគន្លង ន. ផ្លូវដែលគេត្រាយទុកមកហើយ

ធនធាន ន. ទ្រព្យសម្បត្តិ

កេរ្តិ៍គម្ពីរ ន. ដំណែលក្បួនច្បាប់

ពិនិត្យពិច័យ ក. ពិនិត្យដោយផ្ចិតផ្ចង់

## ពាក្យចងចាំ

ពិនិត្យពិច័យ + ពិនិច្ឆ័យ + វិនិច្ឆ័យ + បច្ច័យ

បៃឆិន្ស + បៃខាំ + ជ្លងបៃ

## លក្ខណពិសេស

ក្ដី ១ ដែលគ្រ ឃើនកុំគិតទៅជាឆាយ សូម្បីតែកា

www.budinst.gov.kh www.elibraryofcambodia.org

ភយរង គឺអាចក្លាយទៅជាពិបាកបានដែរ ដោះបើកិច្ច ធ្ងន់បែបណា បើយើងព្យាយាមគន់តែសម្រេច តែយើងកុំធ្វើដោយធ្ងនធាង ក្រែងត្រេងត្រាងដេកផ្លូវ ។

— ស្រែស្រាក្តីស្រែប្រាំងក្តី ចំការក្តី យើងត្រូវធ្វើចំណារ ឬ របង កុំឲ្យសត្វពាហនៈលុកលុយ ។ ផ្លូវត្រង់តែប្រកបដោយគ្រោះថ្នាក់ យើងត្រូវដើរតាមផ្លូវវៀចវិញ គន់តែដល់ទីដៅដូចគ្នា ។

— បើស្រុកកើតចោរ ត្រូវចិញ្ចឹមឆ្កែ ព្រោះវាជួយចាំធនធាន បើរើសបានគ្រឿងសឹក ត្រូវប្រគល់ឲ្យរាជការ ចំណីអាហារអ្នកប្រាជ្ញ គឺក្បួនគម្ពីរ ។ បើឃើញតូចកុំអាលមើលងាយ តែបើឃើញធំ ត្រូវស្ទង់សិន កុំអាលលោភក្រែងគ្រោះថ្នាក់ ។

## សទិសសូរស័ព្ទ ឬ សទិសស័ព្ទ

ចា : បរចា , រាចា , ចាប៉ី . ចាប៉ុក ,

www.budinst.gov.kh www.elibraryofcambodia.org

ចារ : ចារសាស្ត្រ , ចាររបង , ដែកចារ, ផ្កាចារ

ចារ្យ : អាចារ្យ , សាស្ត្រាចារ្យ , ព្រឹទ្ធាចារ្យ

ចារណ៍ : មូលវិចារណ៍ ( ការពិចារណារកហេតុដើម )

ចារ៉ : បំពង់ឡតតូច ៗ, ពាក់ចារ៉ុ , ចារ៉ុមាស

## ឧត្តមគតិ

ដោយយល់ឃើញថា : ជនមួយចំនួននៃកុលសម្ពន្ធបុត្រសម័យ ច្រើនតែមិនចេះអប់រំចិត្ត បណ្ដោយឲ្យមានចិត្តរំលោភលើកិច្ចការ ៗ មិនតែប៉ុណ្ណោះ បានបណ្ដោយឲ្យចិត្តស្ថិតនៅលើគោលការកេរ្តិ៍និយមទៀតផង ទើបលោកអ្នកប្រាជ្ញតែងប្រដៅបញ្ញាជនដូចតទៅ ៖

— កុំបីមើលងាយកិច្ចការ ទោះបីការនោះតូចក៏ដោយ

— កុំបីធ្វើការហួសសមត្ថភាពដែលខ្លួនមាន

— កុំបណ្ដោយខ្លួនឲ្យទំនេរ ហើយដកដង្ហើមចោលឥតប្រយោជន៍

www.budinst.gov.kh www.elibraryofcambodia.org

– ត្រូវមានមធ្យោបាយដោះខ្លួនក្នុងគ្រាកុន (ផ្លូវវៀចកុំបោះបង់ . . .)

– មនុស្សគាបទុកជារបង (ក្តែជាឲ្យបាយដី . . .)

– ត្រូវស្គាល់ករណីរបស់ខ្លួន ទាហានរក្សាគ្រឿងសឹក អ្នកប្រាជ្ញតែងរក្សាក្បួនគម្ពីរជានិច្ច

– ត្រូវពិនិត្យសិនមុននឹងប្រឡោតខឹង

X

X X

– កូនអើយកើតមេបា ចូររក្សាចាំសព្វថ្ងៃ
ទ្រព្យធនទោះថោកថ្លៃ គួររក្សាកុំបំផ្លាយ ។
– ពាក្យនេះជាគ្រូកាល ជាខ្លឹមសារទៀងទុកឲ្យ
កូនចៅនៅឯក្រោយ តែងខ្លួនានអង្គអាត្មា ។
– ចង់ចាំទើបគង់ទ្រព្យ រៀបរណ្តាប់ទុកទើបជា
ចាយវាយក្រៅតម្រា សឹងវិនាសធនធានផង ។
– បានមកទុកឲ្យគង់ កុំឲ្យបង់បាត់បំណាន

| | |
|---|---|
| រៀនរិះរកក្រគន់ | យកចេញហាយដោយផ្លូវៗ |
| – ដឹងបាបឲ្យដឹងតុល | ក្អែកឲ្យយល់ទៀងត្រាជូ |
| គិតគ្រប់សព្វដោយផ្លូវ | ក្តិបខ្ទោះកុំបីមាន ៗ |
| – ពាក្យនេះស្មើខ្លួនហើយ | កូនចៅអើយចូរចាំប្រាណ |
| អស់អាថ៌ទុកទទាន | ជាសូរចបណ្តាំហោង ៗ |
| | បញ្ចប់កេរ្តិ៍កាល · |

## ពាក្យប្រែកាទេស

កេរ្តិ៍មេបា ន. កេរ្តិ៍ពីដូនតា, ដំណែលជាប់បុរាណ

កុំបីភ្លោយ គុ. កុំបីឃ្លាត, កុំឲ្យភ្លាះភ្លោយ

ត្រកាល់ គ. ទើបប្រែថ្មី, ទើបមានមកថ្មី

រៀបរណ្តាប់ កិ. រៀបជាលំដាប់លំដោយ

ក្រៅតម្រា ន. ក្រៅក្បួន, ក្រៅច្បាប់មនុស្ស

តុល ន. ជញ្ជីង, គ្រឿងថ្លឹង

ត្រាជូ ន. ជញ្ជីង, តម្លឹង ក្អែកជញ្ជីង

www.budinst.gov.kh www.elibraryofcambodia.org

អាចិទុកទាន ន. ការឲ្យដំបូន្មានដ៏មានសារប្រយោជន៍

# លក្ខណពិសេស

កេរ្តិ៍មត៌កមាតាបិតា កាលគាត់ចែកឲ្យដល់កូន ទោះបីតិចតួចក៏ដោយ យើងត្រូវរក្សាទុកឲ្យគង់ បើមិនបានរកបន្ថែមទេ ។ ច្បាប់កេរ្តិ៍កាលនេះ ជាច្បាប់រស់នៅថ្មីជានិច្ច ក្នុងការប្រើប្រាស់រូបកាយប្រុសស្រី ។ ការចាយវាយឥតប្រយោជន៍ ចំពោះល្បែងបៀគឺ ស្រី, ស្រា, បៀ-អាប៉ោង, កូនក្រមុំ... តែងវិនាសធនធាន រកអង្ករប្រកឆ្នាំង មិនបានជាមិនខាន ។ ត្រូវចាយក្នុងលក្ខណៈណាដែលចាំបាច់ . . . ។ យើងជាមនុស្សត្រូវចេះមើលខ្លួនជញ្ជីង កុំឲ្យគេកោរបំបិតខ្លួនតាំងស្រស់ ។ ច្បាប់ដែលបានពោលយ៉ាងហូរហែមកនេះ ជាទ្រឹស្តីសម្រាប់អប់រំយុវជន ឲ្យប្រតិបត្តិលំបាកក្នុងទំនើរដំណើរ ។

www.budinst.gov.kh www.elibraryofcambodia.org

បញ្ចកកុធភណ្ឌ = ទ្រព្យ សម្រាប់រាជ្យ

៥ យ៉ាង :

១– សុពណ៌បាទុក ២– មកុដ ៣– ព្រះខ័ន

៤– ស្វេតច្ឆត្រ ៥– វាលវីជនី = ផ្លិតកន្ទុយសត្វ

ឧត្តមគតិ

– ត្រូវថែរក្សាមត៌កពីដូនតា

– ត្រូវលះបង់ល្បែងអកុសល

– ត្រូវបំណាយធនធានក្នុងករណីចាំបាច់.

– ត្រូវប្រយ័ត្នការបន្លំក្លែកជញ្ជីង តែបន្លំក្លែកស្រស់

– ច្បាប់ល្អ នាំមនុស្សឲ្យបានសុខមង្គល កាលបើ ប្រព្រឹត្តតាម ។

www.budinst.gov.kh www.elibraryofcambodia.org

# ច្បាប់អរិយសត្ថា

អរិយសត្ថា គន់គិតបារមែង ចងទុកជាច្បាប់
ឲ្យកូនសិស្សផង គ្រប់គ្រាប់សណ្ដាប់ យកជាតម្រាប់
តម្រង់អាត្មា ។

ឲ្យមានប្រយោជន៍ ប្រយ័ត្នអសោចិ៍ កល់រូបអ្នកណា
អម្បាលមករៀន រៀនសាស្ត្រា ប្រយ័ត្នអាត្មា
ការកេរ្តិ៍លោកិយ ។

ទោះខឹងចេញទៅ ប្រយោជន៍នានៅ ផ្តាប់ផ្គុំមន្ត្រី
ឲ្យគ្រូនឹងច្បាប់ សណ្ដាប់សួស្តី ដូចលោកស្រដី
ប្រដៅទុកមក ។

www.budinst.gov.kh www.elibraryofcambodia.org

បើមិនចង់ទេ ចង់នៅទំនេរ ជួញប្រែរះរក
ចិញ្ចឹមជីវិត គួរគិតរៀនយក របៀននោះមក
ទើបរកទ្រព្យបាន ។

ច្បាប់អរិយសត្ថា

## ពាក្យចងចាំ

អរិយសត្ថា ន. នាមបញ្ញត្តិរបស់កវីនិពន្ធ

សិស្ស ន. អ្នកសិក្សា, ជនដែលរៀនវិជ្ជាពីគ្រូ

អម្បាល និ. ទាំងប៉ុន្មាន, អម្បាលម៉ាន, បើសិនជា

សាស្ត្រា ន. ក្បួនច្បាប់, គម្ពីរ, រឿងរ៉ាវដែលចារលើស្លឹករឹត

មន្ត្រី ន. នាម៉ឺន, ជនមានគំនិតដឹងកក់ក្តៅ

ជួញប្រែ កិ. លក់ចេញទិញចូល, លក់ដូរ

របៀន ន. សិល្បសាស្ត្រ, មន្តវិជ្ជាការ, ចំណេះវិជ្ជា

www.budinst.gov.kh www.elibraryofcambodia.org

## ពាក្យផ្ទុយ ឬ បដិពាក្យ

### អាត្មា ≠ អនាត្មា, អត្ម័ន ≠ អនត្ម័ន, អត្តា ≠ អនត្តា, សោភា ≠ អសោបិ

### កំណិតរៀបចំ

ដើម្បីជាច្បាប់សម្រាប់សិស្សទូទៅ ទើបអ្នកនិពន្ធ អរិយសត្តា បង្ក្រងជាច្បាប់ ដែលមានន័យដូចតទៅ :

នរជនគ្រប់រូប គង់រក្សាកេរ្តិ៍ឈ្មោះរបស់ខ្លួន កុំឲ្យមាននិន្ទអសោច៍ បើអ្នករៀន ត្រូវចេះចាំច្បាប់ឲ្យមែនទែន ប្រយ័ត្នក្លាយទៅជាថ្នាំពិស ព្រោះចេះក្បួនមិនស្ទាត់ ៗ

បើយើងចេះស្ទាត់ ទោះទៅទីណា ក៏គាប់ជល់អ្នកប្រាជ្ញជានិច្ច ៗ បើយើងចេះក្បួនច្បាប់ ហើយយើងមិនធ្វើកផការ បែរជាធ្វើអ្នកជំនួញវិញ ទ្រព្យធនក៏ហូរចូលជានិច្ចនិរន្តរដែរ ៗ

www.budinst.gov.kh www.elibraryofcambodia.org

# ឧត្តមគតិ

— ស្មារតីជឿនលឿន ខានផ្លូវច្បាប់នាអតីតសម័យ

— ចង់កិត្យាកេរ្តិ៍ឈ្មោះ ទ្រព្យធន បុណ្យស័ក្តិ

— លើកដំកើង អ្នកចេះដឹង (អ្នកប្រាជ្ញ)

— ស្គាល់តម្លៃវិជ្ជា ទុកជាអង្គសមទិធិ

— ចង់ឲ្យកូនខ្មែរ ចាប់ចិត្តនឹងពាណិជ្ជកម្ម

កាយលេខគាត់ក្បាច់ សង់ផ្សំសម្រេច ឲ្យបានជំនាន
ដឹងដើមដឹងចុង ដឹងចង់ដឹងបាន ដឹងគិតប្រមាណ
គត់ត្រាបញ្ជី ។
ឲ្យបានប្រយោជន៍ ប្រយ័ត្នអសោច៍ ជាអ្នកគេស៊ី
សម្រាប់លោកិយ ប្រក្រតីជាទី សំគាល់បញ្ជី
សៀវគ្រាសៀវភៅ ។
គន់គិតប្រយ័ត្ន អស់ទ្រព្យសម្បត្តិ ឲ្យស្អាត់ដោយខ្ទូរ

www.budinst.gov.kh www.elibraryofcambodia.org

រាយលេខពាត់ក្បាច់ ឲ្យស្រេចឃើញផ្លូវ សឹមថយ
ចេញទៅ តាមផ្លូវលោកិយ ៗ
ល្បងដឹងតិចច្រើន ល្បងដឹងក្រវើន ទ្រព្យធនរ៉ូ ៗ
លេខនិងអក្សរ កំដរស្មារតី សម្រាប់លោកិយ
នោះឯងទើបត្រូវ ៗ
បើតែវិលវេះ ខ្វិលដេកស្រមេះ ស្រមូញស្ញូញស្ញូវ
សពាងលើខ្នើយ កន្ត្រើយលក់ទៅ នរណាទឹមនៅ
ដាស់តឿនឲ្យទៀត ៗ

ច្បាប់អរិយសត្ថា

## ពាក្យត្រូវចងចាំ

ប្រក្រតី ន. ធម្មតា, សាមញ្ញ, ដូចដែលចំណាំ

សៀន ន. អ្នកកត់ត្រា, លេខាធិការ

អក្សរ ន. ស្នាមគំនូសដែលសម្រាប់បញ្ជាក់ភាសា

ស្មារតី ន. ការភ្ញាក់រលឹក, ការនឹកឃើញ

www.budinst.gov.kh www.elibraryofcambodia.org

វិលវេះ   ក. ត្រឡប់គេចកៀស,   គេចបាត់ ស្រមូញស្មូញស្មូរ គ. ស្មុញស្មាញ, សុយមម៉ុយ, អៀរមៀរ

## គំនិតរៀបចំ

ក្នុងការប្រកបមុខការ ទោះបីក្នុងនាទីណា ក៏ដូចជានាទីណាដែរ ជាចាំបាច់ គឺយើងត្រូវចេះគិតគូរកត់ត្រា បញ្ជាក់លេខបូកប៉ាន់ឲ្យត្រឹមត្រូវ ដើម្បីឲ្យបានដឹងខាតចំណេញ ៗ គិតយ៉ាងណា ឲ្យបានចំណេញ កុំឲ្យខាតលិចលង់អស់សោប៍កេរ្តិ៍ឈ្មោះ ព្រោះតែខ្លួនមិនបានពិនិត្យបញ្ជីស្មៀន ៗ ត្រូវគិតគន់ ត្រាលេខលក់ចេញទិញចូល ឲ្យដឹងចំណេញសិន សឹមយើងចេញទៅផ្សញ ប្ដលក់ដូរ ៗ ក្នុងការស្វែងរកទ្រព្យធន ការចេះលេខនិងអក្សរ ជាខឿនសម្រាប់ជួយដល់ស្មារតីកត់សំគាល់ក្នុងលោកិយ ៗ បើយើងកើតជាមនុស្ស ហើយយើងបង្កើនគំនិតខ្ជិលច្រអូស សុយមម៉ុយ ដេកទ្រមក់គំកេក់ចែស

មិនគិតប្រកបការងារ តើឲ្យនរណាជួយធ្វើវិញ ។

ឧត្តមគតិ

– បង្ហាញតម្លៃនៃគណិតវិទ្យា ចំពោះពួកពាណិជ្ជករ

–បង្ហាញរបរជំនួញ មិនសុទ្ធតែចំណេញទាំងអស់ទេ បើធាយពាណិជ្ជ មិនស្ទាត់ខាងបញ្ជី (គែស) ។

– បង្ហាញចិត្តសាស្ត្រ: គិតមុនគូរ (មុនលក់ចេញ ឬទិញចូល ត្រូវគិតខាតចំណេញសិន)

–បង្ហាញ តម្លៃនៃការចេះលេខនិងអក្សរ ចំពោះការស្វែងរកទ្រព្យសម្បត្តិ

- បង្ហាញ ស្នាដៃតីកំពុករបស់ជនខ្ជិលផុប

| |
|---|
| មិនដឹងឬគ្មី ក្នុងរាជ្យលោកិយ រកការបង្កៀត<br>នរណាទុកឯង លេងកយដៃព្រាត ឃើញហើយគេបៀត<br>ជម្រៀតរកការ ។ |

www.budinst.gov.kh www.elibraryofcambodia.org

ហេតុនោះគួរគិត គួរកាន់គំនិត គួរគិតឧស្សាហ៍
សង្វាតរករៀន រៀនសាស្ត្រា តម្រិះប្រាជ្ញា
បង្ការទុកទៅ ។

ទើបដោះខ្លួនរួច រាប់ជាអ្នកស្រួច ដឹងគិតរាក់ជ្រៅ
ក្នុងពភ្យលោកិយ សេចក្តីឥឡូវ គិតឲ្យឃើញផ្លូវ
ឆឹងទៅមុខទៀត ។

ទីត្រង់ឯងទៅ គេថយចេញទៅ រកស៊ីបង្អៀត
គិតគួរម្តេចម្តា ប្រាប់បែររៀត ពឹងអ្នកកន្ទៀត
ដូចខ្លួនកាលណា ។

ហេតុតែខ្លួនឯង បេះគិតបាត់បែង ឲ្យគ្រប់ប្រការ
តាំងលេខតាំងក្បាច់ ស្រេចនូវអាត្មា ឯងឲ្យអស់ការ
គិតគួរសព្វកាយ ។

អរីយសត្ថា

## ពាក្យគួរចងចាំ

រាជ្យលោកិយ ន. រាជ្យ + លោកិយ = រាជ្យបច្ចុប្បន្ន

ជម្រៀតរាជការ ៗ ន. ពន្ធ ដែលរាជការបង្គាប់ឲ្យបរទេស បង់ ( ឡាំងកាយ )

អ្នកកន្ទៀត ន. អ្នកដទៃ , បរជន

សព្វសាយ កិរិ. គ្រប់ទិសទី , គ្រប់មុខទាំងអស់

រាជការ ន. កិច្ចការផែនដី ដែលមានក្សត្រសោយរាជ្យ , រាជការខ្មែរ

រដ្ឋការ ន. កិច្ចការផែនដី ដែលឥតមានស្ដេចសោយរាជ្យ , រដ្ឋការបារាំង

## រាជ + រាជ្យ

រាជ ន. ក្សត្រ, ស្ដេច, មហារាជ, អធិរាជ, សេនាកុត្តរាជ, ៗ នៅខាងដើម: រាជទ្រព្យ, រាជ-ភ័ស្តុ, រាជពាហន, រាជសម្បត្តិ, រាជធម៌ . . ៗ

www.budinst.gov.kh www.elibraryofcambodia.org

រាជ្យ ន. ភាពនៃខ្លួនជាក្សត្រ, សោយរាជ្យ, គ្រងរាជ្យ, ទ្រព្យរាជ្យ, សម្បត្តិរាជ្យ, បល្ល័ង្ករាជ្យ...។

## គំនិតរៀបចំ

បច្ចុប្បន្នសម័យនៃច្បាប់ ដោយស្រុកបង្កៀតបង្អល់ខ្លាំង កាលណាយើង ធ្វើឲ្យហួសច្បាប់មុខតែត្រូវមានការពិន័យ ជាមិនខាន ។ គួរតែយើង រៀនក្បួនច្បាប់ទុកក្នុងខ្លួនគ្រប់ៗគ្នា ដើម្បីការពារអត្តនូ ។ កាលបើមានឧបសគ្គមកដល់ គួរតែយើងចេះដោះខ្លួន ឲ្យរួចពីគ្រោះនោះ គេចាត់ទុកជាមនុស្សមុះមុត ។ បើខ្លួនល្ងង់ទៅហើយ យើងពឹងអ្នកដទៃ មិនដូចជាខ្លួនពឹងខ្លួនឡើយ ។ កិច្ចការអ្វី ។ គោងពិនិត្យដោយខ្លួនឯង យ៉ាងជាក់ច្បាស់សិនមុននឹងធ្វើ (បើយើងចេះ) ។

## ឧត្តមគតិ

— បញ្ហាបំបិទសិទ្ធិរាស្ត្រ នៃអ្នករាជការខ្លះ ( បុរាណសម័យ)

www.budinst.gov.kh www.elibraryofcambodia.org

– បញ្ហាកស្រ្តមិនសូវគិតផលច្បាប់ផ្ត

– បញ្ហាដោះខ្លួនឲ្យផុតពីគ្រោះថ្នាក់

– បញ្ហាមនុស្សល្ងង់ = ខ្វាក់ចាំងសន្ធាន

– បញ្ហានិទំពារជីវិត ( វិភារណញ្ញាណ )

+++++++++

ទើបបានគេកោត គេមានចំណោទ គេកោតព្រាជ្ញប្រាយ
គេយល់ឯងវេះ ចំណេះលែបខាយ ពុំហាងក្លែងក្លាយ
បំបាត់បានឡើយ ៗ

ទីត្រង់អ្នកខ្លៅ ផ្តេកផ្តិតចិត្តទៅ យកគេជាត្រើយ
កាលម្តងគេត្រង់ គង់ចិត្តនៅឡើយ ផលពីរដងហើយ
គេប្រែប្រាញ់ ៗ

គេគិតចាយចាត់ រាយលេខបំភ្លាត់ បំផ្លាញអាត្មា
ចំណេញទៅគេ ទទេអសារ ខ្លួនឯងឥតការ
ខាតទុនក្រខ្លួន ៗ

នេះឯងក្មេងហើយ កុំប្រហែសឡើយ រៀនទុកជាខ្លួន

ទាំងលេខទាំងក្បាច់ ឲ្យស្រេចនៅខ្លួន អក្សរឲ្យស្ទួន
ទាន់ខ្លួននៅក្មេង ៗ

តែចាស់បន្តិច វិញ្ញាណភ្លាំងភ្លេច គំនិតប្រែផ្សេង
គិតការច្រើនមុខ កើតទុក្ខកន្ទេង ប្រាប់អស់ក្មេង ៗ
ឲ្យដឹងឲ្យហើយ ។

អរិយសត្ថា

## ពាក្យគួរឲ្យចងចាំ

បំណោទ ន. ការចោទសួរ

លែបខាយ គុ. ដែលមើតប្រាយ, ប្រាកដប្រជា

អ្នកខ្លៅ ន. អ្នកល្ងង់ អ្នកដែលមិនប៉ិនប្រសប់

អសារ ន. ឥតខ្លឹមសារ, ឥតប្រយោជន៍

ឲ្យស្ទួន គុ. ឲ្យសមល្មម, ឲ្យគ្រប់គ្រាន់

វិញ្ញាណ ន. ធម្មជាតដឹងច្បាស់, ការដឹង

កន្ទេង គុ. ស្រងាកចិត្ត, សង្រេងចិន្តា

www.budinst.gov.kh www.elibraryofcambodia.org

## គំនិតរៀបចំ

ផនដៃ តែងកោតសរសើរអ្នកចេះគិតគូរ, កាលបើគេមានការឆ្ងល់ តែងសួរយើងអ្នករៀន ដែលមានចំណេះពិតប្រាកដឥតក្លាយ ។ អ្នកល្ងង់ពឹងគេបានតែម្តងប៉ុណ្ណោះ អុញផល់ឡើងពីរដង គេក៏ប្រែចិត្តបែបសោះអង្គើយទៅវិញ ។ អ្នកមិនចេះលេខអក្សរ ជាទ្វារចំហបើកឱកាសឲ្យផនដៃតែបន្ទំតាមចិត្តទឹកឃើញគ្រប់កាលៈទេសៈ ។

ក្នុងខណៈដែលខ្លួនយើងនៅយៅវ៌ ត្រូវតែខំរៀនឲ្យសព្វវិជ្ជា កុំគួរគេប្បីប្រហែសធ្វេសឡើយ ។ កុំចាំខ្លួនចាស់ វិញ្ញាណគាំង ពាំងគំនិត គិតមិនយល់ ឆ្ងល់មិនដែង រង្វើងដោយមុខការរយពាន់ ដេកចាំតែដល់ថ្ងៃអន្ទ្រាចេប បែរកេរិ៍ឈ្លានោះ ។

## ឧត្តមគតិ

— បង្ហាញបង្គមវិទ្យានិយម (ចូលចិត្តអ្នកប្រាជ្ញ)

www.budinst.gov.kh www.elibraryofcambodia.org

– បញ្ហាសង្គមបញ្ញើក្អែកនិយម (ផ្ញើកសនាដោយសារគេ)

– បញ្ហាសង្គមវិបត្តិទំនាស់និយម ( អ្នកបេះ ÷ អ្នកលួង )

– បញ្ហាសង្គមអប់រំយុវជនតាមរបមសិក្សានិយម

– បញ្ហាសង្គម អនក្ខរជននិយម ( ចាស់ជ្រុល )

កុំអាងម៉ែឪ សម្បត្តិដែលនៅ មានច្រើននោះឡើយ
ក្រែងឥតទីពឹងម៉ែ ឪងាប់ទៅហើយ ខ្លួនទៅឆោតល្ងើយ
ងងឹតល្ងង់មោហា ៗ

ក្រែងអស់ទាំងទ្រព្យ នោះក៏មិនខ្ជាប់ នៅនឹងអាត្មា
ខ្លួនឯងឆោតនៅ កំឡៅមោហា មិនចេះរក្សា
មិនបានគង់ទេ ៗ

ខ្ចបខាតមិនខាន គំនិតមិនបាន ប្រហែលខ្ញុំគេ
គេវាយគេធាក់ គេប្រើគេជេរ មិនឲ្យទំនេរ
ខ្មាស់គេពិបអ្វី ៗ

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទេប្រះគួរគិត　គួរឃើញគំនិត　គួរគិតសេចក្ដី
ជាមនុស្សដូចគេ　គួរតែឃ្លាតខ្លី　រំពឹកស្មារតី
ស្រឡាញ់រៀន ។
កុំគិតខ្ជិលពេក　កុំគិតពួនដេក　កុំគិតវេះវៀន
កុំគិតមានពុត　រមត់គិចគៀន　កុំគិតអៀនប្រៀន
វេះវៀនចិត្តកាច ។

អរិយសត្ថា

## ពាក្យគួរចងចាំ

ឆោតងើយ　គុ. ឆោតងើយ , ឆោតល្ងង់ , ឆោតល្ងើយ

ឆោតឆៅ　គុ. ដែលឆោតហើយឆៅគំនិត

មិនខ្ជាប់　គុ. មិនមាំមួន , មិនតាំងនៅ

ខូចខាត　គុ. ដែលបាត់បង់ , ដែលសូន្យទៅ

ឃ្លាតខ្លី　គុ. ស្រក់ស្រទេញ , ដែលស្មុះស្មា

ពួនដេក　កិ. លាក់ខ្លួនសម្ងំដេក

www.budinst.gov.kh　www.elibraryofcambodia.org

រេះរៀន  គឺ. រេះតួនក្រៀន , គេបចេញបាត់

## គំនិតរៀបចំ

គប្បីយើងកុំអាងមាតាបិតាមានទ្រព្យច្រើន ហើយយើងខ្ជិលមិនខំស្វែងរកវិជ្ជានោះ ក្រែងគាត់អនិច្ចកម្មទៅ យើងគ្មានជំរះអ្នកផងខ្លួន ។ កាលបើយើងគ្មានចំណេះវិជ្ជា មុខជាធ្លាក់ក្នុងរណ្តៅមនុស្សល្ងង់ ហើយមត៌កទាំងនោះ ត្រូវវិនាសជាអសារបង់ ។ កាលបើយើងមិនចេះច្បាប់ លុះយើអ៊ុនផាក់ អាគ្រេះជាន់ មុខជាត្រូវធ្លាក់ខ្លួនក្នុងទាសភាពមិនខាន ហើយរមែងត្រូវទទួលនូវទារុណកម្មយ៉ាងអាមាស់ ។ ចំណាំងដើងនេះ យើងជាអ្នកសិក្សាគួរតែភ្ញាក់ខ្លួន ហើយហក់ចូលក្នុងសៃរៀន ជាអ្នកបន្តវិជ្ជាសព្វយ៉ាង ។ មិនត្រូវធ្វើចិត្តកើតកើជ ខ្ជិលច្រអូសគេចរេះគៀសអាគ្មាដោយបុកពាអ្នួទទ្ធខាំងមិលស៊ុមឹងឡើយ ។

www.budinst.gov.kh www.elibraryofcambodia.org

## ឧត្តមគតិ

– ប្រដៅមនុស្សឲ្យស្គាល់ច្បាស់ នូវតម្លៃបំណេះវិជ្ជា ប្រសើរជាងទ្រព្យសម្បត្តិធម្មតា

– ប្រដៅមនុស្សឲ្យចេះរក្សាទ្រព្យធន កាលបើមានវិជ្ជាចេះដឹងហើយ

– ប្រដៅ មនុស្សឲ្យស្គាល់ ការធ្វើទុក្ខបុកម្នេញពីអ្នកមានទ្រព្យទៅលើអ្នកក្រ

– ប្រដៅមនុស្សឲ្យចេះរកស៊ីខ្លួនឯងដោយប្រាជ្ញា

– ប្រដៅមនុស្សឲ្យតាំងនៅលើការព្យាយាម ខ្មីឃ្មាតក្នុងកាតព្វកិច្ចសព្វបែប

+++++++++++

ឲ្យរៀនចិត្តល្អ ដឹងធម៌អក្សរ គួរគិតកោតខ្លាច
ការកើតប្រយ័ត្ន គួរកាត់ពាលកាច គួរឲ្យខ្លួនខ្លាច
កុំឲ្យគ្រូទាយ ។
ពាក្យគ្រូធ្ងន់ណាស់ ដំនៀលដល់ចាស់ ពីព្រេងមុនឆាយ

ឯគ្រង់ពាក្យម្ដាយ ទំនាយគ្រូទាយ នេះឯងមិនងាយ

អាក្រក់ណាស់ណា ៗ

ឲ្យប្រុងប្រយ័ត្ន បម្រើប្រណិប័តន៍ កាត់ចិត្តស្នេហា

កុំឲ្យអន់អាក់ ថ្នាំងថ្នាក់ចិន្តា គ្រូទាយហើយណា

ឆ្កុតឆាប់ណាស់ហោង ៗ

ឲ្យដឹងបាបបុណ្យ ស្គាល់ទោសនិងគុណ ជាទុនទៅមុខ

គុណគ្រូបាធ្យាយ គុណម្ដាយឪពុក រៀមច្បងទំនុក

ឲ្យសុខអនុកូល ។

គ្រូមួយផងគ្នា រួមរក្សចិត្តជា ស្នេហាមិត្រមូល

កុំនាំអុជហេតុ បំបែកចេញចូល កាចកិនគ្រកូល

បង្កើតមាត់ក ៗ

ព្យាច់អរិយសត្ថា

ពាក្យត្រូវចង់ចាំ -

ផិមអក្សរ ន. ផិម = ផម្ភៈ + អក្សរ > អក្ខរៈ = អក្សរ

និងច្បាប់

www.budinst.gov.kh www.elibraryofcambodia.org

ដំនៀល ន. ពាក្យតិះដៀល, ពាក្យដៀល

ចំនាយ ន. ការចាយ, សេចក្ដីដែលគេចាយ

ស្នេហា ន. សេចក្ដីស្រឡាញ់, ដែលជាទីស្រឡាញ់

ឋាំងឋាក់ចិន្ដា ន. គ្រួណាក់ចិត្ត, ការទើសទាក់ចិត្ត

អនុកូល គុ. ដែលទំនុកបំរុង ដែលពេញចិត្ត. ន. ករុណា

រូមរក្ស គិ. រួមស្រឡាញ់, រួមរក្សា

កាចកិន គុ. ដែលមានចិត្តសាហាវខុសបទ

## កិច្ចការរៀបចំ

ម្នាក់ៗត្រូវមានសន្ដានចិត្តល្អ ត្រូវចេះច្បាប់និងអក្សរសាស្ត្រ ត្រូវគ្រាក្ដីឈ្មោះ ត្រូវលះបង់អំពើកាចឃោរឃៅ ដើម្បីជៀសកង់ចំនាយគ្រូ ។ គ្រូនិងម្ដាយតែងមានគំនិតជាសំតែងពិនិត្យឃើញលក្ខណចរិយារបស់សិស្សគណឬកូនចៅ យ៉ាងច្បាស់លាស់ ខណៈណាដែលអ្នកទាំងនោះចាយចុកហើយ អនាគតរមែងស្ថិតនៅមិនឆ្ងាយពី

www.budinst.gov.kh www.elibraryofcambodia.org

សភាពកក់ចានោះឡើយ ។ យុវសិស្ស ត្រូវយកចិត្តទុកដាក់ចំពោះដំបូន្មានគ្រូ កាលបើករណីនេះគ្មានក្នុងសាលា ចំនាយមាត្រារបស់គ្រូ មុខតែមានប្រសិទ្ធិភាពជាប្រាកដ ។ យើងជាមនុស្ស ត្រូវស្គាល់បុណ្យបាប ទោសគុណចំពោះគ្រូបាធ្យាយ មាតាបិតា និងរៀមច្បងដែលទំនុកបំរុងយើងពីដើម ។ យើងជាអ្នកសិក្សា រួមសាស្ត្រាចារ្យជាមួយគ្នា គួរគប្បីមានគត្តីភាពទៅវិញទៅមក កុំនាំអុជអាលចាក់រុក ឲ្យបែកបាកសាមគ្គី បង្កើតជាអធិករណ៍ឲ្យសោះ ។

## ឧត្តមគតិ

បំភ្លឺ ចិត្តត្រាប្រណីនៃអ្នកចេះដឹង និងឥទ្ធិពលចំនាយ

បំភ្លឺ លទ្ធផលបណ្ដាំម្ដាយ ចំនាយគ្រូក្តិការពិត

បំភ្លឺ លក្ខណចិត្តរបស់សិស្សទៅលើគ្រូ ក្នុងបុព្វសម័យ

បំភ្លឺ គុណភាពរបស់គ្រូ, ម្ដាយនិងរៀមច្បង

បំភ្លឺ បញ្ហាសំដីញុះញង់ ជាគន្លងបំបែកសាមគ្គីភាព

www.budinst.gov.kh www.elibraryofcambodia.org

កុំធ្វើមាក់ងាយ ទិទ៍គ្រូបាធ្យាយ រៀនចិត្តឲ្យល្អ

ទោះអ្នកឯណា ណែផ្លូវអក្សរ អ្នកនោះឯងអរ

ឲ្យចិត្តមេត្រី ។

កុំឲ្យសៅហ្មង លើលោកកន្លង ពោលពាក្យស្រដី

រឹងរូសទ្រគោះ ឈ្លាសឈ្លោះសេចក្តី កើតទោសអប្រិយ

ជេរពោលប្រមាថ ។

អ្នកនោះស្មើគ្រូ បង្កើតអភិរូប៍ គុណគេទុកទ

គេជួយប្រដៅ គេហៅឧបាគ ដាស់តឿនសង្វាត

ឲ្យឯងចេះឆាប់ ។

បើឯងចេះហើយ កុំភ្លេចគុណឡើយ ឲ្យដឹងដោយច្បាប់

គួរគិតកោតខ្លាច ដើរតាមសណ្តាប់ គន្លងធម៌ច្បាប់

កុំឲ្យមាក់ងាយ ។

នេះឯងគន្លង ត្រឹមត្រូវទំនង អំពីព្រេងនាយ

www.budinst.gov.kh www.elibraryofcambodia.org

> ឯកំផ្សឥឡូវ ច្រើនតែមាក់ងាយ ចេះហើយជេរម្តាយ
> ប្រមាថគ្រូវិញ ។
> អរិយសត្តា

## ពាក្យគួរចងចាំ

ណែផ្លូវ កិ. ពន្យល់ផ្លូវ , ឲ្យទំនងផ្លូវ

ឈ្លាសឈ្លោះ គុ. ដែលប៉ិនប្រសប់ខាងឈ្លោះ

អប្រិយ គុ. ដែលមិនជាទីស្រឡាញ់, អាក្រក់

ទុរ៉ង កិ. សង្វាតជាអចិន្ត្រៃយ៍ , សប្តី

សណ្តាប់ ន. បែបបទ , ទំនៀម , របប

រាជ្យ ន. ភាពនៃខ្លួនជាស្តេច , សម័យនៃក្សត្រ
សោយរាជ្យ

## គំនិតរៀបចំ

យើងមិនត្រូវប្រមាថគ្រូបាធ្យាយទេ គឺត្រូវធ្វើចិត្តឲ្យល្អ បើយើងគោរពក្រែងអ្នកដទៃ គេក៏មានគំណារ

គុណដោយមេត្រីមិនខាន ។ យើងមិនត្រូវប្រើសំដីទ្រគោះ បោះបោកលើអ្នកដែលមានគុណដល់ខ្លួនឡើយ បើយើង ប្រព្រឹត្តបែបនេះទោសអប្រិយផុសឡើងដល់ខ្លួនជាចាំបាច់ ។ ព្រោះអ្នកទាំងនោះ គេចាត់ស្មើនឹងគ្រូក្នុងការបង្ហាញផ្លូវទៅ រកវឌ្ឍនភាពគ្រប់វិស័យរស់នៅ ។ អុញ ខណៈដែលយើង ចេះដឹងប្រឡងជាប់សញ្ញាប័ត្រតាមបំណងហើយ យើង មិនត្រូវបំភ្លេចឧបការគុណរបស់អ្នកដទៃ ដែលបង្ហាញផ្លូវ ច្បាប់ឡើយ ។ ដោយយល់ឃើញថា សម័យបច្ចុប្បន្ន ប្រភេទជនខ្លះ កាលមិនទាន់ចេះដឹង ធ្វើបែបគ្រូន ៗ កាលបើចេះរើប ៗ ហើយ បែរជាប្រមាថគ្រូវិញ ។

## ឧត្តមគតិ

លក្ខណៈនៃការរស់នៅក្នុងសង្គមមនុស្ស ច្បាប់ខាង លើបានបង្អុលនូវគោលដៅដូចតទៅ ៖

— បើយើងចិត្តល្អ ស្លូតបូតចំពោះជនណា អ្នកផ្សេងតែង

www.budinst.gov.kh www.elibraryofcambodia.org

ផ្តល់នូវករណីស្មើគ្នាចំពោះយើងវិញ

— ជនអាក្រក់តែងទទួលទារុណកម្មតាមមាត្រា

— ជនណាដែលគ្រាន់តែបង្ហាញគំនិតល្អ សូម្បីបន្តិច ក៏ចាត់ជាគ្រូបានដែរ

— ត្រូវដឹងឧបការគុណចំពោះអ្នកដែលបានធ្វើគុណ ដល់យើងជាប្រត្យក្ស

—លក្ខណៈសិស្សចេះគួរសមក្នុងបុរាណសម័យ និង លក្ខណៈសិស្សលុបគុណគ្រូ ក្នុងអាណានិគមសម័យ

++++++++++++

ហេតុដូច្នេះឯង លោកិយយល់ស្មើ តែងឃើញម្តេចមិញ
ហិនហោចសូន្យសុង លិចលង់ទៅវិញ ទោសនោះឯងមិញ
កើតពីឯណា ៗ
កើតពីចិត្តឯង បង្កើតស្ទុះស្ទែង បំផ្លាញអាត្មា
ពេលពលក្នុងពោះ ឆេះក្នុងឧរ បង្កើតទោសា
ឲ្យទុក្ខរបឯង ៗ

បេះតែបន្តិច លើកខ្លួនកំប៉ិច ដំប៉ោងឥតក្រែង
តែងឃើញរៀងមក យ៉ាងដូច្នេះឯង ម្ល៉ោះហើយក៏តែង
ខុសទឹងទេពតា ៗ

រឺចិត្តអកល្អ ដឹងធម៌អក្សរ បេះពិចារណា
ស្គាល់គុណនិងទោស សន្តោសអាត្មា អត់ធុនចិន្តា
ពុំដែលសៅហ្មង ៗ

អ្នកនោះឯងនៃ លោកសឹងប្រពៃ សួស្តីកន្ទង
បរលោកិយ ឥតបើសៅហ្មង តាំងទេព្តាផង
ចំរើនឲ្យសុខ ៗ

អរិយសត្ថា

## ពាក្យគួរចងចាំ

សូន្យសុង ន. សូន្យគ្មានពន្លឺសោះ , ទទេផង

ស្វះស្វែង ន. ការនាំឲ្យកើតទោស , សត្រូវ

ធុក ន, ទ្រូង

www.budinst.gov.kh www.elibraryofcambodia.org

ទោសា ន. កំហឹង , ការប្រទូសរ៉ាយ , គំហុស

កំប៉ុច គុ. ដែលទំលើកណាស់តែមិនខ្ពស់

ទេពតា ន. អជនដែលជាទិព្វ , ជនដែលសប្បាយ
ដោយកាមគុណ

សន្តោស ន. មិនរាតរាទិ , មិនរើមរាម . ការឧបត្ថម្ភ

ឥតបរិហ្មងសៅ ន. ឥតប្រឡាក់ប្រឡូស , គ្មានហ្មងសៅ

## គំនិតរៀបចំ

បច្ចុប្បន្ននៃជនអ្នកប្រមាថពាក្យបណ្តាំបុរាណ តែងជួបប្រទះទីងឹកអន្តរាយ សូម្បីសុងលង់កេរ្តិ៍ឈ្មោះដោយខ្លួនឯង ៗ អំពើមិនគប្បីយើងប្រព្រឹត្ត ក៏តែងកើតវិប្បដិសារី នេះពេលក្នុងទ្រូងសព្វទិនទិវាតែខ្លួនឯង ៗ ជនមួយចំនួនទៀត មានការចេះដឹងបន្តិចបន្តួចហើយគ្មានប្រាកដប្រជា តែចំលើកអំណួត ក៏យកពាហួសវិស័យ ជននោះឯងតែងត្រូវទទួលពាក្យនិន្ទាពីអ្នកប្រាជ្ញមិនខាន ។

www.budinst.gov.kh www.elibraryofcambodia.org

រីឯជនដែលមានចិត្តល្អ ដឹងច្បាប់សុជីវធម៌ ចេះពិចារណា ស្គាល់គុណទោស ចេះសន្ដោសអត់ធ្មត់ដោយគន្លងច្បាប់ ៗ នរជននោះ តែងបានប្រកបដោយសុខភាពយ៉ាងសួស្ដីក្នុងនាលោកិយ ដោយមានការគាំទ្រពីអ្នកផងទាំងពួងគ្រប់គ្នា ៗ

ឧត្តមគតិ

គោលគំនិតខាងលើ អាចដៅនូវចំណុចគតិដូចតទៅ

— ជនដែលប្រព្រឹត្តអំពើទុច្ចរិត គឺជនអាក្រក់តែងហុចផលឲ្យខាន់ហាន់

— ជនទុច្ចរិត តែងមានវិប្បដិសារីក្នុងចិត្តជានិច្ចបន្ទាប់ពីពេលដែលខ្លួនប្រារព្ធអំពើលាមករួច ៗ

— ការលើកកំពស់អត្តអាទិ៍នៃជនពាល (បុកណសម័យ)

— ការស្គាល់គុណទោសនិងចិត្តធម៌ នៃអ្នកប្រាជ្ញ

www.budinst.gov.kh www.elibraryofcambodia.org

## — ការលើកដំកើង នៃជនមានមនុស្សធម៌

+++++++++++

ដពបរៀនទៅ សុខពីឥឡូវ រៀនទៅឯមុខ
ចៀសចាកប្រាសប្រាណ ពីស្ថាននរក រៀនរួចបានសុខ
ដល់សួគ៌ាល័យ ។

អរិយសត្តា គន់គិតចែងការ ចែងចងសេចក្ដី
តម្រង់តម្រាប់ ជាច្បាប់យ៉ាន់ថ្មី ដាស់តឿនស្រដី
សិស្សសព្វប្រការ ។

គ្រូគិតគេរៀន កិច្ចការរៀន របបសាស្ត្រា
តាមច្បាប់និទាន ខ្ទួនគាថា រៀនកល់រូបា
សូមរៀបចប់ហោង ។

ច្បាប់អរិយសត្តា

### ពាក្យគួរចងចាំ

ចៀសចាក កិ. ចេញផុត , ថយចេញផុត

ប្រាសប្រាណ កិ. ឃ្លាតពីខ្លួន , និរាសចេញពីប្រាណ

សួគ៌ាល័យ ន. សួគ៌ + អាល័យ = លំនៅនៃសួគ៌

ថែងបង កិ. សរសេរបងគ្រង

សព្វប្រការ ន. គ្រប់ផាន់ថ្នាក់ , គ្រប់ប្រភេទ

ផាសតៀនស្រដី កិ. ក្រើនរំលឹកដោយពាក្យ

## សទិសសព្ទ ឬ សទិសូរសព្ទ

## ប្រាស + ប្រាស់ + ប្រះ

ប្រាស កិ. ឃ្លាតចេញ , ព្រាត់ចេញ ,។ ន. ព្រាត់

ប្រាស ប្រាសចាក , ប្រាសនិរាស

ប្រាស់ ឋរ. ប្រើប្រាស់ , ភោគប្រាស់

ប្រះ កិ. ផ្ដេកខ្លួន , ខ. ប្រះខ្លួន = ប្រះប្រាណ។ — គុ

សក់ប៉ប្រះស្មា , ថ្ងៃប៉ប្រះមាត់ព្រឹកព្រា ។ — កិ.វិ

ថែវប៉ប្រះទឹក ។

## កំណត់រៀបចំ

ការធ្វើល្អ នៃជនអ្នកយល់គុណ - ទោស តែងបាន



www.budinst.gov.kh www.elibraryofcambodia.org

ទទួលខ្សែសេចក្ដីសុខមិនត្រឹមបច្ចុប្បន្ននេះទេ សូម្បីក្នុងអនាគតកាល ក៏នឹងគឺតែមានប្រសិទ្ធិភាពទៅទៀត ៗ ដោយយល់យ៉ាងច្បាស់លាស់ នូវសភាពការណ៍ក្ដីច្បាប់ល្អបរិសុទ្ធនេះ ទើបព្រះអរិយសត្ថាចារ្យបែងទុកឲ្យបច្ឆាជន ធ្វើជាស្ពានសម្រាប់បម្លងខ្សែជីវិត ទៅរកសុភមង្គលគ្រប់ប្រការ ៗ សម័យនេះ យើងជាសិស្សគួរគប្បីខំប្រឹងរិះរៀនសព្វគ្រប់ច្បាប់ ទោះបីច្បាប់ផ្សេង ៗ ក៏ដូចជាច្បាប់បណ្ដាំនិងភាសិតដែរ ដើម្បីទូន្មានរូបកាយគ្រប់ ៗ គ្នា ។

## ឧត្ដមគតិ

- លទ្ធផលរបស់ជនមានឧត្ដមគតិ ( គោរពការងារ)
- គោលគំនិតកក្ដីភាពផ្លូវច្បាប់របស់អ្នកនិពន្ធ
- ករណីចាំបាច់របស់មនុស្សជាដំបូង គឺការសិក្សា

+++++++++++++

— ចប់ —

www.budinst.gov.kh www.elibraryofcambodia.org

# បញ្ចពិធកល្យាណី

## លំអរបស់ស្ត្រី ៥ យ៉ាង

**Les Cinq points d'appat de jeune fille**

១– កេសកល្យាណី : លំអសក់ , សក់វែងមិនបាច់អ៊ុត ដូចគេអ៊ុតពីកំណើត

(La Beauté de la chevelure)

២– អដ្ឋិកល្យាណី : លំអឆ្អឹង , ធ្មេញត្រឹមដូចគេតម្រឹម

(La Beauté des dents en forme)

៣– មំសកល្យាណី : លំអសាច់ , ពពីរមាត់ក្រហមដូចផ្លែព្រាសទុំ

(La Beauté des lèvres en nature)

៤– ឆវិកល្យាណី : លំអស្បែក , សម្បុរសឬខ្មៅ តែស្អាតឥតមានអាចម៍រុយដើរដុះ

(La Beauté du touche)

៥– វយកល្យាណី : លំអវ័យ , អាយុ ៥០ ឆ្នាំក៏ដូចជាអាយុ ១៥ ឆ្នាំដែរ (តាំសាច់)

(La Beauté Eternelle)

www.budinst.gov.kh www.elibraryofcambodia.org

# ១០០ ពាក្យបណ្ដៅ

១) ខែរះធ្នូផ្សារ កូនកើតមុនឪ ពតាដើរលេង ។

( សម្ដេចព្រះឧបយុវរាជទ្រង់ : សោយរាជ្យក្នុងវង្ស -> សោយរាជ្យ មុនព្រះវរបិតា -> តាមតាឯករាជ្យ )

២) ប្រទេសក្នុងពិភពលោក វដ្ដមានគរគោក តើវដ្ដណា

កណ្ដាលគេ ។

( វដ្ដអព្យាក្រឹត )

៣) ស៊ីពីមាត់ជុះពីមាត់ នរណាក្លាត់ប្រឡាក់ព្រុះណា ។

( ស៊ីឡូ )

៤) ឯកអគ្គនាមាត្រា ទ្រង់កន្សា ជិតជាមជាគួ ។

( ខ្មៅដៃ )

www.budinst.gov.kh www.elibraryofcambodia.org

៥) ឯកអង្គទ្រង់នាមគង្គា បង្ហាញឫទ្ធិគ្រប់គ្នា

បានដល់អ្នកផង ។

( ទឹកខ្មៅ )

៦– នាងនួនពិសី នាងល្អឥតបី បង់គ្រេកគ្រអាល

ពេលបានឃើញភ្លាម ចិត្តាស្រើបស្រាល ចំណី

ខួរក្បាល ហៅនាងអក្ខរូប៍ ។

( សៀវភៅមើល )

៧– ឯកអង្គទ្រង់នាមព្រឹត្តិប័ត្រ ហត្ថាខ្វែងខ្វាត់ បក្សក្រឡង់ ។

( សៀវភៅសរសេរ )

៨ ឯកអើយអ្នកឯក ខ្លួនធំអនេក តែទាបជាងស្មៅ ។

( ផែនដី )

៩– ខ្សែមួយចន្លាយ កាយគ្រប់ស្រុក ។

( ផ្លូវ )

១០– ត្រប៉ាក់ ៗ អើយ នាងនៅឲ្យសុខ អាស់ស្តោកបង

www.budinst.gov.kh www.elibraryofcambodia.org

រនទុក្ខ ទុកបុះទុកឡើង ៗ

( នាឡិកាប៉ោល )

១១-ស្រីស្រស់ល្អមានទ្រង់ គេបោលបោះបង់ គេបង់កអួស

( លាន់ដាក់អន្ទង់ )

១២- ដករណ្តៅ សល់បង្គោល ៗ

(ដកចិញ្ចៀនពីម្រាមដៃ)

១៣ - អង្គុយលើក្តំ យំផ្អប ៗ ដូចកង្កែបហៀរទឹកមាត់ ៗ

( បាយពុះលើជើងក្រាន )

១៤- ក់យកគង់លេងសមុទ្រ សែនខ្លាចយកទៅដុត

កណ្តាលកោះលង្កា ៗ

( អាំងត្រី )

១៥- ខាងត្បូងភ្លើង ខាងជើងកោះ កណ្តាលគោក

សោះ មានទឹកខាង ១ ៗ

( នំពាក់ខ្នុល )

១៦ កាច់កគេជួរមុខឯង ស្លៀកសំពត់ឯង លេបគូថគេ ៗ

www.budinst.gov.kh www.elibraryofcambodia.org

(ពោយនំបញ្ចុក)

១៧– មុខធំគូថស្ទិត ស្រី ១ ចូលចិត្ត យកដាក់ក្រោមភ្លៀក

(ឈ្នាន់អុំកំពិស)

១៨– មេលួនកូនកាយ ទៅមិនឆ្ងាយ គេហៅអ៊ី ៗ

(ទូកអុំ)

១៩– ឯកអគ្គនាមកក្កុសន្ធោ នាពេលទឹកជោរ ងើបឡើងស្រែកច្រៀង ៗ

(មាន់រងាវ)

២០– ឈើវៀចដាក់លើឈើវេ វេវង់ ១ ពត់ខ្លួន ១ ៗ

(វេអំបោះ)

២១– ឯកអគ្គទ្រង់នាមពិសាល៍ មាន់រងាវកាលណា ឡើងជិះស្រី ១ ៗ

(ចង្អេរអុំអង្ករ)

២២–ជិះខ្នងកាន់ស្នែង ដើងជាក់ខ្វាក់ខ្វេង ក្រឡាប់ផែនដី ៗ

www.budinst.gov.kh www.elibraryofcambodia.org

(ឆាក់កន់)

២៣– ជិះខ្នងកាន់ស្នែង ដោមចេញសុទ្ធផ្សែង ខ្ចាយ

ព្រះធរណី ។

(ជិះមូតូ)

២៤– គេះផ្ទឹមជំនឹងឯង ថ្ងួនចេញរងំ ។

(តាប៉ី)

២៥– ឃ្លោកមិនឃ្លោក ល្ពៅមិនល្ពៅ នៅលើក្រភ្លៅព្ន

សូររងំ ។

(ទ្រ ប្ច ស្គរ)

២៦– ទៅហោះមកហែល មនុស្សមិនដែល រកមិនឃើញ ។

(សន្ទូចប្របក់)

២៧– ម្រឹគមិនស៊ីម្រឹគា តែនព័ទ្ធលើគ្នា ផ្ទៃស៊ីមុតមាត់ ។

(ផ្លែសន្ទូច)

២៨– ដាក់ទ្រូលើបុនប្ចុស្សី មិនត្រូវត្រីអី ត្រូវនាងកប្ចង់ ។

www.budinst.gov.kh www.elibraryofcambodia.org

(គោមបង្ហោះ)

២៩– កែះគេវិលឯង វិលវិញតែខ្លួន បេញព្រះពោះម្តាយ ។

(កង្ហារអគ្គិសនី)

៣០– ឫស្សីមួយចម្រៀក ប្រៀកកណ្តាលអាកាស ។

(ឯកខ្លួន)

៣១– ឫស្សីមួយគុម្ព ជ្រុំកណ្តាលទន្លេ ។

(អង្រឹង)

៣២– សត្វសាំងគេចង កន្ទុយនៅខ្នង ជើងនៅក្បាល ។

(ទូកបែរ)

៣៣– បក្សីបក្សាសត្វ ហើរប្រវាត់ពុំដែលទុំ បក្សីបក្សាក្តី ពុំតែមាត់យំ ពុំឃើញខ្លួន ។

(សត្វត្រចៀកកាំទិងផ្គរលាន់)

៣៤– មានជើងមិនចេះដើរ មានស្លាបមិនចេះហើរ មានមាត់មិនចេះស្តី ។

www.budinst.gov.kh www.elibraryofcambodia.org

(គេហដ្ឋាន)

៣៥- ស៊ីពីពោះផុះពីខ្លួន ដើរមិនតម្រង់ខូចការ ។

(ផែកឈូស)

៣៦- ជើង ៤ ទល់មេឃ ជើង ៤ ទល់ដី ក្បាលបី

កន្ទុយ ១ ។

(សែនជ្រូក)

៣៧- ផុកផុលមមុលក្រោមដី សត្វជើង ៨ នាំមុខ

ផុកផុល ។

(ក្ដារស្រែ)

៣៨- អ្នកដេកស្រណុក អ្នកនៅពីលើកើតទុក្ខ បះជើង

បះដៃ ។

(បែរទូរ)

៣៩- គ្រណាប់កំសាច់ ពន្លាញកំសាច់ ទង្គក់គ្នាប៉ាច់

ស្រវាំឧបព្រឹប ។

www.budinst.gov.kh www.elibraryofcambodia.org

(ក្អែនថ្ងៅដោះ)

៤០— អ្នកតើតខ្ញុំតើប អ្នកលើកជើង ខ្ញុំសម្ងំ ។

(ត្បាល់ជាន់អង្ករ)

៤១ ទឹកពីក្រោម ភ្លើងពីលើ ម្ចាស់អើតមើលឃើញ

ពុះគគ្រុក ។ ( ខ្សៀកញ្ជា )

៤២ - កោះម្តុមមនុស្សម្នា នាំគ្នាអង្គុយជុំ ជំនុំគ្នាធំ ។

(ហិបស្លា)

៤៣— ដើមក៏ជាភ្លេងអ្នកផង កណ្ដាលជាគង ចុងជាបក្សី ។

(ទ្រមូងសេក)

៤៤— ជើងមិនជើង ក្បាលមិនក្បាល អ្នកនៅកណ្ដាល

បែកញើសជោក ។

(វែកអម្រែក)

៤៥— ឈើពុករុកគូថយាយចាស់ យាយអើយស្រួលណាស់

វៀចមាត់វៀចក ។

www.budinst.gov.kh www.elibraryofcambodia.org

(ត្បារត្រចៀក)

៤៦– ទឹកមួយថ្នុក ពស់វែនជកក ៗ

(ប្រេងចង្កៀង)

៤៧– ខែប្រាំងផ្កា ខែវស្សាក្រាប ៗ

(ដីខ្សាច់)

៤៨– មេឈប់កូនឈរ មេដើរកូនដេក ៗ

(ជន្ទល់ទេះ)

៤៩– នាងនងផ្គង់ពិសេស បងយកដៃកេះនាងបើក

ទ្វារឲ្យ ៗ

(សោរទ្វារ)

៥០– លើកជើងរំលងក្បាល មនុស្សគណ្ដាលមិនដែលគិត

(ជើងមុង)

៥១– អាធូរអាធាត់ អាធូរឥតមាក់ អាធូរធាត់ឯង ៗ

(ខ្ទើយ)

www.budinst.gov.kh www.elibraryofcambodia.org

៩២– គុកៗក្រាប ១ យកដៃទៅស្ទាប ម៉ែអើយប៉ុន្មាន ។

(រាល់អង្ករដាំបាយ)

៩៣– ឈើគោងប្រហោងឈើកាង អារក្សចូលផាង

ត្រីខ្ជាក់ខ្ជាយ ។

(ត្បាល់កិន)

៩៤– ទឹកមួយថ្នុក កុកមិនដែលចុះ ស្មៅមិនដែលដុះ

ត្រីមិនដៃមាន ។

( ថ្នុកដ្រាំ )

៩៥– ដើរតាំងៗ ដាក់គូថផាំង អ្នកស្រុកផ្អើលឈូ ៗ

( បង្គន់រុយផ្អើល )

៩៦– ធ្មេញសកលើង ពោះឡើងកំពីង កំបុតកន្ទុយ

ឡើងអង្គុយចេញកាក ។

( ខ្នាសកោសដូង )

៩៧– គោមួយឆាប់ក្រោមដើមគ្រប់ កាំបិតសា ដប់

www.budinst.gov.kh www.elibraryofcambodia.org

ការតោមិនអស់ ។

( ថ្មសំលៀងកាំបិត ) ។

៥៨– កំងអើយកំងរេ កំងដុះកណ្ដាលទន្លេ គេហៅកំងឝី ។

( កំងព្រាប )

៥៩– កុកមួយហ្វូងពណ៌ស ។ បបួលគ្នាឆ្លើយ៉ាងត្រេកអរ
រួបចុះមុជទឹកបែកកករ បរស្បូរបេដេកត្រៀបត្រា ។

(ចានបាយ)

៦០– នាងនងផ្គង់បក្សី មិនបេះដើរដី ដើរលើឈើឆាប់ៗ

(ដើមម្បូ)

៦១– ទឹកមួយថ្នុក កំពិសពង់ពេញ ។

(ផ្លែក្រូច)

៦២– បើគេប្រើធាត់ បើគេបង្អត់ស្គម ។

(ប៉ាវ ឬការុង)

៦៣– វិញកន្ទោស ខ្ទោសអាញញ ។

(ចាក់ក្តិតម្ជុល)

៦៤— អ្នកតាំង ប្រាំ ចាំដង្វាយ សាមសិមនៅកាយ ចាំ

បើកទ្វាររន្ធ ។

(ឆីបាយ)

៦៥— អំពៅមួយគុម្ព ប្រហោងដល់គល់ ។

(ដើមខ្ទឹម)

៦៦— ពីតូចស្លៀកសំពត់ ធំឡើងបេះវត់ ស្រាតសំពត់

ដួតក្បាល ។

(ផ្លែត្រប់)

៦៧— ពីតូចគេហៅតា ធំឡើងកាលណា គេហៅអា ។

(ដើមឫស្សី)

៦៨— សត្វមួយមកពីស្រុកយួន បន្ទាពេញខ្លួនយួនហៅខម

(ផ្លែម្នាស់)

៦៩— សត្វមួយមកពីស្រុកខ្លួន ត្រចៀក២ មាត់ប្រហារ ។

www.budinst.gov.kh www.elibraryofcambodia.org

( ពាងត្រចៀក )

៧០ – សត្វមួយមកពីស្រុកចិន មិនចេះបុកក្បាន ឲ្យចិន
បុកឲ្យ ៗ

( ឆ្កកដប )

៧១– សត្វមួយមកពីស្រុកសៀម អង្គុយស្ងៀម ៗ គេ
ចាប់ដាក់ខ្នោះ ៗ

( ជើងក្រានក្នុងខ្នោះ )

៧២– មនុស្សមួយមកពីត្បូង បាំងឆ័ត្រ ជ្រាងកូនចៅស្រៀ ៗ

( ដើមល្ហុង )

៧៣– គោក្រហម លិទ្ធគូថគោខ្មៅ ៗ

( ភ្លើងនិងឆ្នាំង )

៧៤ – ដើមប៉ុនដំបង ស្លឹកញ៉ែងញ៉ង អ្នកផងចង់ស៊ី ៗ

( ដើមអំពៅ )

៧៥– អាកំបិតបុកធិតអាសំរែង ចេញឈាមក្រហមខែង

www.budinst.gov.kh www.elibraryofcambodia.org

យកអណ្ដាតលិទ្ធ ៗ

(ក្បាល់បុកស្វា)

៧៦– ដើមមួយដុះតាមផ្លូវ ស្លឹកផងដើរទៅគេហៅឪ ៗ

(ឪឡឹក)

៧៧– ប្រហុកមួយពាន មានឆ្អឹងតែមួយ ៗ

(បង្គីរអកកំបោរ)

៧៨– លើកដំបូល ខូលបង្គន់ មនុស្សមិនត្រង់រក

មិនឃើញ ៗ

(ដំបូលផ្ទះ)

៧៩– ក្បាលជាសត្វនាគ កន្ទុយជាក្រអើក ដើមផ្ដាំមាន

ផ្កា ផ្លែស្រាប្រសូត ៗ

(ដើមស្វា)

៨០– កាល្អិតតូចពិត ប្រាជ្ញាមិនឥត ចំណេះថ្លៃថ្លា

ប្រាសាទប៉ុជាន់ ប្អូនកំលុំពីតា ហ៊ានទៀតពិសា



www.budinst.gov.kh www.elibraryofcambodia.org

ឥតកោតញញើត ៗ

(សត្វរុយ)

៨១– កំពីងអើយ កំពីងប៉ោះ កំពីងឥតដោះ ចិញ្ចឹម

កូនរស់ ៗ

(មេមាន់)

៨២– ឥតខ្នើយ កើយខ្នង ៗ

(សត្វទា)

៨៣– ឯកអង្គទ្រង់ព្រះផលី ថ្ងៃត្រង់ចេញស៊ី ការកោង

ស្អាកចាប់ ៗ

(សត្វដៀសជាប់អន្ទាក់)

៨៤– ផ្គរលាន់ភ្លៀសាន. ប្រាននៅអគ្នេយ៍ កូនកើតមុន

មេ មេកើតក្រោយកូន ៗ

(សត្វមេភ្លៀង)

៨៥– មានខ្សែមិនដែលចង មានដំបងមិនដែលវាយ

www.budinst.gov.kh www.elibraryofcambodia.org

មានមាត់មិនចេះស្ដី មានភ្នែកមិនផែលធេះ ។

(ពស់វែកគោ + កុកដំបងក្រញូញ + មាត់ទ្វារ + ស្រមោចភ្លើង)

៨៦– សត្វមួយមុខពីជើង ក្បាលចូលភ្លើង ជើងចាក់ស្រែះ

(សត្វក្អែប)

៨៧– កស្វាគោកេស៊ីទីងដី អាចូចកខ្វីកេស៊ីលើផ្ទះ ។

៨៨– រស់គេស្អប់ ងាប់គេស្រឡាញ់ ។

(សត្វសង្កើច)

៨៩– កក្កដាប្រាំបីបាទ រកស៊ីសង្ខាត កណ្ដាលផ្លូវថ្កើង ប្រមាថផងលើសប្រមាថជើង ស្រវាកាន់ឡើងចាក់ដូចគេកាំ គេក្ដិបសិនថាគេខាំ ចុះកន្ត្រាំកណ្ដាលគង្គា ។

(សត្វក្ដាមសមុទ្រ)

៩០– នាមវាគឺព្រឹទ្ធយក្ស ភ្នែកសៀនស៊ើរធ្លាក់ ដៃវែងជាងខ្លួន ។ (សត្វបង្កង)

www.budinst.gov.kh www.elibraryofcambodia.org

៩១– អង្គុយខ្ពស់ជាងឈរ ឃើញគេមកមិនដែលអរ ។

( សត្វឆ្កែ )

៩២–ក្រលីងក្រលោងលោត នរណាទោតរកមិនឃើញ។

( សត្វក្រលីងក្រលោង )

៩៣– ចិនទៅ ដោះអាវទាប់ ។

( សត្វកង្កែប )

៩៤– ផ្គរលាន់គគ្រឹម ភ្លៀងធ្លាក់លើម នាមាបក្សា
រកស៊ីសព្វថ្ងៃ បានផ្អែតអស្ចារ្យ លំនៅក្បែរគ្រា
ព្រៃមាត់ថ្ងូរ ។

( សត្វព្រាប )

៩៥– ឯកអើយអ្នកឯក ពូជអ្នកចំឡែក ឯកធំកូនឯង ។

( ត្រីឆ្តោ )

៩៦–អូសមងចងបង្កែ រកស៊ីសព្វថ្ងៃ អាស្រ័យទឹកគូថ។

( សត្វពីងពាង )

www.budinst.gov.kh www.elibraryofcambodia.org

៩៧– នាងនួនវិឡារ មានឫទ្ធិអស្ចារ្យ ខាងចាប់មូសិក

មានជើងមានដៃ មុខជាងសត្វម្រឹគ ចិន្តាតែងទឹក

ឲ្យម្ចាស់មានទ្រព្យ ។

(សត្វឆ្មា)

៩៨– សត្វមួយមកពីស្រុកខាងលិច កន្ទុយសិចរិច

ស៊ីដែក ៗ ។

(សត្វជ្រូក)

៩៩= តាតាតោកដូចត្រឡោកអ្នកឯង ដកកឡើងវែង

ដូចត្រឡោកបេះដើរ ។

(សត្វអណ្តើក)

១០០– សត្វមានវិញ្ញាណទិងប្រាជ្ញា ចិត្តឥតសាវ៉ក្ទង់ហេតុ

ផល គស៊ូសត្វយ៉ាងលើកប្តូកល បើគិតមិនដល់មិនបានថា

(សត្វមនុស្ស)

(ចប់ច្បាប់ពាក្យបណ្តៅ)

www.budinst.gov.kh www.elibraryofcambodia.org

# ច្បាប់ភាសិត

ភាសិត គឺជាពាក្យដឹកនាំមនុស្ស ឲ្យអនុវត្តទៅតាម មាគ៌ាមធ្យោបាយនៃកុសលសម្ពន្ធនិមួយ ៗ ដើម្បីឲ្យបាន ស្គាល់នូវគ្រប់វិស័យរស់នៅ ក្នុងរបបសង្គមជន ។

ដោយរូបន័យនេះ ភាសិតសំដៅយកតម្រាទូន្មាន ប្រៀនប្រដៅ ហើយការប្រៀនប្រដៅនោះចែកចេញជា ពីរចំណែក និយមន័យណាដែលប្រដៅមនុស្សឲ្យលះបង់ អំពើមិនសមហេតុផល ឈានចាប់យកទ្រឹស្តីល្អសម្រាប់ ទំពាំជីវិត និយមន័យនោះហៅថា សុភាសិត ប្រែថា ពាក្យប្រៀនប្រដៅមនុស្សឲ្យមានគាក់ចិប ផ្នែកគំនិតប្រព្រឹត្ត ល្អ ។ និយមន័យណាដែលប្រដៅមនុស្ស ឲ្យរុល

www.budinst.gov.kh www.elibraryofcambodia.org

ខ្លួនធ្វើដំណើរទៅលើទ្រនំស្ពានក្រខ្វក់ទាំងមិលសុំមិនបង្កើនទុទិដ្ឋិនិយម ភាសិតនោះហៅថា ទុភាសិត ប្រែថាពាក្យសម្រាប់ប្រដៅមនុស្សឲ្យប្រព្រឹត្តអាក្រក់ ទោះតាមផ្លូវកាយក៏ដូចជាផ្លូវវាចា និងផ្លូវចិត្តដែរ ។

## រូបន័យ នៃ ភាសិត

តាមព្រឹត្តិការណ៍ នៃ ភាសិត ដែលមានមកតាំងពីបុរាណសម័យ ទល់នឹងបច្ចុប្បន្ននេះ តែងស្ថិតស្ថិតនៅលើលក្ខណរូបន័យពីរយ៉ាង គឺ :

ក) ន័យអត្ថានុរូប = ន័យចំ ៗ គឺន័យដែលយើងត្រូវអធិប្បាយ តម្រង់លើសភាពសំដីដែលហូរហៀរចេញតាមនិន្នាការភាសិត ទោះបីភាសិតនោះបង្ហាញបង្កប់ន័យជាបញ្ហាចំពោះជីវិតមនុស្សក៏ដោយ រុក្ខជាតិក៏ដោយ ន័យទាំងនេះហៅថា ន័យអត្ថានុរូបទាំងអស់ ។

១- ចេះមកពីរៀន មានមកពីរក (រៀនចេះរកមាន)

១)  ន័យអត្ថបដិរូប = ន័យប្រៀបធៀប  គឺន័យដែលយើងត្រូវអធិប្បាយចេញពីក្រុមភាសិតប្រភេទណា ដែលពោលភ្ជាប់ទៅលើធម្មជាតិឬសត្វ ។

ឧ-  កុំកាប់បំពង់ រង់ចាំទឹកភ្លៀង  (ក់សនាទិនបុណ្យសក្តិ)

ការកត់សំគាល់ : ភាសិតណា ដែលពោលចំលើជីវភាពមនុស្សត្រង់ៗ ភាសិតនោះមានន័យតែមួយ គឺន័យអត្ថានុរូបប៉ុណ្ណោះ ។ ឯភាសិតណា ដែលពោលចំលើបលនាធម្មជាតិ ភាសិតនោះត្រូវមានន័យពីរ គឺន័យអត្ថានុរូប និងន័យអត្ថបដិរូប (ន័យធម្មជាតិ ប្រៀបទៅលើន័យជីវិតមនុស្ស)

## គម្រោងការនៃការតែងភាសិត

ជាបឋមនៃការធ្វើគន្ធប្រធានបែបភាសិត  យើងត្រូវសញ្ជឹងគិតតាមផែនការបំណងដូចតទៅ ៖

www.budinst.gov.kh www.elibraryofcambodia.org

ផែនការទី ១ (សេចក្ដីផ្ដើម) ត្រូវពិនិត្យឲ្យច្បាស់នូវគោលគំនិតនៃភាសិត ដែលយើងត្រូវអធិប្បាយ។

ឧ- « កុំកាប់បំពង់រង់ចាំទឹកភ្លៀង » គំនិតសំខាន់គឺ ចង់ប្រដៅកុំឲ្យមនុស្ស ជឿទៅលើព្រេងកសនាហួសវិស័យ គ្មានការពិចារណា ។

ផែនការទី ២ (អង្គសេចក្ដី) ក្នុងនាទីនេះគឺយើងត្រូវអធិប្បាយបំបែករូបន័យ ដោយបញ្ជាក់ទៅលើន័យអត្ថរូបនិងន័យអត្ថប្បដិរូប ហើយវាំងពីរនេះតែងតែហោចភ្ជាប់ទៅក្នុងគោលន័យមបីយ៉ាងគឺ : មតិ (Thèse), បដិមតិ (Antithèse), និងសំយោគមតិ (Synthèse) ។

គួរចំណាំ - មតិ : ត្រូវអធិប្បាយស្របតាមប្រធានរោទ។

ឧ-បើប្រធានរោទថា „កុំកាប់បំពង់រង់ចាំទឹកភ្លៀង, យើងត្រូវដៅថា មិនត្រូវកាប់បំពង់យកទៅត្រងទឹកភ្លៀងទេ ព្រោះវាជាធម្មជាតិមិនទៀងទាត់ដល់សេចក្ដី

ក្តីត្រូវការរបស់មនុស្ស ។ រីឯវាសនាក៏យើងមិនត្រូវផ្ញើ គំនិតលើទាំងអស់ដែរ ព្រោះវាជាអរូបធម៌ឥតមានឥទ្ធិ-ពលដល់ការរស់នៅរបស់មនុស្សទាល់តែសោះ បើមនុស្សខ្វះយាមចំពោះកិច្ចការ ។

បដិមតិ : ត្រូវអធិប្បាយបង្ហាញគំនិតផ្ទុយពីមតិខាងដើម គឺផ្ទុយពីការចោទរបស់ប្រធាន ។ ១. កុំកាប់បំពង់រង់ចាំទឹកភ្លៀង : កាលបើមនុស្សមិនយកបំពង់ទៅត្រងទឹកភ្លៀងឬ មិនជឿវាសនាសោះនោះ មិនជាការប្រពៃទេវិញទេ ព្រោះថា ពិតមែនតែភ្លៀងបង្អុរចុះមិនទៀងទាត់ តែបើយើងយកវត្ថុទៅត្រង ទោះបីយ៉ាងណា ក៏បានទទួលលទ្ធផល គឺបានទឹកសម្រាប់ប្រើប្រាស់ដែរ ។ ឯវាសនាមនុស្ស ខ្លះខំប្រឹងសិក្សា ខ្លះខំប្រឹងប្រែងធ្វើការតាមកិច្ចយ៉ាងមមាញឹកដែរ តែលទ្ធផលល្អមិនសូវមាន មិនតែប៉ុណ្ណោះជួនកាលគ្មានទាំងបានទទួលផលនោះសោះក៏សឹងមាន ។

www.budinst.gov.kh www.elibraryofcambodia.org

អញ្ញកាលបើហេតុកេទកើតឡើងបែបនេះ តើយើងអាចឃាត់មិនឲ្យជឿលើព្រេងសាសនាបានឬទេ ?

ដូច្នេះយើងគួរតែជឿលើចំនួនសាសនាផងទើបគួរ ។

សំយោគមតិ : មានអាចបំប្រួញមតិនិងបដិមតិឲ្យស្របចូលគ្នាវិញ ។ ឧ. ម្នាក់ ៗ មិនត្រូវយកបំពង់ទៅរង់ចាំត្រងទឹកភ្លៀងឡើយ តែបើគ្មានទឹកសោះនោះគួរតែត្រងទឹកភ្លៀងដែរ ចំណែកសាសនា យើងមិនត្រូវជឿជាដាច់ខាត តែបើអស់សង្ឃឹមត្រូវតែជឿខ្លះ ដើម្បីឲ្យធូរដើមទ្រូង ជៀសវាងការវិកលចរិត ។

ផែនការទី៣(យោបល់) យើងត្រូវបញ្ជាក់ជាបណ្ដាច់នូវលក្ខណៈសំខាន់នៃការគិត តាមចំណូលចិត្ត និងដើម្បីជាលទ្ធផលល្អក្នុងការប្រព្រឹត្តតាមសេចក្ដីអធិប្បាយ ។

១. ពាក្យទូន្មានខាងលើ ដែលបានអធិប្បាយមកនេះ បង្ហាញនូវមាគ៌ាដ៏ប្រសើរ គឺការព្យាយាម កាលបើមនុស្ស

www.budinst.gov.kh www.elibraryofcambodia.org

មានព្យាយាមល្អហើយ សុភមង្គលសព្វយ៉ាងតែងកើតឡើងជាចាំបាច់ មិនតែប៉ុណ្ណោះ ម្នាក់ ៗ តែងបាននាមប្រាកដ ថាជាអារ្យជនជាប្រត្យក្ស ។

++++++++

## សុភាសិត

បើទុកជាគិតឃើញវិសតាស្មោះ មិនត្រូវបង់បោះ
សេចក្ដីប្រឹង ត្រូវខំខ្នះខ្នែងពេញទំហឹង ព្រោះប្រឹង
និងបុណ្យជាគូគា ។

## គំនិតរៀបចំ

សត្វនិករភាគច្រើនក្នុងពិភពលោកទាំងមូល កាលបើប្រសូតចាកគភ៌មាតាពេលណាមក លុះបានដ្រួតដ្រាបដឹងសេចក្ដីខុសត្រូវហើយ តែងតែមានកូនជំនឿមួយភ្ជាប់ទៅនឹងទឹកចិត្តជានិច្ច គឺសង្ឃឹមលើព្រេងវាសនារបស់ខ្លួន ៗ ទោះបីមនុស្សមួយចំនួនដែលមានសតិគ្គកាយ

វិកលវិការដល់កិរិតណាក៏ដោយ កំមានអារម្មណ៍រំពឹង ជានិច្ចចំពោះរាសនាអនាគតរបស់ខ្លួន ដើម្បីឲ្យបានចំណេះវិជ្ជា បុណ្យស័ក្តិទ្រព្យសម្បត្តិដូចគេឯងដែរ ៗ ជាការពិតណាស់ មនុស្សកើតមក ហើយមានលក្ខណៈគ្រប់គ្រាន់មានអាយុយឺនយូរនោះ ជាកព្វសំណាងណាស់ទៅហើយ ៗ ចំណែកបុណ្យស័ក្តិ បើមនុស្សមិនខំស្វែងរកទេនោះ ប្រាកដជាគ្មាននរណាអាចជួយឲ្យកើតមានឡើងបានឡើយ ៗ

++++++++++

## គក់ ៗ ពេញបំពង់ ឆ្កុង ៗ កន្លះគ្រហែត

## គំនិតរៀបចំ

— ដំណក់ធម្មជាតិមានភ្លៀងជាដើម កាលបើស្រក់ចុះក្នុងបំពង់ណាមួយដែលមានមាត់ចហារ ពិតមែនតែមានគ្រាប់តូច ៗ តែបើស្រក់ផ្សំយូរ ៗ ទៅ អាចបង្កើតជាទឹកពេញប្រៀបបំពង់បាន តែបើគេចាក់ទឹកមួយធុងយ៉ាងធំណាំ ចូលក្នុងបំពង់ដោយឥតកោតញញើត ទឹក

កន្ទបំពង់តែងក្រឡុកឡើងវិញ នៅសល់បំពង់គេហោត មិនអាចពេញប្រៀបបានឡើយ ។

សត្វកណ្ដៀរកេងបូក ស្រមោចពូនសំបុក មនុស្សមានព្យាយាម កាលបើគេកពូនប្រឹងប្រព្រឹត្តម្ដងបន្តិច ៗ តាមសមត្ថភាពដែលខ្លួនមាន ទោះបីសមិទ្ធិនោះមានទំហំប៉ុណ្ណភ្នំព្រះសុមេរុក៏ដោយ ក៏អាចសម្រេចបានដោយងាយ ។ កិច្ចការបន្ទាប់បន្សំល្អមនឹងកម្លាំងបំពេញ តែបើយើងធ្វើតាមដំនោរចិត្តនឹកឃើញនោះ សមិទ្ធិការ្យនោះពុំបានលទ្ធផលល្អឡើយ ។

++++++

## បេះមកពីរៀន មានមកពីរក

## កំណត់រៀបចំ

សេចក្ដីប្រាថ្នានៃមនុស្សលោក សុទ្ធតែចង់ឲ្យខ្លួនមានតម្រិះប្រាជ្ញាឈ្លាសវៃនូវគ្រប់វិជ្ជាជីវៈ សម្រាប់អបស្ទុបលើបញ្ហារស់នៅឲ្យបានស្មើមុខនឹងគេឯង ។ ការ

បេះដឹងដែលមាននៅក្នុងខួរសេរី នៃប្រជាជនប្រទេសណាមួយទៅបាន លុះត្រាតែជននោះបានចូលទៅសិក្សាតម្រាក្បួនច្បាប់ដោយហ្មត់ចត់ មិនមែនគ្រាន់តែដេកគងអន្ទាក់ខ្លាធ្វើក្អែកមើរ ហើយបន់ស្រន់សុំឲ្យចំណេះវិជ្ជាគេចូលក្នុងខួរក្បាលបានដោយងាយឡើយ ។ ឯជនដែលគេមានទ្រព្យសម្បត្តិទៀតសោត ក៏គេមិនមែនខ្ជិលច្រអូសសំកុកអង្គុយទន្ទឹមបែបមួយៗនោះទេ ប្រាកដជាគេមានបានដោយការស្មុះស្មាស្វែងរកគ្រប់ពេលវេលា គ្មានត្អូញត្អែរទំរន់ទឹងបាតុក្កូតសព្វយ៉ាង ។ កាលបើយើងព្យាយាមតស៊ូចំពោះកាតព្វកិច្ចគ្រប់ជំហាន វិជ្ជានិងទ្រព្យសម្បត្តិរមែងកើតមានដល់យើងជាចាំបាច់ ។

www.budinst.gov.kh www.elibraryofcambodia.org

# ទូកទៅ កំពង់នៅ

## គំនិតរៀបចំ

ទូកជាយានសម្រាប់ដឹកនាំសម្ភារៈ និងសម្រាប់បំពេញសេចក្តីត្រូវការរបស់មនុស្ស ក្នុងការធ្វើដំណើរតាមជលបថ ។ ទូកចេញផុត កំពង់តែងស្ថិតនៅជានិច្ច ពុំដែលមានពេលណា កំពង់ពុំដែលភ្ជាប់ទៅជាមួយទូកផងឡើយ ។

មនុស្សរស់នៅក្នុងសង្គមកុលសម្ពន្ធ តែងមានការទាក់ទងរវាងគ្នានិងគ្នាជាត្រីមុខ ។ ក្នុងពេលៈដែលយើងទៅស្នាក់អាស្រ័យលើគេហដ្ឋានមិត្តភ័ក្ត្រស្គាល ឬ នៅក្នុងទីណាដោយបណ្តោះអាសន្ន មិនគប្បីយើងបញ្ចេញបរិយាកាសរលួយ ទុច្ចរិតនៅទីនោះទេ ។ កាលបើយើងជម្រុះអំពើពាលអប្បលក្ខណ៍ ក្នុងទីដែលយើងស្នាក់នៅនោះ លុះយើងចេញផុតទៅ កេរ្តិ៍មាត្រករបស់ខ្លួន

តែងជាប់នៅស្អុយរអ៊ើនជានិច្ច ជាពិសេស សាម័ជន ដែលឲ្យយើងជួបរោគនោះ ត្រូវទទួលកិត្តិស័ព្ទដ៏អសោចិ ដោយសារយើងមិនចេះរក្សាចិត្តគំនិត ឲ្យត្រឹមត្រូវតាមមនុស្សធម៌ ។

## អណ្តាតជាអាទ៍ក្លង ស្លាប់ផងរស់ផង ពីព្រោះអណ្តាត ។

### កំណិតរៀបចំ

គ្រប់តែនាទីរស់នៅ មនុស្សត្រូវការជាទីបំផុតនូវសំដី ចរចាគ្នាទៅវិញទៅមក ក្នុងករណីយកិច្ចដែល ទាក់ទងរវាងគ្នានិងគ្នា ក្នុងសង្គមគ្រួសារ ។ ពាក្យសំដីសំនួនវោហារ ដែលហូរហៀរស្រូតចេញពីដួងវិញ្ញាណ តែងផ្តល់ទៅនូវការពិត និងគ្រោះថ្នាក់ប្រហាំដ៏ពិតផ្ទាល់ខ្លួន ឬ អ្នកដទៃជាចាំបាច់ ព្រោះវាជាដើមចម នៃហេតុការណ៍គ្រប់ប្រភេទ ។

www.budinst.gov.kh www.elibraryofcambodia.org

មនុស្សជាតិភាគច្រើន ត្រូវមានជោគជ័យយ៉ាងគាប់ប្រសើរ លើទំព័រជីវិតដោយសារអណ្តាត តែខ្លះត្រូវបាត់បង់កិត្តិយស កេរ្តិ៍ឈ្មោះ អស់ទ្រព្យសម្បត្តិ រហូតដល់សូន្យជីពផងក៏ព្រោះតែអណ្តាតនោះឯង ។ រូបមន្តខាងលើនេះ ស្របទៅនឹងពាក្យថា : លោកស្ថិតនៅលើពាក្យផ្អែមល្ហែមទៅរកអ្នកដទៃ បើដូចនេះ ក្រអឺនឹងពាក្យផ្អែមល្ហែមទៅរកអ្នកដទៃ ។

++++++++++++

# សំណាបយោងដី ស្រីយោងប្រុស

## គំនិតរៀបចំ

របរកសិកម្ម ជាសេដ្ឋកិច្ចសម្រាប់រដ្ឋមួយចំណែក យ៉ាងពិសេស ។ ពួកកសិករ គ្រប់ជនបទ កាលបើមានភ្លៀងធ្លាក់ជោកជាំហើយ តែងរកជីធូចាក់ដីលើកថ្នាល ដើម្បីសាបព្រោះពូជធារ ៗ សំណាបល្អ មានលក្ខណៈ គឺ: មានដើមធំៗ ស្លឹកខៀវខ្ចី ឫសច្រើន ហើយក៏ជាប់ដីជាច្រើន

www.budinst.gov.kh www.elibraryofcambodia.org

ផង សំណាបអន់ ៗ លុះដល់គេយកទៅស្ទូង ទោះបើ ដីស្រែមិនសូវមានជីជាតិក៏ដោយ ក៏អាចជួយដំឡើងសភាព សន្ទូងឲ្យបានល្អបង្គួរដែរ ៗ សត្វមានញីមានឈ្មោល មនុស្សមានស្រីមានប្រុស ស្រីគ្រប់លក្ខណ៍ អាចជួយលើក យោងប្ដីឲ្យមានកិត្តិយស និងសេចក្ដីថ្លៃថ្នូរគ្រប់ពេលវេលា ដំរីខ្វាក់ទ្រមាក់ក្លួត បើប្ដីជាអ្នកផឹកស៊ីប៉ោល្បែកាក់សែ ស្រី ជាប្រពន្ធមានមធ្យោបាយ បេះធ្វើឲ្យប្ដីសប្បាយចិត្តក្នុងគ្រួ សារ ប្ដីអាចលះបង់បានដោយងាយនូវភាពនោះ បើ មិនទាំងអស់ក៏ធូរស្រាលជាងដើមដែរ ៗ

## អូសទូកកុំឲ្យល្អាង ចាប់ត្រីបានកុំឲ្យល្អក់ទឹក

គំនិតរៀបចំ

ទូកគេចាត់ទុកយានខាងជលបថ ហើយសម្ភារៈនោះ រៀបចំឡើង ដោយមានបិទជ័រ នៅពីខាងក្រោមផង ៗ

www.budinst.gov.kh www.elibraryofcambodia.org

កាលបើគេអួស ត្រូវរកកំណាត់ឈើយកមកសើមពីក្រោម ដើម្បីកុំឲ្យរបើកដីចេញពីសន្ទះក្តារក្តិត ៗ ឯត្រីជាមច្ឆជាតិសម្រាប់ជាអាហារ នៃប្រជារាស្ត្រ ហើយពួកនេសាទ តែងចាប់យកទៅធ្វើជាម្ហូប និងលក់ដូរតាមត្រូវការ តែពួកនេសាទគប្បីចាប់មច្ឆជាតិទាំងនោះ ដោយមធ្យោបាយយ៉ាងណា កុំឲ្យទឹកក្នុងថ្លុកត្រពាំងកករល្អក់ឲ្យសោះ ព្រោះទឹកថ្លាជាសេចក្តីត្រូវការរបស់អ្នកផងទាំងពួង ៗ

ក្នុងការស៊ើបអង្កេតបំបាក់ជនទុច្ចរិតក្តី ក្នុងការសិក្សាយកជ័យជំនះក្តី កិច្ចការអ្វី ៗ ក្តី យើងត្រូវធ្វើឲ្យសម្រេចដោយកលល្បិចសន្តិភាព គឺកុំធ្វើឲ្យប៉ះពាល់ដល់អ្នកសុចរិត ៗ ក្នុងនាមនៃអ្នកសិក្សាត្រូវកុំឲ្យគេដឹងមុនថាយើងធ្វើកិច្ចការ ដើម្បីយកជ័យជំនះ ក្នុងការរៀនសូត្រឲ្យសោះ ៗ

www.budinst.gov.kh www.elibraryofcambodia.org

# ពាក្យពិតមិនចេះស្លាប់

## គំនិតរៀបចំ

ពាក្យពិតស្ថិតនៅលើទឿនភាពទៀងត្រង់ លះបង់ការកុហកបោកប្រវ័ញ្ចកែបន្លំចិត្តគំនិតខ្លួនឯងនិងអ្នកដទៃ ។ ពាក្យពិតអាចនាំមកនូវអត្ថប្រយោជន៍សព្វយ៉ាង ដល់ក្រុមគ្រួសារ និងសង្គមជាតិដូចគ្នា ។ ពាក្យពិតជាអរូបនាមរស់នៅជានិច្ច ទោះបីរូបមនុស្សបាត់ទៅក៏ដោយ ឯពាក្យពិតសល់នៅរស់រវើក ហើយផ្ដួចលនាយ៉ាងសកម្ម ចូលស្ថិតជាប់ក្នុងសន្ដានចិត្តប្រជាករគ្រប់ប្រភេទ ។ ក្បួនច្បាប់ផ្សេង ៗ ដែលបានចងក្រងចេញពីពាក្យបរិសុទ្ធរបស់អ្នកប្រាជ្ញបូរាណ តែងរស់នៅជាច្រើនសតវត្សរ៍តាំងពីបុព្វសម័យ រហូតដល់បច្ចុប្បន្នសម័យ ។ ទាំងនេះហើយដែលនាំឲ្យឃើញថា ម្នាក់ ៗ កាលបើគ្មានពាក្យសត្យក្នុងខ្លួនទេ ហាក់ដូចជាជនដែលរស់នៅ មានតែសព្វាង្គកាយ

www.budinst.gov.kh www.elibraryofcambodia.org

តែឥតសោះឡើយសតិសម្បជញ្ញៈ ពោលឲ្យចំ គឺជាមនុស្សរស់ឥតប្រយោជន៍ ធ្ងន់តែផែនដី ហើយអ្នកប្រាជ្ញរាប់ចាត់ទុកដូចជាជនស្លាប់អស់ជីវិតដែរ ។

## ស្លូតស្លាប់ វៀចវេមានភ័ក្ត្រ អាយុយឺនយូរ

### គំនិតរៀបចំ

ដោយយល់ឃើញថា ប្រជាករខ្លះហានសភាពអ្នកស្លូត គ្មានកលល្បិច សម្រាប់គេចវេះកៀសខ្លួនឲ្យរួចពីភ័យអន្តរាយសោះ ទើបបុព្វាចារ្យ បានចងទុកជាទិដ្ឋានុគតិដូចខាងលើ ។

គ្រប់មជ្ឈដ្ឋាន គេស្អប់ណាស់នូវជនពាលកាចសាហាវយង់ឃ្នង ទំនើងមានចិត្តគំនិតវៀចវេ តែផ្ទុយទៅវិញ មនុស្សត្រូវមានប្រាជ្ញានិងស្មារតីវៃប៉ិន ត្រូវស្គាល់ព្រឹត្តិការណ៍ នៃការលៀងជីពជន្ម ។

ដូច្នេះ មនុស្សត្រូវមានកលោបាយ ក្នុងសភាពការណ៍សម្រាប់យកខ្លួនឲ្យរួចពីគ្រោះកាច ដែលកើតឡើងម្ដងម្ដាល ៗ ក្នុងបំណោមជនដូចគ្នា យើងមិនត្រូវដំអក់ទម្រន់ខ្សែជីវិត រហូតដល់ស្លាប់កេរ្តិ៍ឈ្មោះ និងស្លាប់ខ្លួន ដោយសារការស្លូតត្រង់ហួសវិស័យ មនុស្សធម៌ឡើយ យើងត្រូវតែតាំងជាមួយខ្មាំងសត្រូវ ដែលប៉ងប្រមាថពាធផង ដល់សង្គមជាតិរបស់ខ្លួនជាប្រត្យក្ស ។

++++++++++++++

## ប្រាជ្ញឯង ឲ្យក្រែងប្រាជ្ញគេ

### គំនិតរៀបចំ

ពាក្យខ្លះកាន់វោហារប្រាជ្ញ រំលោភមនោសញ្ចេតនាហៈ អ្នកផង សំអាងលើការចេះដឹងរបស់ខ្លួន ពោលបំបិទទឹកចិត្តអ្នកដទៃ ដោយអគតិធម៌ណាមួយ មានលោភគតិជាដើម ។ ពាក្យបែបនេះ មិនដែលមាន

www.budinst.gov.kh www.elibraryofcambodia.org

គំនិតសំគុកគិតថា ថ្ងៃណាមួយខ្លួននឹងលិចចុះក្នុងការអាមាស់មុខ ដោយសារប្រាជ្ញាវោហារបស់ជនឡើយ ៗ សភាពអ្នកចេះច្បាប់ ហើយអង្គុយលើច្បាប់ កាត់សេចក្តីឲ្យជនដទៃ តាមអំពើចិត្តនឹកឃើញ ព្រោះតែក្តីលោភលន់សំណូកនោះ ៗ អំពើអយុត្តិធម៌ បែបខ្មៅងងឹតនោះរមែងក្លាយទៅជាអាវុធសម្រាប់សំពងបកមកអាត្មាវិញ មិនខានក្នុងថ្ងៃណាមួយ ដែលមានអ្នកចេះដឹងដូចខ្លួនឬលើសខ្លួននោះកើតឡើង ៗ

ក្នុងបែបរស់នៅ យើងមិនត្រូវមើលងាយគេ ដោយគាន់ថាមានតែខ្លួនមួយប៉ុណ្ណោះ ដែលចេះដឹងជាងអ្នកដទៃឡើយ គឺត្រូវដឹងច្បាស់ថា មធ្យោបាយបែបអាត្មាអញធ្វើនោះ អ្នកដទៃអាចធ្វើបានដូចខ្លួនអញដែរ ៗ

**ចាន់ — សយ**

www.budinst.gov.kh www.elibraryofcambodia.org

# ចិត្តល្អក្រខ្លួន ស្លួនតែងចិត្តល្អក្រមិនយូរ

## គំនិតរៀបចំ

បុត្របុរសរបស់យើង តែងមានឧត្តមគតិ ចង់ជួយយើតយោង បណ្ដាជនឲ្យចេះជួយសង្គ្រោះគ្នាទៅវិញទៅមក តាមផ្លូវកាយក៏ដូចជាតាមផ្លូវចិត្តដែរ ។ ការដែលមនុស្សចេះជួយសង្គ្រោះគ្នាជាការប្រសើរណាស់ តែមុននឹងធ្វើចិត្តល្អ ចំពោះជនណាម្នាក់ ត្រូវមានវិចារណញ្ញាណ ពិនិត្យពិច័យលក្ខណចរិយា ជននោះជាមុនសិន ។ បើយើងមានហឫទ័យល្អ ហើយចំណាយទ្រព្យសម្បត្តិលុយកាក់ឲ្យចំពោះជនដែលដើរលេងស៊ីផឹកស្វិប្រទូអ្នកទ្រូក ដោយល្បែងស្រីស្រា អំពើពាលា មិនយូរប៉ុន្មានអ្នកចិត្តល្អនោះត្រូវទទួល គ្រោះថ្នាក់ជាមិនខាន ។ កាលបើឧបសគ្គបែបនោះកើតឡើងប្រកែកជនចិត្តល្អនោះ ត្រូវធ្លាក់ចុះក្នុងនាមក្រខ្លួនជាប្រត្យក្ស ។ រីឯជនដែលមានចិត្តល្អ ចំពោះ

www.budinst.gov.kh www.elibraryofcambodia.org

តែនរណា ដែលមានមនុស្សធម៌ប្រចាំអាត្មា ស្គាល់គុណទោស ប្រព្រឹត្តចិញ្ចឹមជីវិតដោយសុចរិត អ្នកនោះអាចជួយផលម្ចាស់ទានវិញ ក្នុងថ្ងៃណាមួយមិនខាន ហើយអ្នកចិត្តល្អបែបនោះ បើធ្លាក់ខ្លួនក្រក៏មិនក្រយូរដែរ ។

++++++++++

## នាងរត់រកអ្នក មេខាតលក្ខណ៍

## រត់រកអាក់បាក់អន្សា

### គំនិតរៀបចំ

មេបាចាស់ទុំ មុនរៀបចំផ្សំផ្គុំកូនទៅ ឲ្យមានគូស្រករ តែងមានការពិនិត្យយ៉ាងម៉ត់ចត់ សូម្បីតែរូបអ្នកមានខ្លួនទាំងសង្ខារ ក៏សុទ្ធតែប្រាថ្នាឲ្យបានគូជីវិត របស់ខ្លួនមានចិត្តគំនិត និងចរិយាត្រឹមត្រូវទាំងអស់ដែរ ។

នារី ដែលមានលក្ខណៈចរិយាពេញលេញចេះដឹងនិងគោរពច្បាប់ខ្លួនជាស្រី ស្គាល់អស់ស្គាស់គន់ ស្គាល់បង

ស្គាល់ប្អូន ស្គាល់ចាស់ព្រឹទ្ធាចារ្យ ៗ ពេលធំកាលណា តែងបានជួបប្រទះនឹងគូប្រុសត្រឹមត្រូវ មានចរិយាសមសួន មានចិត្តបេះអាណិតអាសូរភរិយាមិនខាន ព្រោះប្រុសបែបនេះ តែងជ្រើសរើសគូភរិយាណាស់ គេមិនមែនឲ្យតែឃើញស្រីរូបស្អាត ហើយបេះតែបញ្ចេញមន្តស្នេហ៍ឡើយ ៗ ឯស្រីដែលមានចិត្តនិងសណ្ដាប់ធ្នាប់ល្អិតល្អើន បុគពាត់តខ្លាស់ តែងជួបប្រទះ ប៉ះពាល់លើប្រុសកំបាក់អន្សាមិនខាន ព្រោះប្រុសដែលចូលចិត្តដើរលេងស៊ីបាយខ្ជិលច្រអូសគេគ្មានបានគិតដល់អ្វី ក្រៅពីស្ត្រីមានរូបស្អាតឡើយ ៗ

## ទឹកត្រជាក់ត្រើក

### គំនិតរៀបចំ

ធម្មជាតិបង្កើតប្រាកដកូតមានក្តៅមានត្រជាក់ សព្វ

www.budinst.gov.kh www.elibraryofcambodia.org

សត្វមានចិត្តប្រាថ្នាខុស ៗ គ្នា ខ្លះមានចំណូលទាងអាកាសធាតុក្តៅ ខ្លះមានចំណូលចូលចិត្តអាកាសត្រជាក់ ៗ មច្ឆាក្នុងគង្គារស់នៅអាស្រ័យលើធាតុក្តុត្រជាក់ ព្រះសុរ្យសែងចែងចាំងលើគង្គាក្តៅមហិមា រុក្ខឆាយាគឺម្លប់ឈើតែងបាំងកំដៅកាំរស្មីនៃព្រះអាទិត្យ មច្ឆាតូចធំតែងចូលមកសម្ងំក្នុងទឹកដែលមានម្លប់ទ្រឈឹងទ្រឈៃ យ៉ាងកុះករ ៗ សត្វមមាចស្លាប់នឹងភ្លើង ស្រមោចក្បែរនឹងស្ករ ឯមនុស្សស្លាប់នឹងពាក្យផ្អែមល្ហែម ដែលហៀរហូរចេញពីមេត្តាចិត្ត ៗ មេត្តាធម៌ ជាម្លប់ដ៏ត្រជាក់ត្រជំ សម្រាប់មនុស្សជាតិដូចគ្នា កាលបើនរណាមានចិត្តមេត្តាចេះអាណិតអាសូរ សន្តោសដល់អ្នកដែលនៅក្រោមបង្គាប់ហើយពលករគ្រប់វណ្ណៈតែងរត់មកជ្រកយ៉ាងកកស្រទាប់ ដោយសុខក្សេមក្សាន្ត ៗ

www.budinst.gov.kh www.elibraryofcambodia.org

# មារយាទថ្លៃឲ្យយក មារយាទថោកឲ្យវៀរ

គំ ឆិត រៀបចំ

កេរ្តិ៍ឈ្មោះយសស័ក្តិ, ទ្រព្យសម្បត្តិ, ចំណេះវិជ្ជា កើតឡើងដល់ជនណា ដែលបានស្វែងរក ដោយក្តីព្យាយាមកពិតមែនហើយ ប៉ុន្តែលុះណាតែជននោះ មានគំនិតមារយាទថ្លៃថ្នូរ ចេះរក្សាថែទាំឲ្យភ្ជាប់ខ្លួន នៅក្នុងសន្តានចិត្តយ៉ាងប្រសើរផងទើបបាន ។ បើសិនជាអ្នកមានបុណ្យស័ក្តិ ទ្រព្យសម្បត្តិ ចំណេះវិជ្ជា តែទឹកចិត្តគំនិតមារយាទថោកទាប ដើរអួតអាងវាយឫកពា ក្នុងតម្រារបស់ពាលជន ល្ងើយយូគោង មិនស្គាល់គុណទោស ខ្ជិលអ្ជើខ្ជជាតិ គុណសម្បត្តិទាំងនោះ ត្រូវសាបសូន្យទៅវិញជាត្រើមុខ ៗ

តាមចិត្តសាស្ត្រ យើងជាអ្នកសិក្សា ត្រូវមានវិចារណញ្ញាណ ពិចារណាមើលគំនិតមារយាទ នៃការ

www.budinst.gov.kh www.elibraryofcambodia.org

ប្រព្រឹត្តរបស់ខ្លួន និងការប្រព្រឹត្តនៃបរជន បើឃើញថាមតិណាល្អយើងត្រូវតម្កល់ទុក បើមតិណាអាក្រក់គប្បីយើងវៀរបង់ចេញពីខ្លួនជាបន្ទាន់ ទើបយើងបានជាមនុស្សល្អ ។

+++++++++

## ឈើកោងវល្លិ៍ព័ន្ធ មនុស្សខ្វាត់ភ្លាត់
## កុំយកខ្លួនបៀត

គំ ឆិន រៀបចំ

សេពគប់ល្អបានល្អ សេពគប់នឹងជនអាក្រក់តែងបានទទួលផលអាក្រក់ ។ រុក្ខជាតិដែលកោងទោរទុះ ព្រោះតែវល្លិ៍មកព័ន្ធ ទោះបីខំប្រឹងធ្វើយ៉ាងណា ក៏មិនសូវរួចពីវល្លិ៍ជាតិឡើយ តែរុក្ខជាតិខ្លះ កោងខ្លួនឯងដោយមិនបាច់វល្លិ៍រុំព័ន្ធក៏មានដែរ ។

មុននឹងទុកចិត្តសេពគប់លើជនណាម្នាក់ តោងយើងពិនិត្យពិច័យ ត្រិះរិះមើលកិច្ចការគុណលក្ខណបរិយាយឲ្យច្បាស់

លាស់ជាមុនសិន កុំគាន់តែឃើញ គេមកដល់ភ្លាម ដោយគេមានសំដីពារោះក្បោះក្បាយ ធ្វើមុខពាសុភាពរាបសារក្អេងក្អាងថា គេជាមនុស្សសុចរិតត្រឹមត្រូវ ហើយបើយើងខ្វះវិចារណញ្ញាណ ជឿទុកចិត្តអស់ពីកន្ទ្រាំខ្លួនភ្លាមនោះ មិនជាការប្រពៃឡើយ ក្រែងបែជឲ្យគាក្រក់កើតឡើង ព្រោះតែជននោះជាមនុស្សក្អេក ៗ ម្នាក់ ១ ត្រូវបេះដូងសង្គ្រោះអ្នកដំណើរ តែត្រូវពិនិត្យសិន ។

## មនុស្សចិត្តជា តែងមានគ្នាជាទីពឹង

កំណិតរៀបចំ

អ្នកប្រាជ្ញបុព្វសម័យ តែងមានមនោគមវិជ្ជាខ្ពង់ខ្ពស់ ចុះឃើញយ៉ាងជាក់ស្ដាន់ នូវវិធានការទាក់ទងគ្នាទៅវិញទៅមក ក្នុងកុលសម្ពន្ធជាតិ ។

មនុស្សចិត្តជា សំដៅយកចំនួនជនមួយភាគ ដែល

www.budinst.gov.kh www.elibraryofcambodia.org

មានហឫទ័យបេះសន្តោសប្រោសប្រណី ដល់អ្នកដទៃ មិនមានចិត្តកន្ទ្រើសប្រស្រាខុសមាត្រា ជួយសង្រ្គោះអ្នកផង ដោយផ្តល់ឲ្យនូវសម្ភារៈ ឬជាគ្រឿងឧបត្ថម្ភសម្រាប់លៀងជីពជន្ម ឬក៏ឲ្យនូវសម្ភារៈសម្រាប់ឧបត្ថម្ភខួរក្បាល បានដល់ការផ្តល់នូវពាក្យប្រៀនប្រដៅណែនាំបង្ហាត់បង្ហាញ ឲ្យដើរទៅរកវឌ្ឍនភាព ផ្នែកក្បួនច្បាប់ប្រព្រឹត្តសុចរិតដោយកាយ, វាចា និងចិត្ត ។

អំពើដែលយើង ធ្វើល្អដល់អ្នកដទៃ តែងបានលទ្ធផលជាទីគាប់ចិត្តដល់យើងវិញ នូវការគប់អាន និងជាទីពឹងពំនាក់ នៃបរជន ដោយពិតប្រាកដ ។

## ត្រូវឲ្យបរិវារទៅ ទើបល្តោភារមក

### គំនិតរៀបចំ

អធិករណ៍ក្តី វិវាទក្តី អ្វីៗ ក៏ដោយ តែងកើត

ឡើង ដោយខ្លួនជាអ្នកបង្ក ទើបអ្នកដទៃហ៊ានលូកដៃចូល (អត្ថៈ ទិន បរៈ) ។ វល្លិជាតិទាំងឡាយមានត្រឡាចជាដើម កាលបើបោះដៃវាទៅប៉ះលើវល្លិជាតិមួយទៀត វល្លិជាតិនោះក៏មិនព្រងើយដែរ តែងបោះដៃវាតោងត្រឡប់មកវិញមិនគប្បីខាន ។

សង្គមជន ក្នុងកាលៈទេសៈ ដែលរស់នៅជាមួយគ្នា សុទ្ធតែមានការទាក់ទងគ្នាទៅវិញទៅមកជាដរាប ។ កាលបើយើងជាម្ចាស់ចំណោទ ហុចសេចក្ដីសុខទៅអ្នកដទៃ អ្នកដទៃតែងផ្ដល់ឲ្យសេចក្ដីសុខមកខ្លួនវិញ ។ បើយើងផ្ដើមផ្ដល់សេចក្ដីទុក្ខដល់គេ គេមុខជាហុចសេចក្ដីទុក្ខមកខ្លួនវិញមិនខាន ។ ដូចនេះ សន្តិភាពក្ដី សង្គ្រាមក្ដី យុត្តិធម៌ក្ដី អយុត្តិធម៌ក្ដី អ្វីៗក្ដី តែងឧប្បត្តិកឡើងពីអត្ថៈទាំងអស់ បើយ៉ាងនេះត្រូវនឹងស្វែងរកសន្តិភាព ។

# ម៉្យឹងចេះឲ្យគេកោត ម៉្យឹងឆោតឲ្យគេអាណិត

## គំនិតរៀបចំ

សភាពរស់នៅនៃមនុស្ស ច្រើនតែស្ថិតនៅក្នុងលក្ខណៈចេះស្ទើរក្អើង ហើយវាយឫកលើកកំពស់ថាខ្លួនគ្រាន់បើ ៗ

យើងកើតមកជាមនុស្ស ត្រូវរៀនវិជ្ជាអ្វីមួយ ឲ្យប្រាកដប្រជាមិនត្រូវចេះស្ទើរ ៗ ហើយបែរទៅរៀនមុខវិជ្ជាផ្សេងទៀតឡើយ ៗ ម៉្យឹងធ្វើអ្នកចេះ ត្រូវចាំក្បួនច្បាប់ឲ្យស្ទាត់សិន ទើបយើងមានប្រសិទ្ធិភាព លើអ្នកផងទាំងពួង ហើយគេក៏កោតញញើតយើងផង កាលបើយើងចេះចាំស្ទើរ ៗ ហើយយើងអួតអាងហួសសមត្ថភាពនោះ គ្មាននរណាម្នាក់គេកោតសរសើរយើងឡើយ ៗ តែបើយើងជាជនឆោតឆៅល្ងង់ខ្លៅ គប្បីទុកខ្លួនឲ្យរាបសា យកគេធ្វើជាមិត្តនាំផ្លូវទៅប្រសើរជាង សមដូចពាក្យថា ពាលណាស្គាល់ថាអាត្មាពាលពិត បែរហៅបណ្ឌិតប្រាកដជាបាន ៗ

# មនុស្សគេយកសំដី ដំរីគេយកភ្លុក

## គំនិតរៀបចំ

ប្រជាជនមួយចំនួន ច្រើនតែផុងខ្លួនក្នុងសំដីប្រទៀសបើស អួតអាងធ្វេប្រវ័ញ្ចហួសព្រំដែន នាំឲ្យខូចប្រយោជន៍ខ្លួនឯង និងប្រយោជន៍អ្នកដទៃ ៗ

សព្វថ្ងៃនេះប្រជាជនគ្រប់រូប រាប់ គេចាត់ទុកជារូបមនុស្សមួយ យ៉ាងវិសេសវិសាលបំផុត ក្នុងការស្វែងរកទ្រព្យសម្បត្តិនិងបុណ្យស័ក្តិ ដើម្បីអបស្តុបជីវិតឲ្យបានថ្កុំថ្កើង ៗ បើយើងបែរក្រឡេកមើលទ្រឹស្តីថា "សំដីជាឯកលេខជាគោ„ យើងដឹងថាសំដីគេចាត់ជាសម្បត្តិទីមួយ ឯគំនូសគេចាត់ទុកជារូបសម្បត្តិទីពីរ ៗ សំដីអាចធ្វើឲ្យជនដែលពោលបន្ទើសម្តីបន្ថយ ធ្លាក់ចុះក្នុងសភាពអបលក្ខណ៍ បាត់អាត្មាអាប់កិត្តិយសរហូតដល់ស្លាប់ខ្លួន ព្រោះតែសំដីនេះឯង ក៏សឹងមាន ៗ

បណ្ដាសត្វទាំងអស់ ដំរីជាសត្វធំចំបងជាងសត្វដទៃ ហើយវត្ថុដែលមានតម្លៃជាចាំបាច់គឺភ្លុក ទោះបីនៅរស់ក៏ដោយ ស្លាប់ទៅក៏ដោយ តែងប្រើការបានសព្វយ៉ាង ៗ

## ទ្រព្យគង់ត្បិតស្រី បេះសំបៃទុក
## ផ្ទះធំស្រណុក ត្បិតលក្ខណ៍ស្រីជា
## គំនិតរៀបចំ

រូបស្ត្រីគេតែងចាត់ជាមេផ្ទះ សម្រាប់តុបតែងគេហដ្ឋាន តាមលក្ខណៈវិជ្ជាមេផ្ទះ ៗ ជាការពិតណាស់ បុរសស្ថិតនៅក្នុងមុខដំណែងជាអាណាព្យាបាលនៃគ្រួសារ ដែលគេទម្លាប់ហៅថា ស្វាមី ប្រែថាម្ចាស់គ្រួសារ ហើយស្វាមីមាននាទី គ្រាន់តែស្វែងរកទ្រព្យយកមកទុកប៉ុណ្ណោះ តែទ្រព្យធនដែលស្ថិតថេរចីរកាលទៅបាន តោងអាស្រ័យលើភរិយាចេះផ្គត់ផ្គង់ចាយវាយ

www.budinst.gov.kh www.elibraryofcambodia.org

សំពៃ និងរុកដាក់ឲ្យមានបែបបទផង ។

គេហដ្ឋានធំទូលាយ ដល់កំរិតណាក៏ដោយ បើមេផ្ទះមិនចេះរៀបចំឲ្យមានរបៀបរៀបរយទេ ប្រាកដជាក្លាយទៅជាគ្រឹះស្ថានចង្អៀតចង្អល់ រកតរកូតមិនខាន ។ ផ្ទុយពីខាងលើនេះ បើផ្ទះតូចតាចកញ្ច្រោកកញ្ច្រាក់រខេករខាក មើលសឹងមិនចង់យល់ក៏ដោយ តែបើស្រីមេផ្ទះចេះតុបតែងឲ្យមានរបៀបទៅ រមែងតែងតែ ប្រែរូបទៅជាផ្ទះធំទូលាយជាប្រច័ក្ខ ។

## ឈើណាគាប់ទុកជារបង ឈើណាត្រង់ ទុកជាបន្ទាត់

### គំនិតរៀបចំ

ព្រៃព្រឹក្សាលតាវល្លិ៍ មានកាចមានស្លូត មានវៀច មានត្រង់ ឈើណាកាច អាចពេលនិងមុតមនុស្សដែល

ប៉ះពាល់ត្រូវវាម្ដងម្កាល តែរុក្ខជាតិដែលមានបន្លាដូចជាដំបងយក្សជាដើម គេអាចយកមកដាំធ្វើជារបងការពារខ្មាំងសត្រូវ ។ ឯឈើណាត្រង់ក្រៅពីយកទៅធ្វើសម្ភារៈប្រើប្រាស់ផ្សេងៗ គេអាចយកទៅធ្វើជាបន្ទាត់ សម្រាប់វាស់វែង បែងជាកំរិតអង្ក្រា ។

មនុស្សកើតមកមានកាចមានស្លូត តែអ្នកប្រាជ្ញពុំបានចាត់មនុស្សកំណាចទុកជាមោឃៈ ឡើយ ដោយចាត់អ្នកទាំងនោះជារបងសម្រាប់ការពារសត្រូវ ក្នុងគ្រាមានអាសន្នទៅវិញ មនុស្សកាចឃោរឃៅ គេមិនចាត់ឲ្យធ្វើជាសភាតំណាងយុត្តិធម៌ឡើយ ។ រីឯមនុស្សស្លូតត្រង់ ក៏គេមិនត្រូវរុញទៅឲ្យការពារខ្មាំងសត្រូវដែរ តែជនបែបនេះ គេទុកជាអ្នកតំណាងសន្តិភាពទៅវិញ ។

www.budinst.gov.kh www.elibraryofcambodia.org

## ផ្ចាញ់កម្លាំងកាយ ដោយកម្លាំងប្រាជ្ញា
## ផ្ចាញ់មនុស្សក្លៀវក្លា ដោយការអង់អាប

### គំនិតរៀបចំ

ដើម្បីបំបាត់ចោលនូវពួកជនដែលកាន់សាប់ជុំ និងជនដែលក្លាហានកាន់អំណាចកំហឹង ទើបលោកអ្នកប្រាជ្ញប្រដៅទុកជាទិដ្ឋានុគតិដូចន័យខាងលើ ។

មនុស្សខ្លាំងពូកែ កាន់សាប់ជុំ អួតកាន់កាប់ចាក់វាយតប់តាមផ្លូវងងឹត យើងមិនត្រូវផ្ចាញ់តបដោយកម្លាំងបាយវិញទេ គឺត្រូវផ្ចាញ់ដោយកម្លាំងប្រាជ្ញា ដោយយកកលល្បិចគម្រិះ តាមមធ្យោបាយសន្តិភាពវិញ ។

ឯពួកជនដែលក្លៀវក្លាហក់លោតដោយសំនួនវោហារគ្រេងគ្រាង យើងត្រូវផ្ចាញ់ដោយការអង់អាប តាមសំនួនវោហារតបវិញ បើយើងហើយធ្វើឫកអាក្រើកៗនោះ ជនក្លៀវក្លារឹតតែបានដៃឡើងពានកំពូលជិះជាន់មិនខាន ។

www.budinst.gov.kh www.elibraryofcambodia.org

យើងម្នាក់ៗ ត្រូវតែផ្ចាញ់ជនដែលមានកម្លាំងកាយ និងជនក្លៀវក្លា ដោយវិធានប្រាជ្ញា និងសេចក្ដីអង់អាចៗ

## ទុព្ភាសិត

### ប្រពន្ធបងស្លាប់បងមិនយំ ដបស្រាបងរលំ បងយំបោកខ្លួន

គំនិតរៀបចំ

គេចង់ប្រដៅមនុស្ស ឲ្យមានគត្តិភាព ទៅលើដបស្រា ថាជាគ្រឿងប្រសើរជាងកិរិយា ដោយបង្ហាញតំម្លៃនៃដបស្រា អាចធ្វើមនុស្សឲ្យស្រឡាញ់ជាងវត្ថុអ្វីៗ ទាំងអស់ៗ គេតែងលើកដំកើងដបស្រាទុកស្មើនឹងជីវិតរបស់គេ ។ ការទុក្ខសោក ចំពោះវត្ថុជាទីស្រឡាញ់ ពុំស្មើនឹងទុក្ខព្រោះដបស្រារលំឡើយ ។

www.budinst.gov.kh www.elibraryofcambodia.org

# បើផឹកស្រាផឹកឲ្យគេសែង ផឹកដើរម្នាក់ឯងផឹកធ្វើអ្វី

## គំនិតរៀបចំ

ប្រដៅជនឲ្យផឹកតាល់តែដេកលូនតាមផ្លូវ ដើរផ្លូវមួយម្នាក់ឯង ដេកដួលតាមចិញ្ចើមផ្លូវ ៗ កាលបើផឹកល្មម ។ ពួកគេមិនឲ្យតម្លៃថាគ្រាន់បើទេ លុះណាតែផឹកឲ្យលិចចុះក្នុងសភាពស្រវឹងអាប់អួ ទើបការផឹកនោះមានតម្លៃ ដល់ក្រុមគេ ៗ គេមិនគិតធ្វើអ្វី ក្រៅពីលើកកែវស្រាផឹកប្រណាំងគ្នា យកឈ្នះចាញ់ ក្នុងចំណោមគូកនគេឡើយ ។ ភគ្មិនេះ តែងបង្អាប់បន្ថោកចំពោះសហការីណាដែលចេះផឹកស្រាមិនស្ទាត់ ឬផឹកស្រាតិច ៗ ការតស៊ូក្នុងការផឹកស្រា ក្រុមនេះបានសន្មតឲ្យតម្លៃយ៉ាងប្រណិតចំពោះជីវិតរស់នៅរបស់គេ ៗ

www.budinst.gov.kh www.elibraryofcambodia.org

យល់ទៅលើការស៊ីផឹក ជាការសំខាន់ ដោយគេឥតបាន ទទួលស្គាល់តម្លៃពុទ្ធសាសន៍ទាល់តែសោះ មិនតែប៉ុណ្ណោះ គេតែងពោលបំអកដល់ជន ដែលមានមនុស្សធម៌ក្នុង ខ្លួនស្គាល់លក្ខណៈព្រះពុទ្ធសាសនា តាំងខ្លួនស៊ប់ក្នុង សាសនាព្រះពុទ្ធ ស្គាល់បុណ្យស្គាល់បាបស្គាល់គុណ ស្គាល់ទោស ។ ប្រភេទជន ដែលមានគំនិតប្រឆាំង នឹងរបបសាសនាសម្រាប់រដ្ឋនេះ គេអាចចាត់ទុកជាជនមួយ ចំនួនតូច ដែលមានមនោគមបរទេស ចូលលុកក្នុងខួរ ក្បាល ហើយបែរមកប្រកួតប្រជែងបំផ្លាញរបបសង្គមនិយមព្រះពុទ្ធសាសនា ដែលជាបេទ្ធិ បង្ហាញនូវផល ប្រយោជន៍ដ៏ត្រចះត្រចង់ ដល់ប្រជារាស្ត្រឥតរើសពណ៌ សម្បុរទៅវិញ ។

(ចប់)

ចាន់-សយ

www.budinst.gov.kh www.elibraryofcambodia.org

បញ្ចសីលា

PANCHA SILA

Les Cinq principes

គោរពទៅវិញទៅមក ដើម្បីសម្បូរណភាព នៃអាណា
ត្តនិងអធិបតីភាព រវាងគ្នានិងគ្នា

*ect mutuel pour l'intégrité territoriale et la souveraine*
*roque*

ះប្រើអំពើឈ្លានពាន

*agression*

ការជ្រៀតជ្រែកទៅវិញទៅមក នូវកិច្ចការ ក្នុងប្រ
បអ្នកផងទៃ

*emnisation réciproque dans les affaires intérieures*

ភាពនូវច្បាប់ និងចិត្តត្រាប្រណី ទៅវិញទៅមក

*ité de droit et bienveillance réciproque*

មរស់ដោយសន្តិភាព

*istence pacifique*


បោះពុម្ពតាមលេខ ៩៦៣ ចុះថ្ងៃទី ១៨-១១-៦៣

បោះពុម្ពលើកទី ១ ចំនួន ២០០០ ក្បាល


ន្ទីរពុម្ព

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org